សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US

7 Video
ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ
- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធនា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ
ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985
660 Middlesex St., Lowell, MA 01851
(978)710-6356

Cambodia daily

## COMMUNE VOTE PITS CPP ROOTS AGAINST CNRP MOMENTUM

**by Ben Paviour | May 19, 2017**

As the country enters its first campaign period since the CNRP nearly upset the ruling party in 2013, the opposition party believes momentum is on its side.



Prime Minister Hun Sen's son Hun Manet pays a goodwill visit to Kampong Speu province, in a photo posted to his Facebook page on Thursday.

-Commune Election 2017-

"I am looking out in front of me, and there are thousands and thousands of women," said CNRP Vice President Mu Sochua on Thursday, moments before speaking at a rally in OddarMeanchey province where organizers had expected a turnout of a few hundred. "We are reaching the grassroots of what used to be the CPP area."

Ms. Sochua has reasons to be optimistic.

Though Prime Minister Hun Sen initially cast his party's near-defeat in 2013 as a wake-up call for state reform, there are few **Continued to Page 18**

# ១០ឆ្នាំនៃការបង្កើតកាសែតខ្មែរផុសក្នុងទឹកដីអាមេរិក

**ដោយ សុខារ័ត្ន កួយ**

អស់រយៈពេល១០ ឆ្នាំមកហើយដែលកាសែតខ្មែរផុសស.រ.អា ចេញផ្សាយ២លេខដែលមាន៣២ទំព័រ ជាទៀងទាត់ក្នុងមួយខែជាភាសាអង់គ្លេសនិងខ្មែរ ដើម្បីពាំនាំនូវព័ត៌មាននយោបាយ, សង្គម, សន្តិសុខ, សុខភាព, វប្បធម៌, ការកំសាន្ត និងការបទវិភាគទាំងក្នុងស្រុក និងអន្តរជាតិប្រកបដោយក្រមវិជ្ជាជីវៈសម្រាប់បំរើដល់សហគមន៍យើងក្នុងសហរដ្ឋអាមេរិក។

ជោគជ័យក្នុងរយៈពេលមួយទសវត្សរ៍ដែលសម្រេចបានេះ គឺដោយសារកិច្ចខិតខំប្រឹងប្រែងធ្វើការងារដ៏លំបាក **តទៅទំព័រទី ០៣**



ខ្មែរផុសថតជាមួយតារាឯកសមាគមអង្គរ

វិភាគនយោបាយកម្ពុជា

# ចាំអ៊ុតលទ្ធផលឆ្នោតឃុំសង្កាត់

**ដោយ ពិន សំខុន**

ប្រជាពលរដ្ឋនៅឡូវែលបានជួយទៅកម្ពុជាច្រើនណាស់ហើយ ដោយមានបំណងចង់ឱ្យបងប្អូនខ្មែរបានសុខសន្តិភាពនឹងរស់នៅបានគ្រប់គ្រាន់ពួកគាត់សង្ឃឹមថានឹងមានការផ្លាស់ប្តូររបៀបគ្រប់គ្រងនៅពេលបោះឆ្នោតខាងមុខនេះ.."ចាំអ៊ុតលទ្ធផល"បោះឆ្នោត គឺប្រើពាក្យអ្នកលេងល្បែងចាក់"អាប៉ោង"។ នៅពេលអាប៉ោងដួលហើយគេមិនបើកតែម្តងទេ តែគេបង្ហើបគ្របតែបន្តិចហើយគេមើលលទ្ធផលដោយទាយអ្វីដែលឃើញពីចំហៀងអាប៉ោងហ្នឹងហើយគេហៅថា "អ៊ុត"



គណបក្សសង្គ្រោះជាតិ



គណបក្សប្រជាជន

រីឯលទ្ធផលធ្វើឱ្យអ្នកលេងល្បែងរំភើបដោយមិនច្បាស់ជាចេញអ្វីដែលគេសង្ស័យថាចេញនោះទេ។ ចំណែកឯការបោះឆ្នោតនៅកម្ពុជាលើកនេះ ថ្ងៃទី៤មិថុនា២០១៧នេះ គឺជាការបោះឆ្នោតលើកដំបូងបង្អស់ដែលទាំងគណបក្សប្រឆាំងនឹងគណបក្សកាន់អំណាចសង្ឃឹមថា **តទៅទំព័រទី ០៨**

មេធាវី លុយហាស្កែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com

សារព័ត៌មាន ខ្មែរផុស ស.រ.អា KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:
Massachusetts:
- Lowell
- Lynn/Revere
Rhode Island:
- Providence
- Cranston
CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us

# Thank you the following sponsors for helping to make the KhmerPost USA #BIG10 Anniversary Celebration possible.

## SPONSORS

*Silver Sponsor*

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

*Bronze Sponsors*

DOLAN

fallonhealth

COMING SOON
Dr. Sokharith Mey, MD
LYNN PRIMARY CARE CENTER (LPCC)
25C Boston Street, Lynn, MA 01904
781-780-7755

LOWELL SPINNERS

***Supporter***
Enterprise Bank
Lowell Five Bank
Remedium Pharmacy
United Healthcare Senior Care Option
University of Massachusetts Lowell

***Reader***
Councilor James Leary
Lowell General Hospital
Trinity EMS
Tufts Health Plan
Middlesex Community College
Conway Insurance
Washington Savings Bank

***Fan***
Athenian Corner
Cambodian Mutual Assistance Association
Cobblestones Restaurant
Councilor John Leahy
Lowell Community Health Center
Eastern Bank
Councilor Rodney Elliott
Former Councilor Vesna Noun

Event Chair
Soben Pin

Celebration Planning Committee
Dahvy Tran
George Anasta
Maria Lobao
Vesna Nuon
Vitchtcha Kong
Sochet Chhen

តមកពីទំព័រទី ០៣

# ១០ឆ្នាំនៃការបង្កើតកាសែតខ្មែរផុស...

និងការលះបង់របស់លោក ពិន សំខុន វ៉ជី ដែលជានិពន្ធនាយក និងជាអ្នកសសេរព័ត៌មាន ដែលធ្លាប់មានបទពិសោធក្នុងការយកព័ត៌មាន សំនាន់ៗក្នុងប្រទេសកម្ពុជា ជាពិសេសលោកជាអ្នកយកព័ត៌មានម្នាក់ក្នុងចំណោម២នាក់តែប៉ុណ្ណោះដែលបានសម្ភាសន៏ជាមួយមេដឹកនាំរបបប្រល័យពូជសាសន៏ខ្មែរក្រហមលោក ប៉ុល ពត។ ជាងនេះទៅទៀតលោក វ៉ជី ក៏ធ្លាប់ជាប្រធានសមាគមន៏អ្នកកាសែតកម្ពុជា (១៩៩៣-១៩៩៧) និងធ្លាប់ជានាយកនៃវិទ្យុអាស៊ីសេរីជាភាសាខ្មែរ (១៩៩៨-២០០៣)។

ទទឹមនឹងនេះបើមិនមានការរួមចំណែកពីអ្នកស្រី សូបិន ពិន ដែលបច្ចុប្បន្នជាសហស្ថាបនិក និងដៃគូរគ្រប់គ្រងកាសែតខ្មែរផុសស.រ.អានោះទេ អាជីវកម្មកាសែតមួយនេះនឹងមិនអាចមានវត្តមាន និងឈានដល់ចំណុចនេះបាននោះទេ។ សូបិន្ត ពិន បានជួបលោក វ៉ជី ហើយបាន រួមគ្នាចាប់ផ្តើមបង្កើតនូវកាសែកខ្មែរផុសឡើងនៅក្រុងហ្វីឡាដែលហ្វ្យ៉ា ក្នុងឆ្នាំ២០០៧ ហើយអ្នកទាំង២បានរៀបការជាមួយគ្នានៅឆ្នាំ២០០៩ដោយមានចំណងដៃកូនប្រុសម្នាក់ឈ្មោះ ពិន ប៉ុណ្ណារ៉ូ អាយដេន ដែលបច្ចុប្បន្នមានអាយុ៦ឆ្នាំហើយ។

ជាមួយនឹងដំណើរការនៃកាសែតខ្មែរផុស ស.រ.អា មកទល់នឹងពេលនេះយើងបានចេញផ្សាយកាសែតចុងក្រោយលេខ២២៤ ហើយជាសរុបក្នុងរយៈពេល១០ឆ្នាំនេះ កាសែតច្រើនជាង ១លានច្បាប់ហើយដែលបានចែកចាយដល់សហគមន៏យើងមានដូចជានៅ ម៉ាសាឈូសេត (ឡូវែល និង លីន/រីវើ) និង រ៉ូដ អាយឡិន ក្រេង ស្តុន នៅ ប្រូវីឌិន។

ជាងនេះទៅទៀត ខ្មែរផុសស.រ.អា ក៏ចូលរួមជាមួយវិទ្យុ WCAP 98.0 AM ជារៀងរាល់ថ្ងៃអង្គារ ចាប់ពីម៉ោង៧ ដល់ម៉ោង១០ព្រឹក ក្នុងកម្មវិធីម៉េរីម៉ាក់ វ៉ាលេ កម្មវិធីពេលព្រឹក

តទៅទំព័រទី១១




សូបិន្ត ពិន




បណ្ឌិត ម៉ាមេត អាលី




លោក អ៊ុង រិទ្ធី




លោក អែនឌី ផេនដលថិន






## For your special day...

## សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក

**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

UMASS LOWELL
Inn & Conference Center



**សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន។

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# 10 Years - 10 Fun Facts about the KhmerPost USA

### Fact #1
### A Life Time Journalist

KhmerPost USA Publisher and Editor Roger Samkhon Pin is a reputable Cambodian Journalist; one of the two people who'd interviewed Pol-Polt in the world. He is the former President of Journalist Association of Cambodia (1993-1997), worked as the Director of Radio Free Asia for Cambodian Service (1998-2003), he then continued his own independent broadcast until 2008. He then met Soben Pin, together they launched the KhmerPost USA. A free biweekly Cambodian-American Newspaper. [Photo Roger Pin interviewed Pol-Pot in 1998 in Anlong Veng, Khmer Rouge Camp]





### Fact #2
### The Co-founder

KhmerPost USA was found in the basement of a friend, Tim Kouch in Philadelphia, Pennsylvania in 2007. A picture of the Co-founder, Soben Pin, who then was in her junior year studying at Penn State University.



### Fact #3
### Marriage

Roger and his co-founder, Soben Pin, married in 2009. It was well attended by family and friends. On their wedding day, one of their close friends introduced Roger as the "18 years old young groom, long time ago!" The truth to be told in their romantic journey who shared the a common passion for journalism: their age gap was 36 years. Soben was then 26 years old.



### Fact #4
### Family

Roger and Soben have one son, Ponnaro Aiden Pin. In 2010, They moved the headquarters of the KhmerPost USA to Lowell, Massachusetts to better serve the Cambodian population in this city and the rest of the New England. They live in Lowell's historic Boott Cotton Mills

.



### Fact #5
### Ponnaro Aiden Pin

KhmerPost USA history would not complete without Ponnaro Aiden Pin, their only son. Aiden is smart and resilient. He grew up around the newspaper and understands his parents commitment and devotion to the newspaper and the people they serve. He endured the long rides, the hot sun, the long Sunday meetings, and try to make the best of the situation. [photo of Aiden at two years old who was excited to pick up newspaper in Western Mass in Fall 2012]



### Fact #6

Today, as we're celebrating our 10 years achievement; the KhmerPost USA has printed 224 editions, over 1 million free copies have shared with Cambodian community in the East Coast of the United States.



### Fact #7
### On the Air

KhmerPost USA joins the WCAP 98.0 AM every Thursday from 7-10am.

Soben Pin, Co-hosts with Teddy Panos for the Merrimack Valley Morning Shows.



### Fact #8
### In TV

We're pleased to bring local news in moving picture to the community at large. Soben Pin reports for LTC Weekly News Broadcast Every Thursday at 6 pm on Chanel 8 & 99



### Fact #9
### In Print

We're connecting 10,000 Khmer-speaking households per month. Free newspaper copies are available in these cities whether it rains or shines:

Massachusetts:
- Lowell,
- Lynn/Revere

Rhode Island:
- Providence
- Cranston

### Fact #10
### Our Team

Sokharath Koy, Staff Writer (Khmer)
Soben Pin,Co-founder/Managing Partner
Sochet Chhen, Office Coordinator
Chhun Leng Heng, Creative Artist



# Updates on New Lowell High School Project

**by Soben Pin**

Public Forums be will held three more sessions before the City Council take vote on Tuesday, June 13 at the Council Chamber at 6:30pm.

They are scheduled as followed:

Thursday, June 8th at the City Council Chamber at 6:30pm

Saturday, June 10th at Lowell High Irish Auditorium at 10am

Monday, June 12th at the Lowell Senior Center at 6:30pm

On Tuesday, June 13th the City Council High School Vote at 6:30pm at the Council Chamber.

Final report on the feasibility study are due on June 2nd and will be available for public to view on the city's website, as well as the city councilors will be getting the information package. Lowell citizens are encouraged to attend at the above three meetings and voice your concerns regarding the New Lowell High School project whether it should be staying in the downtown or moving to the new Cawley Stadium site.




The State of Rhode Island and Providence Plantations
Department of Administration
Division of Human Resources, Office of Classification & Examination

RECRUITMENT ANNOUNCEMENT

**JUVENILE PROGRAM WORKER**

**Salary Range from $43,228 – $49,062* (Pay Grade 22A)**

To provide for the custody, supervision and security of youth detained in the Rhode Island Training School for Youths including assisting in the rehabilitation, education, treatment, care and control of these residents and to do related work as required.

***EDUCATION AND EXPERIENCE:***

Education: Such as may have been gained through: Possession of an Associate's Degree with preferred specialization in a Behavioral Science, or in Social Work; and
Experience: Such as may have gained through: employment in a responsible position in a clinical or correctional treatment facility.

***Application Process:*** *Qualified applicants must pass a BCI/NCIC, Child Protective Screen, Drug Screen, Interview Boards and Psychological Screen.*

All qualified applicants must complete a 4 week Pre-Service Training Academy

APPLICATION PERIOD: All resumes must be received by June 18, 2017

Interested parties should submit resume to the address listed below.

Department of Children, Youth and Families
Attn: Janet Mahoney
101 Friendship Street
Providence, RI 02903

**Open hour and informational sessions will be at the following locations, dates, and times:**

***Youth Transition Center – 790 Broad Street, Providence, RI 02905 – June 5th, 4:00-6:00pm**
***Youth Transition Center – 242 Dexter Street, Pawtucket, RI 02860 – June 7th, 1:00-3:00pm**
***Rhode Island Training School – Youth Development Center – 57 Power Road, Cranston, RI – June 8th, 3:00-6:00pm**

**SPECIAL REQUIREMENTS:**

At the time of appointment must be capable of performing (with or without reasonable accommodation) the essential duties as evidenced by a physician's certificate and must continue to be qualified to perform assigned duties through employment. Must have successfully completed and graduated from Department of Children, Youth and Families Juvenile Correction Pre-Service Training Program. In accordance with RIGL 42-28.3-1 no person shall be appointed temporary, probationary, or permanent until they shall have been evaluated and tested by a certified psychologist and receive a
satisfactory rating which shall be in writing

**After graduating from Pre-Service Training Academy candidates may be placed on a hiring list and offered employment upon positions becoming available.**

**AN EQUAL OPPORTUNITY/AFFIRMATIVE ACTION AND DIVERSITY EMPLOYER.**
Women and minorities are encouraged to apply.
Any individual with a disability who requires assistance to effectively participate in the application process should contact the Department of Administration at the above number prior to the close of the application period.

**Wages subject to union contract*



# ប្រធានាធិបតី"ត្រម"នឹងមេឡីនីញ៉ាស្ត្រីទី១ធ្វើទស្សនៈកិច្ច ផ្លូវការក្រៅប្រទេសដំបូងបង្អស់រយៈពេល៩ថ្ងៃ

**ដោយ ខ្មែរផុសស.រ.អា.**

លោកប្រធានាធិបតីអាមេរិកាំងនឹងស្ត្រីទី១ បានផ្ដើមទស្សនៈកិច្ចផ្លូវការដំបូងបង្អស់នៅមជ្ឈឹមបូព៌ានាទីក្រុង"ហេរូ្សសាឡេម" ថ្ងៃទី២២-២៣ ឧសភានេះ ដើម្បីជួបប្រស្រ័យទាក់ទងជាមួយប្រធានាធិបតី"និតានញ៉ាហ៊ូ"នៃប្រទេសអ៊ីស្រ្តាអែលនឹងលោកប្រធានាធិពាបតី ម៉ាមុត អាបាស នៅ"បេត្លេហែម"នៃប្រទេសប៉ាឡេស្ទីន, គឺជាសញ្ញានៃការស្វែងរកសន្តិភាពដោយការចរចានយោបាយ, តែលោកប្រធានាធិបតី "ត្រម" បែរជាឱ្យន័យដំណើរទស្សនកិច្ចរបស់លោកថា ជាដំណើរសម្រាប់សាសនាទៅវិញ។ "ហេរ្សូ សាឡេម" គឺជាតំបន់ដែលប្រទេសអុី ស្រ្តាអែលបានវាយយកផ្ដាច់ពីប៉ាឡេស្ទីននៅឆ្នាំ១៩៦៧ ហើយមានទំនាស់រវាងប្រទេសទាំង២មកទល់ពេលនេះមិនទាន់ចប់ ហើយក៏គ្មានប្រទេសណាហ៊ានទទួលស្គាល់ថា "ហេរូ្សស្លាឡេម"ថា ជារបស់អុីស្រ្តាអែលនៅឡើយទេ។ ការមកដល់របស់ "ឌុណល ត្រម" គឺជាប្រធានាធិបតីអាមេរិកាំងដំបូងបង្អស់ដែលមកប្រឈមមុខនឹងបញ្ហានៅមជ្ឈឹមបូព៌ាដ៏សេរីប បំផុតនៅ"អុីសនឹងវ៉ៃសបេងគី"។

ល្ងាចទិ២៣លោកប្រធានាធិបតិ"ត្រម"បាន មកដល់"ប្រ៊ុចសែល"នៃប្រទេស"បែលហ្សិក"ដើម្បីប្រស្រ័យទាក់ទងជាមួយសភាសហភាពអឺរ៉ុបនឹងប្រធានអង្គការ"ណេតូ" ថ្ងៃទី២៤ លោកត្រូវជួបសម្តេច"ប៉ូបហ្វ្រង់សីស"នៅវិមាន"វ៉ាទីកង់"មុននឹងទៅចូលរួមប្រជុំប្រមុខ"ណេតូ"នៅក្រុងរូមថ្ងៃទី២៥ឧសភា ។ ជំនួបដ៏មានសារសំខាន់សម្រាប់សហរដ្ឋអាមេរិក គឺសម្ព័ន្ធមិត្រនៅ "ណេតូ" ដែលជាកម្លាំងយោធាក្រៅប្រទេសរបស់សហរដ្ឋអាមេរិក តែអាមេរិកាំងបានយកឱកាសដ៏សំខាន់នេះ


លោកប្រធានាធិបតី ឌុណល ត្រម នៅអារ៉ាប់ប៊ីសាវ៉ុយឌីត

សម្រាប់ទារលុយវិភាគទានរបស់ប្រទេសជាសមាជិកឱ្យ"ចេញប្រាក់ចំណាយឱ្យបានគ្រប់ៗគ្នាពេលនោះ



ណេតូនឹងមានកម្លាំងគ្រប់គ្រាន់សម្រាប់វាយបកភេរវករអាយស៊ីសហើយ" ក៏ប៉ុន្តែប្រទេស (មាន២៣ក្នុងចំណោម២៧ដែលមិនបានបង់វិភាគទាននិយាយថា"គេមិនបានជំពាក់លុយសហរដ្ឋអាមេរិកឬណេតូនោះទេ"។

ជំនួបដ៏សំខាន់មួយទៀត គឺការជួបនឹងប្រមុខនៃរដ្ឋាភិបាលអឺរ៉ុបនៅទីក្រុងប្រ៊ុកសែល លោកស្រីឆាន់សឺល័យ នៃប្រទេសអាលឺម៉ង់ រួមទាំងប្រទេសបារាំងដែលជាមគ្គុទេសនៃអឺរ៉ុប ហាក់ដូចជាសំដែងភាពត្រជាក់ជាមួយសហរដ្ឋអាមេរិកនៅចុងបញ្ចប់នៃទស្សនកិច្ចរបស់"ឌុណល ត្រម" ដោយនិយាយថា "អឺរ៉ុបត្រូវមានសង្ឃឹមលើខ្លួនឯង"។

សហរដ្ឋអាមេរិកកំពុងមានបញ្ហា"ត្រៀមធ្វើសង្គ្រាមជាមួយកូរ៉េខាងជើង"នាវាចម្បាំងធំៗយន្តហោះប្រដេញលឿនៗ ក៏បានទៅប្រចាំការនៅកូរ៉េខាងត្បូងនឹងនៅជប៉ុនដែលជាមុខព្រួញនៃការគម្រាមបាញ់មកលើរបស់កូរ៉េខាងជើង។ ការបញ្ជូនទ័ពដ៏ច្រើនសង្ហឹកនៅទល់មុខកូរ៉េតែមិនឆ្ងាយពីសមុទ្រចិនមិនបានធ្វើឱ្យចិនរីករាយនោះទេ មិនត្រឹមតែចិនមិនទប់កូរ៉េប្រកបដោយប្រសិទ្ធិភាពទេ ថែមទាំងបន្ថែមទំនាក់ទំនងជាមួយនឹងរុស្សីទៀតផង ចិនបានកាត់បន្ថយថាមពលម្ហូបចំណី... មែន ក៏ប៉ុន្តែខាងរុស្សីឯណោះបង្ហូរចូលកូរ៉េខាងជើងនូវអ្វីដែលកូរ៉េខ្វះខាតយ៉ាងសន្ធឹកសន្ធាប់ខុសពីកាណែនាំរបស់អ.ស.ប. ដែលបានដាក់ទណ្ឌកម្មលើប្រទេសកូរ៉េខាងជើងដែលបាញ់សាកកាំជ្រួចផ្លោនទឹងការព្រមានរបស់អ.ស.ប.។

បន្ទាប់ពីទស្សនកិច្ច៩ថ្ងៃរបស់ប្រធានាធិបតី "ត្រម.នៃសហរដ្ឋអាមេរិក នៅអឺរ៉ុប នឹងមជ្ឈឹម



បូព៌ា មានយោបល់កោតសសើរក្នុងស្រុក "តិចតួច"ថា ជាទស្សនកិច្ចប្រកបដោយភាពច្បាស់លាស់មិនស្រពេចស្រពិលជាមួយនឹងអាយស៊ីសទៀតទេ, តែយោបល់ជាច្រើនយល់ថា ជា "ការគ្រោះថ្នាក់បំផុត"ដែលអាមេរិកនៅឆ្ងាយពីណេតូនឹងអឺរ៉ុប។ ចំណែកឯក្នុងស្រុកឯណោះវិញ លោក "ឌុណល ត្រម" ក៏ត្រឡប់មកជួបបញ្ហាស៊ើបអង្កេតទំនាក់ទំនងជាមួយប្រទេសរុស្សីដែលគេរកឃើញកាន់តែជ្រៅទៅហើយ ៕


## ការិយាល័យច្បាប់
### រ៉ូសា និង តាំង


Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា


Andrew 'Bunna' Taing, Esq.
មេធាវី អែន ឲ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

| SERVICES | តំណាងក្ដីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com



## ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៏
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្ដីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**

# MEGAN'S HOUSE
A Residential Treatment Home for Women




មូលនិធិមេកានហោស (The Megan House Foundation) កំពុងរៀបចំលក់សន្លឹកឆ្នោតផ្សងសំណាង ដើម្បីឈ្នះផ្ទះដ៏ថ្មីស្រឡាង ដែលមានទីតាំងនៅ៦0 Gumpus Road ក្រុង Dracut រដ្ឋម៉ាសាជូសេត។ មូលនិធិមេកានហោស (ដែលមានតួនាទីជាអ្នកសម្របសម្រួល ផ្នែករដ្ឋបាល និងវែរអង្គាសថវិកា នៃគម្រោងផ្ទះ Megan's House) កំពុងលក់សន្លឹកឆ្នោតផ្សងសំណាងសម្រាប់វែរអង្គាសថវិការ, បង្កើនការយល់ដឹង និងផ្តល់ឱ្យសហគមន៏នូវឱកាសក្នុងមួយជីវិត! សន្លឹកឆ្នោតនឹងមានសម្រាប់លក់នាពេលឆាប់ៗនេះ ប៉ុន្តែលោកអ្នកអាចចុះឈ្មោះនៅថ្ងៃនេះ ដើម្បីទទួលព័ត៌មានថ្មីៗពីការលក់សន្លឹកឆ្នោតតាមរយៈ www.themeganhouse.org/megans-house-dreams-come-home-raffle ។ ឆ្នោតមួយសន្លឹកលក់ក្នុងតំលៃ $100.00 ហើយមានតែ 5,000សន្លឹក ប៉ុណ្ណោះ នឹងត្រូវដាក់លក់។

គម្រោងស្នាក់នៅ Megan'sHouse គឺជាផ្ទះស្នាក់នៅទូលាយសម្រាប់ស្ត្រីក្មេងៗមានអាយុចន្លោះពី១៨ ដល់២៦ឆ្នាំ ដែលកំពុងតស៊ូជាមួយនឹងការញៀនថ្នាំ និងជំងឺផ្លូវចិត្ត និងការប្រើប្រាស់ថ្នាំប្រភេទញៀនផ្សេងទៀត។ Megan's House ផ្តល់វិធីសាស្ត្ររួម និងចំរុះរយៈពេលវែង ដើម្បីព្យាបាល។ កម្មវិធីនេះរួមមានផ្តល់សេវាកម្មផ្អែកតាមភាពជាក់ស្តែងក្នុងគោលបំណងដើម្បីធ្វើឱ្យគុណភាពនៃជីវិតមានភាពប្រសើរឡើង និងការផ្តល់ជំនាញក្នុងជីវិតសម្រាប់អ្នកស្នាក់នៅ។ លោកអភិបាលរដ្ឋម៉ាសាជូសេត KarynPolito បានឆ្លាតឱកាសមកទស្សនកិច្ច Megan's House ហើយបានមានប្រសាសន៏ជាមួយនឹងអ្នកស្នាក់នៅថា "Megan's House គឺមានតែមួយគត់។ ជារដ្ឋមួយម៉ាសាជូសេត ចាំបាច់ត្រូវគិតគូរពីវិធីដើម្បីធ្វើគម្រោងស្នាក់នៅ Megan's House ច្រើនបន្ថែមទៀតនៅកន្លែងផ្សេងទៀត"។

លោក Tim Grover ដែលជាឪពុករបស់ Megan និងអ្នកបង្កើតគម្រោង Megan's House បានទិញអាគារដែលឥឡូវនេះបានប្រើប្រាស់ជា Megan's House ដើម្បីផ្តល់ជាកន្លែងស្នាក់នៅរយៈពេលវែង ដោយសង្ឃឹមថា កូនស្រីរបស់គាត់ជានិច្ចជាកាលនឹងមានកន្លែងសម្រាប់ស្នាក់នៅក្នុងកំឡុងពេលកំពុងជាសះស្បើយពីការញៀនថ្នាំ។ គួរឱ្យស្តាយ Megan បានបោះបង់ចោលការតស៊ូប្រឆាំងទៅនឹងការញៀន នៅថ្ងៃទី ៣0 ខែធ្នូ ឆ្នាំ ២០១៤។ គម្រោងស្នាក់នៅ Megan's House បានចាប់បើកដំណើរការនៅថ្ងៃទី ៣0 ខែកញ្ញា ឆ្នាំ២០១៥។

លោក Tim Grover បានមានប្រសាសន៏ថា "យើងមានការរីករាយក្នុងការផ្តល់ការគាំទ្រជាច្រើនរបស់យើងក្នុងសហគមន៏នូវឱកាសក្នុងការចូលរួមឆ្នោតផ្សងសំណាងនេះ និងឈ្នះផ្ទះថ្មីដ៏ស្អាតនេះ ទទឹមនឹងនេះក៏ធ្វើឱ្យមានការផ្លាស់ប្តូរក្នុងជីវិតរបស់ស្ត្រីក្មេងៗទាំងនេះ"។

គម្រោងផ្ទះដែលកំពុងតែរៀបចំជាឆ្នោតផ្សងសំណាង គឺជាប្រភេទផ្ទះសងថ្មី មានទំហំ 2,000 square foot, មានបន្ទប់ដេក 3, មានបន្ទប់ទឹក 2.5 (Colonial situated on a quiet) ស្ថិតនៅតាមផ្លូវលំនៅដ្ឋានក្នុងក្រុង Dracut រដ្ឋម៉ាសាជូសេត និងមានតំលៃ $454,900 ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វ៉ិបសាយរបស់យើងខ្ញុំ តាមរយៈអាសយដ្ឋាន www.themeganhouse.org ។ សមាជិកអគ្គនាយកនៃគណកម្មការមូលនិធិមេកានហោសនឹងចូលរួមក្នុងកម្មវិធីប្រារព្ធខួប១0ឆ្នាំនៃការបង្កើតសារព័ត៌មានខ្មែរផុស ស.រ.អា សម្រាប់លោកអ្នកដើម្បីជាវសន្លឹកឆ្នោតនៃគម្រោងផ្ទះ Megan's House រឺលោកអ្នកអាចចូលទៅ On-line តាមរយៈអាសយដ្ឋាន www.themeganhouse.org\raffle ៕







តមកពីទំព័រទី ០១

## ចាំអ៊ុតលទ្ធផលឆ្នោតឃុំសង្កាត់...

នៅថ្ងៃបើកគ្រប់ចេញមកគេសង្ឃឹមថា នឹងទទួលបាននូវ"លទ្ធផលពិតប្រាកដ"ជាមិនខាន, ខុសគ្នាពីពេលមុនៗ បន្ទាប់ពីបោះឆ្នោត "អ៊ុនតាក់" ឆ្នាំ១៩៩៣មក ការបោះឆ្នោតនិមួយៗ តែងតែឱ្យ "លទ្ធផលខុសពីពេលអ៊ុតជាដំរាប"។

គណបក្សប្រឆាំងបានចំណាយពេលមួយអាណត្តិ(៥ឆ្នាំពី២០១៣-១៨)ចុងក្រោយ សម្រាប់រៀបឱ្យប្រើយន្តការថ្មីដើម្បីឱ្យបាន"លទ្ធផលពិតប្រាកដ"ដែលចង្អុលអ្នកឈ្នះពិតប្រាកដ ហើយដែលនឹងអាចបញ្ចៀសសង្គ្រាមក្នុងស្រុកបានទៀតផង។ ក្រោមសម្ពាតគណបក្សសង្គ្រោះជាតិគណបក្សប្រជាជនកាន់អំណាចបានសុខចិត្តដោយគ្មានជម្រើសផ្សេងទទួលយកការបង្កើតគ.ជ.ប.ថ្មី ឱ្យមានសមាជិកគណបក្សប្រឆាំងពាក់កណ្តាលនៅក្នុងនោះ ជាថ្នូរនឹងភាពស្របច្បាប់របស់សមាជិកសភាគណបក្សប្រជាជនរបស់ខ្លួន។ ជាមួយគ្នានោះមានការធ្វើបញ្ជីបោះឆ្នោតសារជាថ្មីជ្រើសរើសគណកម្មការប្រតិបត្តិគ.ជ.ប.ថ្មី ដែលជាហេតុធ្វើឱ្យដៃគណបក្សប្រជាជននៅឆ្ងាយពីយន្តការបោះឆ្នោតថ្មីដែលយន្តការថ្មីនោះ ផ្តើមសាកល្បងប្រសិទ្ធិភាពជាលើកដំបូង នៅថ្ងៃទី៤មិថុនាខាងមុខនេះ ក្នុងសេចក្តីសង្ឃឹមយ៉ាងច្រើនរបស់គណបក្សសង្គ្រោះជាតិថា: "ខ្លួននឹងឈ្នះ តែបើចាញ់ឆ្នោតទៅវិញ ក៏នឹងបន្តការតស៊ូរបស់ខ្លួនទៅទៀតបានកុំឱ្យតែមានការលួចបន្លំសន្លឹកឆ្នោត" ចំណែកឯប្រធានគណបក្សប្រជាជននៅតែស្រែកថា "បើគណបក្សប្រជាជនចាញ់ឆ្នោតនឹងមានសង្គ្រាម" ថែមទាំងចោលពាក្យថា: "នឹងអាចកម្ចាត់អ្នកប្រឆាំងចោល២០០-៣០០នាក់ក៏ដោយ ដើម្បីរក្សាដំណែងលោកក្នុងរដ្ឋាភិបាលដដែល" តែកម្លាំងឃោធានឹងការគម្រាមរបស់លោក ហ៊ុន សែន មិនបានធ្វើឱ្យបក្សប្រឆាំងនឹងអ្នកគាំទ្រខ្លួបខ្លាចឡើយ។

នៅមួយអាទិត្យមុនថ្ងៃកំណត់(៤មិថុនា) ការឃោសនាស្របច្បាប់បង្ហាញពីភាព"ហ៊ឹកហាក់"របស់គណបក្សប្រឆាំងនៅតាមដងផ្លូវតូចធំនៃទីក្រុងនឹងជនបទ, រីឯខាងគណបក្សប្រជាជនវិញគេចង់បង្ហាញភាព"ហ៊ឹហា"ដោយធ្វើកិច្ចប្រជុំធំៗបញ្ចាំងតាមទូរទស្សន៍ នៅតាមមហាសាលធំៗនាទីក្រុងមានមនុស្សម្នារាប់ពាក់នាក់ចូលរួមមានទាហ៊ានមានប៉ូលិសថែមទៀត, នៅមានអង្គការក្រៅរដ្ឋាភិបាលកោះប្រជុំជា"វេទិការដេញដោល"សម្រាប់ផ្តល់ការវិនិច្ឆ័យលើបេក្ខជនដល់ម្ចាស់ឆ្នោត,មានប្រមុខរដ្ឋាភិបាលនៅតែស្រែកគម្រាមថា"បើគណបក្សប្រជាជនចាញ់ឆ្នោតនឹងមានសង្គ្រាមរដ្ឋាភិបាលអាចនឹង...នៅឡើយ", រីឯគណបក្សសង្គ្រោះជាតិដែលជាគណបក្សតែមួយគត់ដែលមានកម្លាំងគ្រប់គ្រាន់សម្រាប់ប្រឈមមុខនឹងគណបក្សប្រជាជន នាំគ្នាថ្ងូរថា "គេធ្វើអ្វីៗបានតែយើងធ្វើមិនបានទេ គេចាប់យើងដាក់គុក...", នៅមានគណបក្សតូចៗ ដែលនៅសល់ក្នុងបញ្ជីបេក្ខជនមានគណបក្សហ៊ុនស៊ិនប៉ិច គណបក្ស ខឹមវាស្នា, បានត្រូវគេជឿថា ជាគណបក្សរណបគណបក្សកាន់អំណាចមានតួនាទីសម្រាប់បំបែកសន្លឹកឆ្នោតចេញពីគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ។ ថ្វីត្បិតតែមានសញ្ញាគម្រៀមកំហែងធ្ងន់ខ្លះៗ ដែលលើកឡើងដោយគណបក្សសង្គ្រោះជាតិក៏ដោយគេអាចមើលឃើញថា: មានបរិយាកាសសន្តិភាពគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋកក់ក្តៅនឹងហ៊ានធ្វើការវិនិច្ឆ័យ ហើយចេញទៅបោះឆ្នោតបានហើយ, មកត្រឹមនេះ ជាបំណងគណបក្សសង្គ្រោះជាតិដែលបានប្រាថ្នាបន្ទូរបរិយាកាសមិនបង្កើតលេសថ្មីៗ សម្រាប់ប្រមុខរដ្ឋាភិបាលចោទប្រកាន់ ហើយរឹតបន្តឹងការគម្រាមកំហែងមកលើខ្លួនថែមទៀតទេ។

គណបក្សដែលចូលប្រកួតក្នុងការបោះឆ្នោតឃុំសង្កាត់មាន១២មែន តែមានទេគណបក្ស២តែ



លោក ហ៊ុន សែន គំរាមសម្លាប់មនុស្ស

ប៉ុណ្ណោះដែលមានសមត្ថភាពដាក់បេក្ខជនគ្រប់ចំនួន(ប្រមាណ១២៦០០រូប)សម្រាប់ការគ្រប់គ្រងគណកម្មការឃុំសង្កាត់១៦៤៦ក្នុងប្រទេសទាំងមូល។ គណបក្សប្រជាជនបានធ្វើឱ្យលោក សម រង្ស៊ី បានខ្ទាតចេញពីដំណែងប្រធានគណបក្សសង្គ្រោះជាតិដោយសង្ឃឹមថា គណបក្សនេះនឹងរលំដោយគ្មានមេពូកែរ ក៏ប៉ុន្តែគឺជាការភ័ន្តច្រឡំថ្មីមួយទៀតរបស់លោក ហ៊ុន សែន ពីព្រោះមិនត្រឹមតែសង្គ្រោះជាតិនៅតែរឹងមាំ តែបានធ្វើឱ្យសម រង្ស៊ី ក្លាយជាទារុណភាពដែលគេជឿថាសន្លឹកឆ្នោតរឹតតែផ្ទេរច្រើនឡើងទៅគណបក្សសង្គ្រោះជាតិទៀតផង ។ គណបក្សសង្គ្រោះជាតិបានចាត់ទុកថាការបោះឆ្នោតឃុំសង្កាត់ពេលនេះ "ជាដំណាក់ការសំខាន់បំផុត"សម្រាប់អនាគត

**តទៅទំព័រទី ១០**



# ការលះបង់គោរមងារជាម្ចាស់ក្សត្រីដើម្បីស្នេហានៃខ្សែរាជ្យវង្សរបស់ជប៉ុន

**ប្រែសម្រួលដោយខ្មែរផុស**

សមាជិកគ្រួសាររាជ្យវង្សម្នាក់របស់ជប៉ុន គឺម្ចាស់ក្សត្រី ម៉ាកូ (Mako) ត្រូវបានគេជឿជាក់










ថានឹងបាត់បង់តំណែងជាម្ចាស់ក្សត្រីដោយសារព្រះនាងបានស្រលាញ់ និងរៀបការជាមួយនឹងជនធម្មតាម្នាក់ដែលមិនជាប់ខ្សែរាជវង្ស។ ព្រះនាងម៉ាកូមានព្រះជន ២៥ វស្សា ត្រូវជាចៅស្រីរបស់ព្រះចៅអធិរាជ្យអាគីហ៊ីតូ(Akihito)ដែលមានព្រះជន្ម ៨៣វស្សានិងត្រូវភ្ជាប់ពាក្យជាមួយអតីតមិត្តរួមថ្នាក់របស់ព្រះនាង គឺលោក គី កូម៉ូរូ (Kei Komuro) មានអាយុ២៥ឆ្នាំ ដូចគ្នាហើយនឹងរៀបការនៅឆ្នាំក្រោយនេះ។

**ប្រវត្តិរបស់ព្រះនាង ម៉ាកូ និងលោកគី កូម៉ូរូ**

ព្រះនាង ម៉ាកូ ប្រសូត្រនៅខែតុលា ឆ្នាំ១៩៩១ជាបុត្រីច្បងរបស់ព្រះអង្គម្ចាស់ ហ្វូមីហ៊ីតូ (Fumihito) និងម្ចាស់ក្សត្រី គីកូ (Kiko) ហើយត្រូវជាចៅស្រីរបស់ព្រះចៅអធិរាជ្យអាគីហ៊ីតូ (Akihito)។ ព្រះនាងបានសិក្សានៅសាលាបឋមសិក្សា Gakushuin ក្នុងឆ្នាំ១៩៩៨ និងបានបន្តការសិក្សានៅវិទ្យាល័យ Gakushuin Girls។ នៅឆ្នាំ២០១០ ព្រះនាងបានចុះឈ្មោះសិក្សានៅមហាវិទ្យាល័យឺជូ College of Liberal Arts ដោយចាប់យកជំនាញសិល្បៈនិងបេតិកភណ្ឌវប្បធម៌។

ព្រះនាងបានបន្តការសិក្សានៅសកលវិទ្យាល័យ Edinburgh ក្នុងឆ្នាំ ២០១២ ហើយ បន្ទាប់ពីការបញ្ចប់ការសិក្សារបស់ព្រះនាងពីមហាវិទ្យាល័យ Edinburgh ក្នុងឆ្នាំ២០១៤ ព្រះនាងបានចូលរួមក្នុងកម្មវិធីឧត្តមសិក្សារបស់មហាវិទ្យាល័យ Leicester ដើម្បីសិក្សាជំនាញ museology រយៈពេល២ឆ្នាំ។ បច្ចុប្បន្នព្រះនាងជា affiliate researcher នៅសកលវិទ្យាល័យតូក្យូ។

ចំណែកគូរស្នេហរបស់ព្រះនាង លោក កូម៉ូរូ រស់នៅជាមួយម្តាយ និងជីតា។ នៅពេលលោកជាសិស្សសកលវិទ្យាល័យលោកបានចូលរួមក្នុងសកម្មភាពជំរុញផ្នែកទេសចរណ៍សម្រាប់ក្រុង Fujisawa ក្នុងខេត្តគានាង awa ដោយមានរហស្សនាមថា "prince of the sea" នៅ Shonan-Enoshima។ បច្ចុប្បន្នលោកកំពុងសិក្សាថ្នាក់អនុបណ្ឌិតផ្នែកច្បាប់អាជីវកម្មនៅមហាវិទ្យាល័យ Hitotsubashi University និងបំរើការងារក្នុងក្រុមហ៊ុនច្បាប់នៅក្រុងតូក្យូប្រទេសជប៉ុន។

**ទំនាក់ទំនងស្នេហា**

ប្រព័ន្ធផ្សព្វផ្សាយជប៉ុនបានផ្សាយថា ព្រះនាង ម៉ាកូ និងលោក កូម៉ូរូ បានជួបគ្នានៅកិច្ចប្រជុំពិភាក្សាមួយអំពីការសិក្សានៅក្រៅប្រទេសកាលពីខែមិថុនា ឆ្នាំ២០១២ ក្នុងក្រុងតូក្យូ និងបានចាប់ផ្តើមជួបគ្នាជាបន្តបន្ទាប់ចាប់ពីពេលនោះមក។ អ្នកទាំងពីរតែងតែជួបគ្នាពីរបីដងក្នុងមួយខែ។ អ្នកទាំង២បច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលធ្វើផែនការភ្ជាប់ពាក្យ។

**ច្បាប់គ្រួសារអធិរាជ្យ**

ទំនាក់ទំនងរបស់អ្នកទាំងពីរ បើតាមប្រពភព័ត៌មានបានឱ្យដឹងថា មាតាបិតារបស់ព្រះនាងម៉ាកូ បានទទួលស្គាល់រួចហើយ ហើយបើតាមច្បាប់គ្រួសារអធិរាជ្យរបស់ប្រទេសជប៉ុនឆ្នាំ ១៩៤៧ គឺសមាជិកគ្រួសារស្ត្រីរបស់គ្រួសារអធិរាជនឹងត្រូវដកហូតតំណែងជាព្រះនាង នៅពេលដែរសមាជិកគ្រួសារជាស្ត្រីរៀបការជាមួយជនធម្មតា ហើយតំរូវឱ្យម្ចាស់ក្សត្រីចាកចេញពីគ្រួសាររាជ្យវង្សទៅរស់នៅពិភពលោកខាងក្រៅ។

បន្ទាប់ពីចាកចេញព្រះនាងនឹងទទួលបានថវិការសម្រាប់ការចំណាយក្នុងការរស់នៅរបស់អ្នកទាំងពីរ។ ជាងនេះទៅទៀត ព្រះនាងនឹងសិទ្ធបោះឆ្នោត, ត្រូវបង់ពន្ធជូនរដ្ឋ, ដើរទិញឥវ៉ាន់ និងធ្វើការងារផ្សេងៗដោយព្រះនាងផ្ទាល់។ ប្រសិនបើអ្នកទាំងពីរមានបុត្រ, រាជ្យបុត្រនោះ


## ទទួលផលកាន់តែច្រើនដែលចំណាយតែ $0

ជាមួយនឹងកម្មវិធី NaviCare® HMO SNP ឬកម្មវិធី NaviCare® SCO, លោកអ្នកទទួលបានផលប្រយោជន៍យ៉ាងច្រើនជាងអត្ថប្រយោជន៍ទូទៅ ព្រមទាំងអត្ថប្រយោជន៍ចំពោះថ្នាំតាមវេជ្ជបញ្ជាដែលមានផ្តល់ជូនតែតាមរយៈកម្មវិធី MassHealth Standard និងកម្មវិធី Medicare ។ សូមហៅទូរស័ព្ទមកជួបយើងខ្ញុំក្នុងថ្ងៃនេះ!

NaviCare

**1-866-274-5389 (TRS សម្រាប់អ្នកពិបាកស្តាប់ និងពិបាកមើល 711)**

**fallonhealth.org/navicare**

ពីម៉ោង 8 ព្រឹក–8 យប់
ថ្ងៃច័ន្ទ–ថ្ងៃសុក្រ

fallonhealth

*NaviCare គឺជាកម្មវិធីរបស់ផែនការថែទាំសុខភាព HMO ដោយមានកិច្ចសន្យាជាមួយនឹងកម្មវិធី Medicare និងកិច្ចសន្យាជាមួយនឹងកម្មវិធី Massachusetts Medicaid ។ ការចុះឈ្មោះចូលជាសមាជិកក្នុងកម្មវិធី NaviCare បាន ឬមិនបាន គឺអាស្រ័យការបន្តកិច្ចសន្យាថ្មីជាមួយនឹងកម្មវិធីទាំងនោះ ។ NaviCare ជាកម្មវិធីស្ម័គ្រចិត្តដោយសហការណ៍ជាមួយនឹងកម្មវិធី MassHealth/EOHHS និងកម្មវិធី CMS ។ កម្មវិធី NaviCare SCO មាន ផ្តល់សេវាកម្មដល់ពលរដ្ឋគ្រប់រូបដែលមានអាយុ 65 ឆ្នាំ និងចាស់ជាងនេះ ដែលមានឈ្មោះទទួលបានអត្ថប្រយោជន៍ពីកម្មវិធី MassHealth Standard ហើយរស់នៅក្នុងតំបន់ដែលកម្មវិធីនេះផ្តល់សេវាជូន ។ ពលរដ្ឋដែល មានឈ្មោះទទួលអត្ថប្រយោជន៍ពីកម្មវិធី Medicare Parts A នឹង B អាចចុះឈ្មោះចូលជាសមាជិកកម្មវិធី NaviCare SCO បាន ។ លោកអ្នកត្រូវបន្តបង់ប្រាក់បុព្វលាភធានារ៉ាប់រងសុខភាពដល់កម្មវិធី Medicare Part B របស់អ្នក ប្រសិនបើ Commonwealth of Massachusetts មិនបានបង់ថ្លៃធានារ៉ាប់រងនេះឲ្យលោកអ្នកទេនោះ ។*

14-679-096KH Rev. 00 9/14 H9001_N_2015_54KH Accepted 10072014

# បណ្ដឹងតំណាងពលរដ្ឋភាគតិចប្រចាំក្រុងឡូវែលប្រឆាំងប្រព័ន្ធបោះឆ្នោតប្លុករបស់រដ្ឋ

**ប្រែសម្រួលដោយ សុខារ័ត្ន កូយ**

ឡូវែល- ក្រុងឡូវែល គឺជាក្រុងមួយដែលមានការផ្លាស់ប្ដូរអស់រយៈពេលជាច្រើនទសវត្សរ៍ ដោយជនភៀសខ្លួនមកពីប្រទេសកម្ពុជា និងជនអន្តោប្រវេសន៍មកពីអាមេរិកឡាទីននិងអាហ្រ្វិច។ ក្រុងឡូវែលដែលធ្លាប់តែមានពលរដ្ឋស្បែកសរច្រើនជាង៩០% ជាងបួនទសវត្សរ៍មកនោះ ឥឡូវនេះមានការផ្លាស់ប្ដូរដោយចំនួនពលរដ្ឋភាគតិចមានការកើនឡើងរហូតដល់៤៩%។

ក្នុងចំណោម៤៩%នេះ ពលរដ្ឋអាស៊ីអាមេរិកមានចំនួនប្រហែល២២% នៃចំនួនប្រជាជនសរុបក្នុងក្រុងឡូវែលដោយរាប់បញ្ចូលទាំងសហគមន៍ខ្មែរធំជាងគេបំផុតទីពីរក្នុងចំណោមសហគមន៍ផ្សេងទៀតក្នុងសហរដ្ឋអាមេរិក។ ប៉ុន្តែវិសាលភាពនៃអំណាចពេលបច្ចុប្បន្ននេះគឺមើលទៅដូចគ្នាកាលពីទសវត្សរ៍ទី៨០។ ស្ទើរតែជាប្រវត្តិសាស្ត្ររបស់ទីក្រុងឡូវែលទៅហើយដែល សមជិក៩ រូបនៃក្រុមព្រឹក្សាក្រុង និងសមជិក៦ រូបនៃគណៈកម្មការសាលាក្រុងឡូវែល (Lowell School Committee) គឺតែងតែជាបេក្ខជនស្បែកសរ។

ទាក់ទងនឹងកង្វះតំណាងភាគតិចនេះកាលពីថ្ងៃទី១៨ ខែឧសភានេះមានពាក្យបណ្ដឹងរួមមួយទាក់ទងនឹងច្បាប់សិទ្ធបោះឆ្នោតសហព័ន្ធបានធ្វើឡើយដោយពលរដ្ឋអាស៊ីអាមេរិក និងស្ពេននីស, ឡាទីនណូដោយចោទប្រកាន់ថា ប្រព័ន្ធបោះឆ្នោតក្រុងរបស់ក្រុងឡូវែលមានការរើសអើងចំពោះសំលេងភាគតិច។

បើតាមការឱ្យដឹងពីគណៈកម្មាធិការមេធាវីសម្រាប់ការពារសិទ្ធិស៊ីវិលនិងយុត្តិធម៌សេដ្ឋកិច្ចថា នៅក្នុងពាក្យបណ្ដឹងបានបញ្ជាក់ថា ការប្រើប្រាស់ការបោះឆ្នោតជ្រើសរើសតំណាងភាគច្រើនក្រុងទាំងមូលសម្រាប់កៅអីទាំងអស់របស់ក្រុមប្រឹក្សាក្រុងឡូវែល និងគណៈកម្មាធិការសាលាក្រុងឡូវែលបានបំបាត់អំណាចបោះឆ្នោតរបស់អ្នកបោះឆ្នោតភាគតិចក្នុងក្រុងឡូវែលដែលរំលោភលើច្បាប់សិទ្ធិបោះឆ្នោតសហព័ន្ធ ព្រមទាំងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកផងដែរ។

ពាក្យបណ្ដឹងនេះ ក៏បានលើកឡើងដែរថា យោងតាមប្រព័ន្ធច្បាប់បោះឆ្នោត "Winner Take All" បេក្ខជនមានចំនួនសម្លេងឆ្នោត ៥១% អាចគ្រប់គ្រងកៅអីទាំងអស់ និងឈ្នះរាល់ការបោះឆ្នោតតែម្ដង។ ក្នុងពាក្យបណ្ដឹងដដែលនោះក៏បានលើកឡើងថា ប្រព័ន្ធបោះឆ្នោតនេះ គឺគ្រាន់តែជាអ្វីដែលបានកើតមានឡើងក្នុងក្រុងឡូវែលដែលប្រព័ន្ធនៃការបោះឆ្នោតនេះ បង្កើតជាការបែកខ្ញែកខាងពូជសាសន៍មានន័យថា ពលរដ្ឋស្បែកសក្នុងក្រុងបានបោះឆ្នោតប្លុក (bloc) ដែលជារឿយៗតែងតែឈ្នះលើបេក្ខជនដែលគាំទ្រដោយពលរដ្ឋភាគតិច។

លោក អូរ៉េន ស៊ែលស្ដម ជាអគ្គនាយកនៃ



គណៈកម្មាធិការមេធាវីសម្រាប់ការពារសិទ្ធិស៊ីវិល និងយុត្តិធមិសេដ្ឋកិច្ច និងជាមេធាវីម្នាក់ក្នុងចំណោមមេធាវីតំណាងឱ្យដើមបណ្ដឹងបានមានប្រសាសន៍ថា "សិទ្ធិបោះឆ្នោត និងគោលការណ៍សិទ្ធិធ្វើការបោះឆ្នោតរបស់បុគ្គលម្នាក់គួរតែរាប់ដោយស្មើគ្នាគឺជាស្នូលសំខាន់បំផុតនៃលិទ្ធិប្រជាធិបតេយ្យ ហើយប្រព័ន្ធបោះឆ្នោតបច្ចុប្បន្នរបស់ក្រុងឡូវែល បំពាន់ទៅនឹងសិទ្ធជាមូលដ្ឋាននេះ"។

ជាមួយគ្នានេះដែរ លោក រ៉ូប៊ឺត ចន ដែលដឹកនាំក្រុមមេធាវីតំណាងឱ្យងដើមបណ្ដឹងដោយមិនគិតពីកំរៃសេវាបានលើកឡើងថា "សមាជិកជាច្រើននៃសហគមន៍ឡូវែលបានសម្ដែងការព្រួយបារម្មណ៍ជាច្រើនឆ្នាំមកហើយថា ប្រព័ន្ធបោះឆ្នោតរបស់ក្រុងឡូវែល គឺមិនមានភាពត្រឹមត្រូវនោះទេ"។ លោកបានបន្តថា "ដើមបណ្ដឹងក្នុងករណីនេះគឺពលរដ្ឋឡូវែលដែលគោលបំណងរបស់ពួកគេ គឺដើម្បីឱ្យប្រាកដថា អ្នកបោះឆ្នោតគ្រាប់សាវតាទាំងអស់ គឺត្រូវមានតំណាងរបស់ខ្លួនត្រឹមត្រូវ"។

នៅក្នុងបណ្ដឹងក៏បានលើកឡើងឧទាហរណ៍នៃការបោះឆ្នោតក្រុមប្រឹក្សាក្រុងឆ្នាំ២០១៣ បេក្ខជនដើមកំណើតខ្មែរអាមេរិក ២ រូប គឺលោក វ៉ាសនា នួន និង វ៉ាន ឡឿនពេច។ បេក្ខជនទាំងពីរត្រូវបានគាំទ្រដោយពលរដ្ឋទាំងអ្នកបោះឆ្នោតអាស៊ីអាមេរិក ព្រមទាំងស្ពេននីស,ឡាទីនណូ លើសពីបេក្ខជនផ្សេងៗទៀតទាំងអស់ដោយឈរលំដាប់បេក្ខជនជំរើសទីមួយ និងទីពីររៀងៗគ្នា។

ប៉ុន្តែក្នុងចំណោមបេក្ខជនទាំងអស់ចំនួន ១៨ រូប បេក្ខជនទាំងពីរ គឺជាប់ជាជំរើសទី ១៧ និង១៨ ក្នុងចំណោមប្លុកបោះឆ្នោតគ្រប់ដណ្ដប់ដោយជនជាតិស្បែកសរដែលមានចំនួនច្រើនជាង។ ជាលទ្ធផលនោះគឺថា អ្នកទាំងពីរមិនបានឈ្នះកៅអីសម្រាប់ក្រុមប្រឹក្សាក្រុងនោះទេ ដោយផ្អែកតាមក្បួនច្បាប់ "Winner Take All" ដោយសំលេងឆ្នោតរបស់ពលរដ្ឋស្បែកសរមានចំនួនច្រើនជាងសំលេងរបស់អ្នកបោះឆ្នោតមិនមែនស្បែកសរ។ ចំណែកឯការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសាលាក្រុងឡូវែលវិញទំរងបៀបបទនៃការការបោះឆ្នោត ក៏ត្រូវបានរៀបចំស្រដៀងគ្នានេះផងដែរដោយអនុវត្តប្រព័ន្ធបោះឆ្នោតខាងលើ។ បណ្ដឹងដដែលក៏បានបន្ថែមថា ដោយសារសំលេងភាគតិចខ្វះតំណាងនៅក្នុងសាលាក្រុងដូចច្នេះហើយបានជាសេវាបកប្រែ គឺកំពុងតែមានការខ្វះខាត់ និងពលរដ្ឋមិនមែនស្បែកសរកំរត្រូវជ្រើសរើសឱ្យមកបំរើការងារក្នុងក្រុងណាស់។ ឧទាហរណ៍ដូចជាប្រហែលជាជិត៨០%នៃមន្ត្រីប៉ូលីស និងច្រើនជាង៩០% នៃការងារមហាវិទ្យាល័យនិងបុគ្គលិកក្នុងសាលារដ្ឋក្នុងក្រុងឡូវែល គឺជាពលរដ្ឋស្បែកសរ។

តាមការលើកឡើងរបស់លោក ហួត ចាន់មុនី ដែលជាពលរដ្ឋដើមកំណើតខ្មែរនៅឡូវែល ហើយក៏ជាដើមបណ្ដឹងមួយរូបបានឱ្យកាសែតក្នុងស្រុកដឹងថា កង្វះតំណាងចំរុះក្នុងរដ្ឋបាលក្រុងឡូវែលធ្វើឱ្យជះផលមិនល្អដល់សហគមន៍ភាគតិចនៃក្រុងឡូវែល និងធ្វើឱ្យរដ្ឋបាលក្រុងឡូវែលឆ្លើយតបតិចតួចចំពោះតំរូវការរបស់ប្រជាពលរដ្ឋ។ លោក ឡាឌីមាយ សាលដានា ដែលជាដើមបណ្ដឹងមកពីសហគមន៍ស្ពេននីស,ឡាទីនណូ ក៏បានបញ្ជាក់ថា អ្នកបោះឆ្នោតទាំងអស់ក្នុងក្រុងឡូវែល គួរតែមានសំលេងស្មើគ្នានៅក្នុងប្រអប់ឆ្នោត ប៉ុន្តែបច្ចុប្បន្ននេះ បេក្ខជនដែលត្រូវបានជ្រើសរើសជាតំណាងមិនត្រូវបានផ្ដល់ការទទួលខុសត្រូវចំពោះសហគមន៍ដែលមិនមែនស្បែកសរនោះទេ។ លោក ឡាឌីមាយ បានបន្ថែមទៀតថា "គោលបំណងនៃបណ្ដឹងនេះគឺដើម្បីធានាថាពលរដ្ឋទាំងអស់នៃឡូវែល និងក្នុងសហគន៍ទាំងអស់ គឺមានតំណាងនៅក្នុងរដ្ឋបាលក្រុង"។

ដើមបណ្ដឹងដែលរួមមានពលរដ្ឋភាគតិចច្រើនជាង១២សហគមន៍ ចង់ឱ្យសាលាក្រុងរៀបចំឱ្យមានប្រព័ន្ធបោះឆ្នោតថ្នាក់ខ័ណ្ឌ ឬស្រុកដែលអាចបើកផ្លូវឱ្យសំលេងភាគតិចមានឱកាសខ្លាំងឡើងក្នុងការជ្រើសរើសជាបេក្ខជនក្នុងក្រុមព្រឹក្សាក្រុង និងគណៈកម្មការធិការសាលាក្រុង។ បើតាមការលើកឡើងរបស់លោកអភិបាលក្រុង មេយ័រ អែតវត ឃែននីឌី ក្រុងឡូវែលបានដំណើរតាមប្រព័ន្ធបោះឆ្នោតសំលេងភាគច្រើន រឺប្លុក (at-large election system) ចាប់តាំងពីឆ្នាំ ១៩៤៣ មកម្ល៉េះ៕

---

តមកពីទំព័រទី ០៨

## ចាំអ៊ុតលទ្ធផលឆ្នោតឃុំសង្កាត់...

របស់គណបក្សខ្លួនក្នុងការចូលទៅកាន់កាប់អំណាចប្រទេស -ងាកទៅគណបក្សប្រជាជនវិញ ហាក់ដូចជាមិនចាត់ទុកថា: ជាដំណាក់ការសំខាន់បំផុតរបស់ពួកគេទេ គឺដំណាក់ការបោះឆ្នោតសភាជាតិឆ្នាំ២០១៨ឯណោះទេ ដែលមានសារសំខាន់បំផុតនោះ, យ៉ាងនេះគេអាចយល់យ៉ាងងាយស្រួលថា: "ទោះជាបាត់បង់មេឃុំខ្លះក៏ដោយក៏នឹងនៅមានសមាជិកឃុំសង្កាត់របស់ខ្លួនខ្លះៗ នៅក្នុងគណកម្មការឃុំសង្កាត់និមួយៗដែរ ទាំងនោះហើយដែលជាបណ្ដាញពតិមានរបស់គណបក្សប្រជាជនក្នុងឃុំសង្កាត់ទាំងអស់ ដែលនឹងគាំទ្រដោយក្រសួងមហាផ្ទៃរបស់គណបក្សប្រជាជនបានដដែលនៅពេញមួយឆ្នាំក្រោយ"។

ការ "អ៊ុតសន្លឹកឆ្នោត" លើកនេះ មិននៅក្នុងការគ្រប់គ្រងគណបក្សប្រជាជនទាំងមូលដូចមុនទៀតទេ ហេតុនេះហើយបានជាយើងទស្សន៍ទាយថា: គណបក្សសង្គ្រោះជាតិអាចនឹងឈ្នះឆ្នោតជាលើកដំបូងបង្អស់របស់ខ្លួន ហើយនឹងមានគ.ជ.ប. ឯករាជ្យជាអ្នកធ្វើសេចក្ដីប្រកាសលទ្ធផលផសតែបើទោះជាចាញ់ក៏ដោយក្ដី ក៏នេះប្រាកដជាជោគជ័យរបស់ប្រទេសកម្ពុជាជាលើកដំបូងបង្អស់គិតចាប់តាំងពីបន្ទាប់សម័យ "អ៊ុនតាក់" មកម្លេះ។ នៅមានមន្ទិលមួយនៅឡើយ ដោយសារតែគណបក្សប្រជាជននៅតែដឹកនាំដោយលោកនាយករដ្ឋមន្ត្រីដដែល តាំងតែពីឆ្នាំ១៩៩៣មក ហើយភាពស្មោះត្រង់មិនដែលមានម្ដងណាឡើយនោះ គេនៅសង្ស័យនៅឡើយថា: គណបក្សប្រជាជននៅតែបង្កប់ល្បិច ដើម្បីយកឈ្នះក្នុងការបោះឆ្នោតរបៀបថ្មីទៀតជាមិនខានឡើយ ពីព្រោះលោក ហ៊ុន សែន នឹងសហការីមិនដែលអៀនខ្មាស់នឹងផ្ដើនលើល្បិច ដែលទោះជាគេបានលាតត្រដាងច្បាស់ក្រឡែតហើយក៏ដោយនោះទេ។ គេក៏នៅរង់ចាំមើល ថាតើកម្លាំងអំណាចផ្ដាច់ការនិយមនៅពេលដែលគ.ជ.ប.ប្រកាសជាផ្លូវការថា "គណបក្សប្រជាជនបានឆ្នោតតិចជាងគណបក្សសង្គ្រោះជាតិ" នោះ, បើគ្មានអំណាចផ្លូវការទេ តើគណបក្សប្រជាជនអាចកាចបានប៉ុណ្ណាទៅ? ៕

# តមកទំព័រទី ០៣ ១០ឆ្នាំនៃការបង្កើតកាសែតខ្មែរផុស...

ដោយមានលោកស្រី សូបិន្ត ពិន និងលោក តេឌី ផេនូស ជាពិធីករក្នុងកម្មវិធី ហើយយើងក៏បានចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានក្នុងស្រុកតាមរយៈកម្មវិធីទូរទស្សន៍ LTC Weekly News Broadcast ប៉ុស្តិ៍លេខ ៨ និង៩៩ ជារៀងរាល់ថ្ងៃរខុកថៃល, ការសម្តែងរបាំប្រពៃណី, អាហារ ពេលល្ងាច, និងចុងបញ្ចប់នៃកម្មវិធីមានការរាំកំសាន្តជាមួយក្រុមភ្លេងតន្ត្រីខ្មែរ។

យើងសង្កេតឃើញថា នៅក្នុងឱកាសនោះមានវាគ្មិនចំនួន ៣ រូប គឺលោក អែនឌី ផេន័យផុសដល់អ្នកចូលរួមទាំងអស់។

នៅក្នុងពិធីនោះផងដែរយើងចាប់អារម្មណ៍ឃើញថា ការជួបជុំនេះមិនត្រឹមតែបង្ហាញឱ្យឃើញពីការគាំទ្រចំពោះកាសែតខ្មែរផុស និងសាមគ្គីភាពរបស់សហគមន៍ទាំងមូលប៉ុណ្ណោះទេ ថែមទាំងជាឱកាសមួយក្នុងការចែករំលែកបទពិសោធន៍ និងបង្កើនទំនាក់ទំនងគ្នាទៅវិញទៅមកថែមទៀត។

គឺលោក ហុង ណេត លោកស្រី រីតា ម៉ៃសែល និងលោក អែនឌី ផេន័រថេន ផងដែរ និងបានថ្លែងអំណរគុណចំពោះការគាំទ្រ និងការអញ្ជើញចូលរួមក្នុងព្រឹត្តការណ៍នេះ។

ជាចុងក្រោយក្រុមកាងារការសែតខ្មែរផុស ស.រ.អា សូមថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភ, អ្នកគាំទ្រ, អ្នកអាន និងអ្នកចូលចិត្តកាសែកដែល


ភ្ញៀវកិត្តិយសរបស់ខ្មែរផុស


អែនឌី ថតជាមួយ ចេត គីម និង សំខុន


រដ្ឋបាលនៅមាត់ទ្វារចូល

អង្គារ វេលាម៉ោង៦ល្ងាច។

តាមរយៈសមិទ្ធិផលនៃការបំរើសហគមន៍យើង និងចង់បង្ហាញពីមោទនភាពដែលខ្មែរមានកាសែតជាភាសារបស់ខ្លួនក្នុងទឹកដីអាមេរិក យើងបានរៀបចំប្រារព្ធពិធីខួបគម្រាប់១០ឆ្នាំនៃការបង្កើតកាសែតខ្មែរផុសស.រ.អា កាលថ្ងៃសុក្រទី១៩ ខែឧសភា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលយូម៉ាស់ឡូវែល អ៊ីង និងមណ្ឌលសម្រាប់ប្រជុំដើម្បីអបអរសាទរជាមួយនឹងបងប្អូនទាំងអស់។


គូរី បាលែនជី រីដា មីសសែល យន់ ជូ ជីម លេរី



ក្នុងកម្មវិធីនេះមានចូលរួមពីសំណាក់លោកអភិបាលក្រុងឡូវែល, តំណាងរាស្រ្តខ្មែរក្រុងឡូវែល, តំណាងរាស្ត្រក្រុងលីន, ប្រធានសមាគមន៍ខ្មែរប្រចាំឡូវែលក្រុមតន្ត្រី ហ្វរ យូ (4 U), ក្រុមរបាំអង្គរដានគ្រូបនិងតំណាងក្រុមហ៊ុន និងអាជីវករជាច្រើនទៀត មានចំនួនប្រហែល៣០០នាក់ ដើម្បីអបអរ និងគាំទ្រដល់សកម្មភាពនៃកាសែតខ្មែរផុស។ ព្រឹត្តការណ៍នោះមានការរៀបចំការសិសាថេន អតីតអ្នកសម្របសម្រួលគម្រោងរបស់អង្គការសហប្រជាជាតិ (United Nations) នៅជំរំជនភៀសខ្លួនជាយដែនខ្មែរថៃក្នុងទស្សវត៩០, លោក ហុង ណេត ជាសមាជិកក្រុមប្រឹក្សាភាគច្រើនក្រុងលីន និងអ្នកស្រី ឈៃរីល ប៊ូវែល នាយករងនៃការិយាល័យ ODEO បានឡើងបង្ហាញនូវបទពិសោធន៍ការងារ និងការយល់ឃើញចំពោះសកម្មភាពរបស់កាសែកខ្មែរ

នៅចុងបញ្ចប់នៃកម្មវិធីលោក រ៉ជី និង សូបិន្ត ពិន បានទទួលនូវបានការកោតសរសើរអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការងាសារព័ត៌មានពីសំណាក់តំណាងរាស្ត្រខ្មែរក្រុងលូវែល និង លីន ចំពោះការរួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍អស់រយៈពេល១០ឆ្នាំកន្លងមកនេះ ព្រមទាំងបានទទួលលិខិតកោតសរសើរ និងពានរង្វាន់អ្នកសារព័ត៌មានឆ្នើមពីតំណាងក្រុង លីនបានគាំទ្រចំពោះវិស័យព័ត៌មានជាភាសាខ្មែរ និងភាសាអង្លេសយើងខ្ញុំឱ្យដំណើរការបានគងវង្សរហូតដល់បច្ចុប្បន្ននេះ។ យើងនឹងបន្តខិតខំប្រឹងប្រឹងធ្វើនូវអ្វីដែលយើងកំពុងធ្វើនេះបន្តទៅទៀត ហើយសង្ឃឹមថានឹងបានជួបគ្នាក្នុងឱកាសខួបទី១១ឆ្នាំរបស់កាសែតយើងខ្ញុំនៅខែឧសភា ឆ្នាំ២០១៨ខាងមុខ៕


ម៉ាយគិល ខនវ៉េ បៀវល សាម៉ារ៉ា ពិន រ៉ជី ចច អណាស្តា


ខ្មែរផុសថតជាមួយលោក ហុង ណេត និងភរិយា


លោក ហុង ណេត អានប័ណ្ណកោតសរសើរពីក្រុងលីន


បុប្ផា ម៉ាឡូន អេចេ សេង សេលេះ ប៊ុណ្ណាដូ រ៉ាឌី ម៉ម សាយ័ន សឿង


ប្រេឌី -វ៉ាសនា នួន- សូបិន្ត ពិន- ជីម លីរី


សូបិន្ត -ពិនពិន រ៉ជី -សុផលបែន អែនី វ៉ែន -ស្រីនាង -ផលីន លិ



## ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

### ប្រជាធិបតេយ្យនិងមិនមានឥទ្ធិពលបរទេស

យើងបានផ្តល់យោបល់ពីអត្ថបទមុន ដើម្បីសម្រេចចិត្តបោះឆ្នោតឲ្យគណបក្សណាមួយ ត្រូវពិនិត្យមើលគណបក្សណា ដែលអនុវត្តគោលការណ៍ពីរប្រការគឺ អនុវត្តរបបប្រជាធិបតេយ្យយ៉ាងពិតប្រាកដ និង មិនទាក់ទងនឹងឥទ្ធិពលបរទេស។

**ប្រជាធិបតេយ្យ** ទើបមានសន្តិភាព ដែលផ្ទុយគ្នាពីពាក្យរបស់លោកឈឹម ផលវុណ្ណអ្នកនាំពាក្យរបស់គណបក្សប្រជាជនកម្ពុជាថា គេមិនគិតពីប្រជាធិបតេយ្យទេ គេគិតពីសន្តិភាព។ តើជាការពិតទេ ពិតមែនពុំមានចម្បាំងដោយអាវុធទាល់នឹងអាវុធ ប៉ុន្តែអាជ្ញាធរខ្មែររំលោភសិទ្ធិមនុស្ស រំលោភសិទ្ធិពលរដ្ឋ រំលោភយកដី ប្រើហិង្សាទៅលើអ្នកបញ្ចេញមតិ ធ្វើទុក្ខបុកម្នេញគណបក្សប្រឆាំង បង្កើតលេសចាប់អង្គការ ការពារសិទ្ធិមនុស្សដាក់ពន្ធនាគារជាដើម ដែលមជ្ឈដ្ឋានជាតិនិងអន្តរជាតិថ្កោលទោស រដ្ឋាភិបាលតែងតែបដិសេធជានិច្ច។ ការមិនគោរពសិទ្ធិពលរដ្ឋដែលជាម្ចាស់អំណាចក្នុងរបបប្រជាធិបតេយ្យនេះហើយដែលគ្មានសន្តិភាព។ **ប្រជាធិបតេយ្យ** មកពី ប្រជានិងអាធិបតេយ្យ ប្រែថា មានប្រជាពលរដ្ឋជាធំ គឺអំណាចរដ្ឋកើតចេញពីប្រជាពលរដ្ឋ តាមរយៈការបោះឆ្នោត ពលរដ្ឋជាម្ចាស់អំណាច ប៉ុន្តែផ្ទុយទៅវិញ សព្វថ្ងៃនេះ អ្នកកាន់អំណាចខ្មែរ ទុកពលរដ្ឋជាសត្វតិរច្ឆាន តែងតែគម្រាមកំហែង ចង់វាយដំ ចាប់ដាក់គុកពេលណាក៏បាន។ **ពលរដ្ឋខ្មែរមានអំណាចគឺសន្លឹកឆ្នោតក្នុងដៃហើយ គប្បីបោះឲ្យគណបក្សដែលអនុវត្តរបបប្រជាធិបតេយ្យពិតប្រាកដ នេះជាគោលទីមួយ។**

ឥទ្ធិពលវៀតណាមនៅតែមានទៅលើគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីការប្រកាសដកទ័ពរបស់ខ្លួនចេញពីកម្ពុជាកាលពីឆ្នាំ១៩៨៩ ដោយគ្មានការត្រួតពិនិត្យ បានទុកចារកិច្ច អ្នកជំនាញការគ្រប់ផ្នែក នៅក្នុងក្រសួងធំៗរបស់ខ្មែរ ផ្លាស់ឈ្មោះហើយចេះភាសាខ្មែរយ៉ាងស្ទាត់ជំនាញ សម្រាប់ផ្តល់យោបល់និងពង្រឹងគណបក្សប្រជាជនកម្ពុជាក្នុងការដឹកនាំឲ្យរឹងមាំ ជាអាណានិគមលាក់មុខ ផ្សេងពីលាវ។ សន្ធិសញ្ញាបំពេញបន្ថែមសម្បទានដីរាប់លានហិកតា៩៩ឆ្នាំ អន្តោប្រវេសន៍វៀតណាមខុសច្បាប់គ្មានការត្រួតពិនិត្យ។ ប្រទេសគ្មានឯករាជ្យនៅក្រោមអំណាចបរទេស ជាគ្រោះថ្នាក់ធ្ងន់ណាស់ដល់កម្ពុជា បំបែកខ្មែរដើម្បីត្រួតត្រា។បក្សប្រជាជនដកខ្លួនពីឥទ្ធិពលវៀតណាមបានទេ? **ពលរដ្ឋខ្មែរគប្បីបោះឆ្នោតឲ្យតែបក្សមិននៅក្រោមវៀតណាម៕**

វត្តខ្មែរកាណាដា,ថ្ងៃ២៨ឧសភា២០១៧:www.hoksavann.org;savannhok@yahoo.com

ព័ត៌មានខ្លីៗ

## បេក្ខជនចៅហ្វាយក្រុងឡូវែលឆ្នាំ២០១៧

ឆ្នាំនេះនរណាខ្លះឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាក្រុងឡូវែល នៅមុនឱកាសអនុញ្ញាត្តិឱ្យឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាក្រុងឡូវែល សម្រាប់អាណត្តិ២០១៨-១៩ ផ្លូវការ



វដ្ឋា យ៉ែម



ប៉ាន់ សូ

ខ្មែរប៉ុស្តស.រ.អា. បានទទួលដំណឹងថា: មានអ្នកនឹងឈរឈ្មោះខ្មែរ-អាមេរិកាំង៣នាក់ បានសម្រេចចិត្តរួចហើយ

**១-**លោក វ៉ាស្នា នួន អតីតសមាជិកក្រុម



វ៉ាស្នា នួន

ប្រឹក្សាក្រុងឡូវែល

**២-**លោក វដ្ឋា យ៉ែម ពាណិជ្ជករអចលនវត្ថុ

**៣-** លោក ប៉ាន់ សូ សាស្ត្រាចារ្យមធ្យមសិក្សា

គួររំលឹកថា សាលាក្រុងឡូវែលមានសមាជិកក្រុមប្រឹក្សា៩រូប តែពុំមានខ្មែរ-អាមេរិកាំងណាម្នាក់ជាប់ឈ្មោះនាអាណត្តមុនៗនេះទេ ៕


THE SPIEGEL CENTER
ADVANCED FACIAL AESTHETICS



**ជឿទុកចិត្តលើមុខរបស់អ្នក អ្នកជំនាញមួយ!**

យើងមានបទពិសោធន៍ និងជំនាញក្នុងការងារតែមួយគត់
គឺ Rhinoplasty ការវះកាត់ត្របកភ្នែកពីរជាន់
ដកចេញស្លាកស្នាមលើផ្ទៃមុខ និងធ្វើឲ្យបប្ញូរមាត់ស្រស់ស្អាត។
ជាអ្នកត្រួសត្រាយក្នុងថ្នាំ Botox និងធ្វើស្បែកឲ្យល្អឡើងវិញ។
សម្រាប់ការព្យាបាលល្អបំផុត ដោយវេជ្ជបណ្ឌិតដ៏ល្បីបំផុតក្នុងលោក
សូមទាក់ទងមជ្ឈមណ្ឌល Spiegel

617-566-3223

THE SPIEGEL CENTER, 1200 Boylston Street, Chestnut Hill, MA 02467
www.drspiegel.com

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។




ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
អាយុ ២២ ឆ្នាំឡើងទៅ
- មាសហ៊ែលស្តង់ដា

ផលប្រយោជន៍ទទួលបាន :

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណើរប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# មេឃុំប្ដឹងអ្នកកាសែតដែលសួរសំណួរអ្នកភូមិពាក់ព័ន្ធការបោះឆ្នោត

**ដោយ វណ្ណ រឿន និង ហ្វូច រ៉ាយត៍ | ថ្ងៃពុធ ទី២៤ ខែឧសភា ឆ្នាំ២០១៧**

មេឃុំម្នាក់បានដាក់ពាក្យបណ្ដឹងផ្លូវការប្ដឹងអ្នកយកព័ត៌មានកាសែត ខេមបូឌា ដេលី ពីរនាក់ដែលបានសម្ភាសអ្នកភូមិក្នុងខេត្តរតនគិរី ជាផ្នែកមួយនៃការយកព័ត៌មានស្ដីពីការបោះឆ្នោតឃុំសង្កាត់ របស់កាសែតនេះ ដោយចោទប្រកាន់អ្នកទាំងពីរថាចូលមក "ក្នុងគោលបំណងមិនល្អ"។

ពាក្យបណ្ដឹងដែលបានប្ដឹងកាលពីថ្ងៃច័ន្ទមានខ្លឹមសារថា "ពួកគេចូលមកក្នុងគោលបំណងមិនល្អ។ ពួកគេមកធ្វើការស្រាវជ្រាវតាមដានក្នុងការបោះឆ្នោត និងញុះញង់ប្រជាពលរដ្ឋ"។

លោក ដាក្លាស ស្ទៀល (Douglas Steele) នាយកគ្រប់គ្រងទូទៅ និងជាមេធាវីនៃកាសែតខេមបូឌា ដេលី បានមានប្រសាសន៍កាលពីម្សិលមិញថា អ្នកយកព័ត៌មានទាំងពីរនាក់នេះគ្រាន់តែបំពេញការងាររបស់ខ្លួនប៉ុណ្ណោះ ហើយបានចាត់ទុកពាក្យបណ្ដឹងនេះថា "មិនសមហេតុផលទេ"។

លោកបានសួរថា "អ្នកយកព័ត៌មានសួរសំណួរអំពីនយោបាយអំឡុងយុទ្ធនាការឃោសនាបោះឆ្នោត តើវាមិនមែនជាផ្នែកនៃការងាររបស់ពួកគេទេ?"។

លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានធ្វើឱ្យស្ថានភាពនេះកាន់តែតឹងតែងឡើងកាលពីម្សិលមិញ ដោយបង្ហោះច្បាប់ចម្លងនៃលិខិតឆ្លងដែនមួយរបស់អ្នកយកព័ត៌មានទាំងពីរនាក់នៅក្នុងទំព័រហ្វេសប៊ុករបស់លោក ហើយបានព្រមានអ្នកកាសែតទាំងអស់ឱ្យដឹងអំពីច្បាប់។

លោក ខៀវ កាញារីទ្ធ បានសរសេរថា "សូមអ្នកកាសែតទាំងអស់រៀនច្បាប់បោះឆ្នោត និងក្រមសីលធម៌ក្នុងពេលបោះឆ្នោតឱ្យបានខ្ជាប់ខ្ជួន ចៀសវាងការចោទប្រកាន់នានា"។

ពាក្យបណ្ដឹងនេះត្រូវបានប្ដឹងដោយលោក រ៉ម៉ាម យួត មេឃុំប៉ាតេនៃគណបក្ស សម រង្ស៊ី ក្នុងស្រុកអូរយ៉ាដាវ ជាឃុំតែមួយគត់ក្នុងខេត្តនេះដែលគណបក្សប្រឆាំងជាប់ជាមេឃុំ ក្នុងឆ្នាំ ២០១២។

ដោយដាក់ពាក្យបណ្ដឹងទៅអភិបាលស្រុក ពាក្យបណ្ដឹងនេះពាក់ព័ន្ធសំណួរដែលអ្នកទាំងពីរនាក់នេះសួរប្រជាពលរដ្ឋនៅក្នុងឃុំនេះ។

ពាក្យបណ្ដឹងនេះលើកឡើងថា អ្នកភូមិត្រូវបានសួរថា?" តើប្រជាពលរដ្ឋបោះឆ្នោតឱ្យគណបក្សណាក្នុងឆ្នាំ២០១២? ហេតុអ្វីបានជាខេត្តរតនគិរីបោះឆ្នោតជាប់ឆ្នោតគណបក្សប្រជាជនទាំងអស់ មានតែភូមិគងធំ ឃុំប៉ាតេឈ្នះឆ្នោតលើគណបក្សសម រង្ស៊ី? តើមានវិធីសាស្ត្រ និងយុទ្ធនាការបែបណាបានជាជាប់ឆ្នោត?"។

ពាក្យបណ្ដឹងដដែលនេះបន្តថា អ្នកយកព័ត៌មានទាំងពីរនាក់នេះ "បានញុះញង់ប្រជាពលរដ្ឋ" ដោយមិនគោរពច្បាប់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត?ដែលបានប្រកាសមិនឱ្យនិយាយពីនយោបាយពេលដែលកំពុងធ្វើការដង្ហែក្បួនយុទ្ធនាការឃោសនាបោះឆ្នោត"។ បណ្ដឹងដដែលនេះមិនបានលើកឡើងពីច្បាប់ជាក់លាក់ណាមួយដែលតាមចោទថា អ្នកយកព័ត៌មានទាំងពីរនាក់នេះរំលោភឡើយ។

អ្នកយកព័ត៌មានទាំងពីរគឺលោក Zsombor Peter និងលោក អូន ភាព ដែលរងបណ្ដឹងរបស់គាត់បានធ្វើសេចក្ដីរាយការណ៍យ៉ាងច្រើនអំពីការកាប់ឈើខុសច្បាប់ដ៏រាលដាលក្នុងតំបន់នេះ រួមទាំងការស៊ើបអង្កេតកាលពីសប្ដាហ៍មុនដែលរកឃើញថា មានយោធាជាប់ពាក់ព័ន្ធក្នុងករណីនេះ។

លោក ម៉ា វិចិត្រ អភិបាលនៃគណៈអភិបាលស្រុកបានមានប្រសាសន៍ថា អ្នកយកព័ត៌មានទាំងពីរនាក់នេះក៏បានធ្វើហួសព្រំដែនផងដែរ ដោយសម្ភាសលោកមេឃុំអំពីបញ្ហានយោបាយនៅក្នុងការិយាល័យរបស់លោក។ លោកបានមានប្រសាសន៍ថា ពួកគេគួរតែសួរអំពី "ការអភិវឌ្ឍ" ជំនួសវិញ។

លោកបានថ្លែងថា "វាខុសហើយក្នុងការសួរសំណួរទាក់ទងរឿងនយោបាយដល់លោកមេឃុំនៅក្នុងការិយាល័យឃុំរបស់លោក។ សូមឱ្យកូនចៅកុំធ្វើអញ្ចឹង"។

នៅពេលទាក់ទងក្រោយមក លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍ថា "លោកគ្រាន់តែរំឭកប្រាប់អ្នកកាសែតទាំងអស់ឱ្យមានការប្រុងប្រយ័ត្នតែប៉ុណ្ណោះ"។ នៅពេលសួរថាតើហេតុអ្វីបានជាលោកគិតថា ចាំបាច់ត្រូវបង្ហោះព័ត៌មានលម្អិតអំពីលិខិតឆ្លងដែន លោកថ្លែងថា វាគ្រាន់

# REPORTERS TARGETED OVER ELECTION QUESTIONS

**by George Wright and Van Roeun | May 24, 2017**

A commune chief has filed an official complaint against two Cambodia Daily reporters who interviewed villagers in Ratanakkiri province as part of the newspaper's commune election coverage, accusing them of arriving "with bad intentions."

"They came with bad intentions. They came to research, monitor the election and incited people," the complaint filed on Monday says.

Douglas Steele, general manager and general counsel of The Cambodia Daily, yesterday said the reporters were just doing their jobs and described the complaint as "a bit absurd."

"Reporters asking questions about politics during an election campaign-isn't that part of the job?" he asked.

Information Minister KhieuKanharith further escalated the situation yesterday, posting a copy of one of the reporters' passports on his Facebook page and warning journalists to be aware of the law.

"Please, all journalists, learn the laws on elections and strictly adhere to code of ethics during the elections to avoid any accusations," Mr. Kanharith wrote.

The complaint was filed by RomamYuot, the Sam Rainsy Party commune chief of Pate commune in O'yadaw district, the only commune in the province that elected an opposition commune chief in 2012.

Filed to the district governor, the complaint takes issue with the questions the reporters were asking people in the commune.

"What party did people vote for in 2012? Why in the 2012 election in Ratanakkiri province did the CPP win all, except in Kong Thom village, Pate commune, where the Sam Rainsy Party won? What kind of strategy and campaign made [the party] win the election?" the complaint says villagers were asked.

The two reporters "incited people" by not respecting the National Election Committee's law "that does not allow discussion of politics during the election campaign," it says. The complaint makes no mention of any specific law the reporters allegedly broke.

The two reporters who were the subject of his complaint, Zsombor Peter and AunPheap, have extensively reported on the area's rampant illegal logging, including an investigation last year that found military involvement in the trade.

District governor Ma Vichet said the reporters had also overstepped the mark by interviewing the commune chief about politics in his office. They should have discussed "development" instead, he said.

"It is wrong to ask questions related to politics to the commune chief in his commune office," he said. "Please, ask your reporters to not do that."

Mr. Kanharith, contacted later, said he was "just reminding all journalists to be cautious." Asked why he felt the need to post passport details, he said it was to "show [the] case."

Political analyst Cham Bunthet said it appeared that there were little grounds for the complaint.

"The role of the media is to report, right?" he said. "People need to know the facts…in that commune and that's the role of the reporters: to report that to the people in that district or nationwide."

Mr. Kanharith's decision to post the passport details of the foreign reporter was likely an effort to cow other journalists in the run-up to the election, Mr. Bunthet said.

"I think that's a form of intimidation, a warning and a threat. It's happened for a long time already from him and other people so I don't see that as a surprise," he said.

Just two weeks ago, Prime Minister Hun Sen called out two reporters, including one from the Daily, during a media briefing at the World Economic Forum on Asean in Phnom Penh, saying journalists who did not report properly on the government would be seen as "servants of the foreigners."

The complaint comes just days after the Information Ministry warned that media outlets must abide by the NEC's "Guidelines for Cambodia elections" or face being shut down.

However, the guide clearly states that the duty of the media is to "find and broadcast the news about the opinions and different ideas of all involved people during the election process."

The Sam Rainsy Party, to which the commune chief, Mr. Yuot, belongs, merged with the Human Rights Party after the commune elections in 2012 to form the CNRP, currently the main opposition party in the country. When the new party selected commune candidates for this year's elections on June 4, Mr. Yuot was left off the ballot, and said at the time that he was shocked by the decision.

**(Additional reporting by Kim Chan)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# អង្គការលើកលែងទោសអន្តរជាតិរិះគន់ប្រព័ន្ធតុលាការ ដ៏ពុករលួយនៅក្នុងប្រទេសកម្ពុជា

**ដោយ ហ្គូច រ៉ាយត៍ និងឆន ភារុណ | ថ្ងៃអង្គារ ទី៣០ខែឧសភា ឆ្នាំ២០១៧**

នៅថ្ងៃនេះ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានចោទប្រកាន់គណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចថា ប្រើអំណាចរបស់ខ្លួនលើប្រព័ន្ធតុលាការដើម្បីយាយី និងបំភិតបំភ័យអង្គការសង្គមស៊ីវិលជាប្រព័ន្ធហើយបានជំរុញឱ្យរដ្ឋាភិបាលដកពាក្យបណ្តឹងលើសកម្មជនគណបក្សប្រឆាំង និងអ្នកការពារសិទ្ធិមនុស្ស។

មន្ត្រីជាន់ខ្ពស់អង្គការអាដហុក ៤ រូប និងមន្ត្រីជាន់ខ្ពស់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោក នី ចរិយា ជាការឆ្លើយតបអ្នកនាំពាក្យរដ្ឋាភិបាលបានចាត់ទុកអង្គការសិទ្ធិមនុស្សមួយនេះជា "សត្រូវរបស់រដ្ឋាភិបាល" ហើយអះអាងថា មន្ត្រីអង្គការសង្គមស៊ីវិលទាំងនោះជាប់ពន្ធនាគារដោយសារល្មើសច្បាប់។

របាយការណ៍ "តុលាការអយុត្តិធម៌" របស់អង្គការលើកលែងទោសអន្តរជាតិដែលបានចេញផ្សាយនៅព្រឹកនេះ?រិះគន់រដ្ឋាភិបាលលើសំណុំរឿងជាច្រើនរួមមានពាក្យបណ្តឹងលើអ្នកស្រី ទេព វន្នី ដែលជាសកម្មជនដ៏លេចធ្លោមន្ត្រីសិទ្ធិមនុស្សទាំងបច្ចុប្បន្ន និងអតីតដែលគេហៅរួមគ្នាថា មន្ត្រីអាដហុកទាំងប្រាំ និងមន្ត្រីគណបក្សសង្គ្រោះជាតិដែលត្រូវបានផ្តន្ទាទោសពីបទ "បះបោរ" នៅក្នុងឆ្នាំ២០១៤។

របាយការណ៍នេះលើកឡើងថា "ចាប់តាំងពីការបោះឆ្នោតសកលលើកចុងក្រោយនៅខែកក្កដា ឆ្នាំ២០១៣មក ប្រព័ន្ធយុត្តិធម៌របស់កម្ពុជា ហាក់បាននិងកំពុងតម្រង់គោលដៅវាយប្រហារទៅរកអ្នកការពារសិទ្ធិមនុស្សឱ្យ HRD និងសកម្មជនគណបក្សប្រឆាំងជាប្រព័ន្ធ"។

អង្គការលើកលែងទោសអន្តរជាតិគូសបញ្ជាក់ថា បច្ចុប្បន្នមានអ្នកទោសនយោបាយយ៉ាងតិច ២៧នាក់ នៅក្នុងប្រទេសកម្ពុជា ខណៈអង្គការសិទ្ធិមនុស្សក្នុងស្រុកលីកាដូថាមានចំនួន២៥នាក់។

អង្គការនេះបានបន្ថែមទៀតថា "អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនគណបក្សប្រឆាំងត្រូវបានតម្រង់គោលដៅវាយប្រហារដោយអង្គនីតិប្រតិបត្តិ និងគណបក្សកាន់អំណាចតាមរយៈប្រព័ន្ធយុត្តិធម៌ដោយសារតែជំនឿនយោបាយសកម្មភាពនយោបាយរបស់ពួកគាត់មិនថាដោយសន្តិវិធីក្តី និងដោយសារឋានៈរបស់ពួកគាត់ជាអ្នកការពារសិទ្ធិមនុស្ស"។

របាយការណ៍ដដែលអះអាងថា សំណុំរឿងប្រឆាំងមន្ត្រីអាដហុកទាំងប្រាំដែលបួនរូបមកពីអង្គការសិទ្ធិមនុស្សអាដហុក និងមន្ត្រី គ.ជ.ប មួយរូបទៀតដែលបានជាប់ពន្ធនាគាររយៈពេលជាងមួយឆ្នាំដោយសារតែពួកគាត់ជាប់ពាក់ព័ន្ធការប៉ុនប៉ងសូកប៉ាន់ស្រីកំណាន់របស់លោក កឹម សុខា ប្រធានគណបក្សប្រឆាំងដើម្បីឱ្យនិយាយកុហកចំពោះស្នេហាលួចលាក់នេះ "ជារឿងនយោបាយយ៉ាងច្បាស់ក្រឡែត"។

របាយការណ៍នេះបានបន្តថា "ពួកគាត់ទាំងប្រាំត្រូវបានគេរើសអើងដោយសារតែឋានៈរបស់ពួកគាត់ជាអ្នកការពារសិទ្ធិមនុស្ស"។

របាយការណ៍នេះបន្ថែមថា "មានភស្តុតាងអាចជឿទុកចិត្តបានដែលគាំទ្រសេចក្តីសន្និដ្ឋានថាពួកគាត់ត្រូវបានចាប់ខ្លួនដើម្បីរារាំងសមាគមអាដហុក និងបុគ្គលិករបស់សមាគមនេះកុំឱ្យបំពេញការងាររបស់ខ្លួនជាអ្នកការពារសិទ្ធិមនុស្ស និងកុំឱ្យប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួន"។

របាយការណ៍នេះក៏អះអាងដែរថា គ្មានមូលដ្ឋានសម្រាប់ដាក់ពន្ធនាគារមន្ត្រីគណបក្សប្រឆាំង?និងសកម្មជនឱ្យជាប់ពន្ធនាគារចន្លោះពី ៧ឆ្នាំ ដល់២០ឆ្នាំ សម្រាប់ការពាក់ព័ន្ធរបស់ពួកគេនៅក្នុងបាតុកម្មមួយនៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញកាលពីខែ កក្កដា ឆ្នាំ២០១៤ ដែលបានផ្ទុះអំពើហិង្សា នៅពេលក្រុមអ្នកគាំទ្រគណបក្សសង្គ្រោះជាតិបានប៉ះទង្គិចគ្នាជាមួយក្រុមសន្តិសុខខណ្ឌឡើយ។

របាយការណ៍នេះបញ្ជាក់ទៀតថា "គ្មាន

**តទៅទំព័រទី១៩**



# AMNESTY INTERNATIONAL CRITICIZES COUNTRY'S 'CORRUPT' COURT SYSTEM

**by George Wright and Chhorn Phearun | May 30, 2017**

Amnesty International today accused the ruling CPP of using its grip on the judiciary to systematically harass and intimidate civil society and urged the government to drop cases against opposition activists and human rights defenders.

In response, a government spokesman branded the global rights group the "enemy of the government," and maintained that jailed members of civil society were imprisoned for breaking the law.

Released this morning, Amnesty's "Courts of Injustice" report criticizes the government over a wide range of cases, including legal assault on prominent activist TepVanny, the current and former rights workers dubbed the Adhoc 5, and opposition CNRP officials convicted of leading an "insurrection" in 2014.

"Since the last general election in July 2013, the Cambodian criminal justice system seems to have been systematically targeting human rights defenders [HRDs] and political opposition activists," the report states.

Amnesty estimates there are at least 27 political prisoners in Cambodia, while local rights group Licadho puts the current number at 25.

"HRDs and political opposition activists are targeted by the executive and ruling party through the criminal justice system on the basis of their political beliefs, activities, however peaceful, and/or due to their status as HRDs," it adds.

The case against the Adhoc 5-four officers from the rights group and an election official who have been jailed for more than a year for their alleged involvement in attempting to bribe a mistress of opposition leader KemSokha to lie about an affair-is "clearly politically motivated," the report says.

"The Five were discriminated against on the basis of their status as HRDs," the report states.

"There is a reliable body of information supporting the conclusion that they were arrested to deter ADHOC and its staff from carrying out their functions as HRDs and from exercising their rights and freedoms," it adds

The report also contends there is no basis for imprisoning opposition officials and activists for between seven and 20 years for their role in a demonstration at Phnom Penh's Freedom Park in July 2014 that turned violent when CNRP supporters clashed with district security guards.

"There is no evidence that the opposition planned violence ahead of the 15 July 2014 event; to the contrary, there is substantial evidence that CNRP parliamentarians in attendance

**Continued to Page 16**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# អ្នកឃ្លាំមើលការបោះឆ្នោតៈការសង្កេតការណ៍ផ្អែកលើគំរូមានប្រសិទ្ធភាពបំផុត

**ដោយ** **hannahhawkins** | **ថ្ងៃអង្គារ ទី៣០ ខែឧសភា ឆ្នាំ២០១៧**

អង្គការតម្លាភាពកម្ពុជាបានសន្យាធ្វើការវាយតម្លៃឱ្យបានឆាប់រហ័សពីភាពមិនប្រក្រតីក្នុងការបោះឆ្នោត ឃុំ សង្កាត់នៅថ្ងៃអាទិត្យដោយការបញ្ជូនអ្នកសង្កេតការណ៍១.១០០នាក់ទូទាំងប្រទេសកម្ពុជា តាមទូក និងឧទ្ធម្ភាគចក្រក្នុងករណីចាំបាច់។

នៅសន្និសីទកាសែតមួយក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថា អង្គការ USAID បានបរិច្ចាគប្រាក់ជិត ២០០.០០០ដុល្លារដើម្បីជួយដល់ប្រតិបត្តិការក្នុងថ្ងៃបោះឆ្នោតដែលក្នុងនោះ ការិយាល័យបោះឆ្នោតគំរូ៤១០កន្លែងក្នុងចំណោមការិយាល័យបោះឆ្នោត២២.១៤៨កន្លែងនឹងត្រូវសង្កេតការណ៍។

លោក ព្រាប កុល ថ្លែងថា គម្រោងគឺត្រូវ ធ្វើរបាយការណ៍ឱ្យបានឆាប់ជាងអង្គការដទៃទៀត ដោយធ្វើការវាយតម្លៃឱ្យបានទូលំទូលាយ។

លោកបានលើកឡើងថា ក្រុមអ្នកសង្កេតការណ៍នឹងត្រូវដាក់ពង្រាយទៅកាន់ "តំបន់កោះ តំបន់ដាច់ស្រយាល ពួកគេប្រហែលជាចាំបាច់ត្រូវធ្វើដំណើរតាមឧទ្ធម្ភាគចក្រ...ពួកគេប្រហែលជាជិះទូកទៅកាន់កោះជាដើម"។

លោក ព្រាប កុល បានមានប្រសាសន៍ថា អ្នកសង្កេតការណ៍ទាំង១.១០០នាក់ត្រូវឆ្លងកាត់ការសម្ភាស?និងការពិនិត្យមើលប្រវត្តិយ៉ាងល្អិតល្អន់ដើម្បីធានាថា ពួកគេមិនជាប់ពាក់ព័ន្ធគណបក្សនយោបាយណាមួយ។ អង្គការមិនមែនរដ្ឋាភិបាលប្រឆាំងអំពើពុករលួយក៏បានឃ្លាំមើលការបោះឆ្នោតក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៣ផងដែរ។

លោក គឹម ឈន អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់នៅគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) ដែលបានចុះឈ្មោះអ្នកសង្កេតការណ៍ប្រហែល១៥.០០០នាក់??បានមានប្រសាសន៍ថា ខុមហ្វ្រែលនឹងរៀបរាប់សង្ខេប ប្រាប់សាធារណជនពីលទ្ធផលមួយចំនួនរបស់ខ្លួននៅថ្ងៃអាទិត្យ




លោក ព្រាប កុល នាយកប្រតិបត្តិអង្គការតម្លាភាពកម្ពុជាថ្លែងនៅសន្និសីទសាព័ត៌មានមួយក្នុង រាជធានីភ្នំពេញ កាលពីម្សិលមិញ។ រូបថតៈ ស៊ីវ ចាន់ណា. ឌឹ ខេមបូឌា ដេលី

ថ្ងៃច័ន្ទ និងថ្ងៃអង្គារ ប៉ុន្តែរបាយការណ៍ចុងក្រោយរបស់ខ្លួននឹងមិនទាន់មានទេនៅរយៈពេលពីរខែទៀតក្រោយការបោះឆ្នោត។

លោក គឹម ឈន បានមានប្រសាសន៍ថា វាជាការសំខាន់ណាស់ក្នុងការដាក់មនុស្សនៅគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ ឬយ៉ាងហោចណាស់ក៏មានម្នាក់ដែររវាងការិយាល័យបោះឆ្នោតពីរ។

លោកបានថ្លែងថា "ប្រសិនបើយើងគ្មានភ័ស្តុតាង បើទោះជាយើងមិនមានរូបភាពពិត រូបថតពិតនៅការិយាល័យបោះឆ្នោតដែលមានបញ្ហា...ក៏យើងមិនអាចបង្ហាញថា វាបានកើតឡើងដែរ។ ខុមហ្វ្រែលព្យាយាមបង្ហាញភ័ស្តុតាងទាំងអស់"៕ **សារុន**

# ELECTION MONITOR: SAMPLE-BASED OBSERVATION MOST EFFECTIVE

**by Hannah Hawkins | May 30, 2017**

Transparency International has pledged a rapid assessment of potential irregularities in Sunday's commune elections by sending 1,100 observers across Cambodia -including, if needed, by boat and helicopter.

-Commune Election 2017-

At a news conference in Phnom Penh on Monday, PreapKol, executive director of Transparency International Cambodia, said USAID had donated nearly $200,000 to fund the Election Day operations, in which a sample of 410 polling stations out of 22,148 would be observed.

The plan was to produce a report more quickly than other organizations carrying out comprehensive assessments, Mr. Kol said.

The observers would be deployed to "islands, remote areas-they might need to fly by helicopter…they might take the boat to the islands," he said.

Mr. Kol said the 1,100 observers had been subject to extensive interviews and background checks to ensure they were not aligned with any political party. The anti-corruption NGO also monitored Cambodia's elections in 2013.

Kim Chhorn, senior program coordinator for the Committee for Free and Fair Elections (Comfrel), which has registered about 15,000 observers, said Comfrel would brief the public on some of their findings on Sunday, Monday and Tuesday. Its final report, however, would not be available for another two months after the vote, he said.

Mr. Chhorn said it was crucial to have someone at all polling stations, or at least a person shared between two polling stations.

"If we have no proof-if we do not have the real picture, the real photo, at the polling station that had the problem…we cannot show that it happened," he said. "Comfrel tries to show all the evidence."

hawkins@cambodiadaily.com

Continued from page 15

# AMNESTY INTERNATIONAL CRITICIZES...

repeatedly told their supporters to conduct themselves peacefully and videos available online indicate that the violence that did take place was in fact initiated by security forces," the report states.

The convictions were not backed up in court, the rights group argues, citing the fact that none of the 38 security guards called as witnesses were able to identify any of the defendants as having engaged in violence.

The court's treatment of female-activists from Phnom Penh's eviction-embattled BoengKak neighborhood is also featured in the report, which focuses on the area's most prominent protester, TepVanny, who was jailed once again last year in what has widely been derided as a politically motivated effort to muzzle the country's best known dissident.

"Members of the community have faced just about every trick in Cambodia's harassment playbook," the report states.

"The cases against Vanny are important for the current discussion as they highlight the lengths to which the authorities will go to use, bend and break the rules of criminal procedure to imprison activists and underscore the unwillingness or inability of the courts' to uphold the internationally protected fair trial rights of HRDs," it adds.

The report ends with nine recommendations to the government, including a call for greater respect for the independence of the judiciary; a plea to stop using the courts to target its critics; and an argument for the immediate termination of all cases against human rights defenders and peaceful political opposition activists.

Contacted by telephone, CPP spokesman SokEysan slammed the rights group and claimed it was biased against the government.

"It is nothing strange, it [Amnesty International] is the enemy of the government," Mr. Eysan said. "If you don't commit any aggravated offenses, there would not be any charges. The court is not biased if you don't violate the law."

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យចេញផ្សាយពី ឌី ខេមបូឌា ដេលី

# ពលរដ្ឋខ្មែរប្រាំពីរនាក់បន្ថែមទៀតត្រូវបាននិរទេសចេញពីសហរដ្ឋអាមេរិកមកកាន់កម្ពុជាវិញ

**ដោយ** Matt Surrusco | **ថ្ងៃព្រហស្បតិ៍ ទី១៨ ខែឧសភា ឆ្នាំ២០១៧**

ពលរដ្ឋខ្មែរប្រាំពីរនាក់ទៀតដែលត្រូវបាននិរទេសចេញពីសហរដ្ឋអាមេរិក បានមកដល់រាជធានីភ្នំពេញហើយកាលពីម្សិលមិញ ថ្វីបើរដ្ឋាភិបាលបានធ្វើសំណើមួយទៀតកាលពីដើមខែនេះ សុំឱ្យផ្អាកការនិរទេសសិន រហូតដល់ប្រទេសទាំងពីរចរចាគ្នាឡើងវិញលើកិច្ចព្រមព្រៀងនិរទេសរបស់ខ្លួនក្តី។

លោក ចេយ៏ រ៉ាមែន (Jay Raman) អ្នកនាំពាក្យស្ថានទូតអាមេរិកបានបញ្ជាក់តាមរយៈសារអេឡិចត្រូនិកថា ពលរដ្ឋខ្មែរទាំងប្រាំពីរនាក់ខាងលើនេះពិតជាត្រូវបាននិរទេសដោយក្រសួងសន្តិសុខជាតិរបស់អាមេរិកមែន។

សូមបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០០២មក ពលរដ្ឋខ្មែរចំនួន៥៦៦នាក់ត្រូវបាននិរទេសចេញពីសហរដ្ឋអាមេរិកក្រោមកិច្ចព្រមព្រៀងទ្វេភាគីនេះ ដែលរួមជាមួយច្បាប់អន្តោប្រវេសន៍របស់សហរដ្ឋអាមេរិកអនុញ្ញាតឱ្យនិរទេសពលរដ្ឋខ្មែរដែលជាអ្នករស់នៅស្របច្បាប់ក្នុងទឹកដីសហរដ្ឋអាមេរិក ក្រោយពីពួកគេអនុវត្តទោសជាប់ពន្ធនាគារនៅទីនោះរួច ។ មួយចំនួនធំក្នុងចំណោមពួកគេបានធ្វើអន្តោប្រវេសន៍ទៅរស់នៅសហរដ្ឋអាមេរិកតាំងពីក្មេងក្នុងនាមជាជនភៀសខ្លួនហើយពួកគេមិនដែលរស់នៅក្នុងប្រទេសកម្ពុជានោះទេ។

មន្ត្រីនៅកម្ពុជាបាននិយាយម្តងហើយម្តងទៀតថា ខ្លួនចង់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ដោយលើកឡើងពីការលំបាកដែលមានទៅលើអ្នកទាំងនេះ និងក្រុមគ្រួសាររបស់អ្នកដែលត្រូវបាននិរទេស។

កាលពីដើមខែនេះ លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសមានប្រសាសន៍ថា សហរដ្ឋអាមេរិកបានប្រាប់ឱ្យកម្ពុជាបន្តទទួលយកពលរដ្ឋខ្មែរដែលត្រូវបាននិរទេសថ្វីបើរដ្ឋាភិបាលអង្វរករយ៉ាងណាក្តី។

លោកថ្លែងថា "យើងបានធ្វើសំណើសុំឱ្យផ្អាកការនិរទេសសិន ដើម្បីឱ្យយើងអាចជជែកគ្នាបន្ថែមទៀត ប៉ុន្តែសហរដ្ឋអាមេរិកមិនបានឆ្លើយតបទេ ហើយចង់ឱ្យយើងបន្ត។ យើងនឹងបន្តទទួលយកនិរទេសជនទាំងនេះ"។

កាលពីម្សិលមិញ លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានបង្វែរសំណួរអំពីការចរចារវាងកម្ពុជានិងសហរដ្ឋអាមេរិកទៅអ្នកនាំពាក្យក្រសួងការបរទេស ដែលមិនអាចទាក់ទងសុំការបំភ្លឺបាន។

ប៉ុន្តែលោកបានគូសបញ្ជាក់ជាថ្មីម្តងទៀតថា រដ្ឋាភិបាលមានបំណងចង់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ" ពីព្រោះនៅពេលអ្នកទាំងនោះមកកម្ពុជា ពួកគាត់យំ ព្រោះពួកគាត់ត្រូវគេបង្ខំឱ្យចាកចេញពីគ្រួសាររបស់ខ្លួន" ៕ **សុខុម**

# SEVEN MORE CAMBODIANS DEPORTED FROM US ARRIVE IN PHNOM PENH

**by Matt Surrusco | May 18, 2017**

Seven more Cambodians deported from the U.S. arrived in Phnom Penh on Wednesday, despite the government making another request earlier this month to put deportations on hold until the two countries renegotiate their repatriation agreement.

The seven Cambodian citizens were repatriated by the U.S. Department of Homeland Security, U.S. Embassy spokesman Jay Raman said in an email.

Since 2002, 566 Cambodians have been deported from the U.S. under the bilateral agreement that, paired with U.S. immigration law, allows for the deportation of Cambodians who are legal residents of the U.S. and have served felony prison sentences there. Many immigrated to the U.S. as child refugees and have never lived in Cambodia.

Officials in Cambodia have repeatedly said they want to amend the agreement, citing hardships placed on the individuals and families of those who are deported.

Earlier this month, Foreign MinisterPrakSokhonn said the U.S. had told Cambodia to continue accepting deported Cambodians, despite the government's pleas.

"We made the request to halt deportations so that we can discuss more, but the U.S. didn't respond and wants us to continue," Mr. Sokhonn said. "We will continue to accept the deportees."

On Wednesday, Interior Ministry spokesman KhieuSopheak referred questions about negotiations between Cambodia and the U.S. to the Foreign Affairs Ministry spokesman, who could not be reached.

But he reiterated the government's wish that the agreement be reviewed again, "because when those people come to Cambodia they cry because they've been forced to leave their families."

តមកពីទំព័រទី ១៤

## មេឃុំប្តឹងកាសែតដែលសួរសំណួរអ្នក...

តែ "បង្ហាញថាករណីវាអញ្ចឹង"។

លោក ឆាំ ប៊ុនថេត អ្នកវិភាគនយោបាយ បានមានប្រសាសន៍ថា ទំនងជាមានមូលដ្ឋានតិចតួចប៉ុណ្ណោះសម្រាប់ពាក្យបណ្តឹងនេះ។

លោកបានថ្លែងថា "តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ គឺរាយការណ៍ព័ត៌មានមែនអត់?។ ប្រជាពលរដ្ឋត្រូវដឹងការពិត...នៅក្នុងឃុំនោះ នោះហើយជាតួនាទីរបស់អ្នកយកព័ត៌មាន...រាយការណ៍ពីព័ត៌មាននោះប្រាប់ប្រជាពលរដ្ឋនៅក្នុងស្រុកនោះឬនៅទូទាំងប្រទេស"។

លោក ឆាំ ប៊ុនថេត បានមានប្រសាសន៍ថា ការសម្រេចរបស់លោក ខៀវ កាញារីទ្ធ បង្ហោះព័ត៌មានលម្អិតអំពីលិខិតឆ្លងដែនរបស់អ្នកយកព័ត៌មានបរទេសរូបនេះទំនងជាការប្រឹងប្រែងដើម្បីធ្វើឱ្យអ្នកយកព័ត៌មានដទៃទៀតខ្លាចរអានៅមុនការបោះឆ្នោតឃុំសង្កាត់។

លោកបានថ្លែងថា "ខ្ញុំគិតថា នេះជារូបភាពនៃការបំភិតបំភ័យ ការព្រមាន និងការគំរាមកំហែង។ វាបានកើតឡើងយូរមកហើយចេញពីគាត់ និងអ្នកផ្សេងទៀតដូច្នេះខ្ញុំមិនយល់ថាវាគួរឱ្យភ្ញាក់ផ្អើលទេ"។

គ្រាន់តែពីរសប្តាហ៍មុនតែប៉ុណ្ណោះលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ទៅកាន់អ្នកយកព័ត៌មានពីរនាក់ រួមមានម្នាក់មកពីកាសែត ខេមបូឌា ដេលី អំឡុងសន្និសីទសារព័ត៌មាននៅវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាននៅរាជធានីភ្នំពេញដោយលើកឡើងថា អ្នកយកព័ត៌មានដែលមិនបានរាយការណ៍ត្រឹមត្រូវអំពីរដ្ឋាភិបាលនឹងត្រូវចាត់ទុកថា "ខ្ញុំបម្រើជនបរទេស"។

ពាក្យបណ្តឹងនេះកើតមានតែប៉ុន្មានថ្ងៃប៉ុណ្ណោះបន្ទាប់ពីរដ្ឋមន្ត្រីក្រសួងព័ត៌មានបានព្រមានប្រព័ន្ធផ្សព្វផ្សាយថា ត្រូវគោរពគោលការណ៍សម្រាប់ការបោះឆ្នោតនៅកម្ពុជារបស់គ.ជ.បបើមិនដូច្នោះទេប្រឈមនឹងការបិទចោល។

ទោះជាយ៉ាងណា គោលការណ៍នេះចែងយ៉ាងច្បាស់អំពីភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយ គឺត្រូវ "ស្វែងរកព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានអំពីមតិយោបល់ និងគំនិតខុសគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់អំឡុងដំណើរការបោះឆ្នោត"។

គណបក្ស សម រង្ស៊ី ដែលមានលោក រ៉ាម យួត ជាមេឃុំ បានច្របាច់បញ្ចូលគ្នាជាមួយគណបក្សសិទ្ធិមនុស្សបន្ទាប់ពីការបោះឆ្នោតឃុំសង្កាត់ក្នុងឆ្នាំ២០១២ដើម្បីបង្កើតជាគណបក្សសង្គ្រោះជាតិបច្ចុប្បន្ននេះជាគណបក្សប្រឆាំងដ៏សំខាន់នៅក្នុងប្រទេស។ នៅពេលគណបក្សថ្មីនេះជ្រើសរើសបេក្ខជនឃុំសង្កាត់សម្រាប់ការបោះឆ្នោតនៅឆ្នាំនេះគឺនៅថ្ងៃទី៤ខែមិថុនាលោករ៉ាមយួតត្រូវបានដកឈ្មោះចេញពីបញ្ជីឈ្មោះបេក្ខជនហើយបានលើកឡើងនៅពេលនោះថា លោកភ្ញាក់ផ្អើលចំពោះសេចក្តីសម្រេចបែបនេះ៕

**សារុន (រាយការណ៍បន្ថែមដោយ គឹម ចាន់)**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ល្បងកម្លាំងចាក់ឫសរបស់ CPP ទល់នឹងសម្ទុះគាំទ្ររបស់ CNRP

**ដោយ** Ben Paviour | **ថ្ងៃសុក្រ ទី១៩ ខែឧសភា ឆ្នាំ២០១៧**

ខណៈរដូវកាលឃោសនាបោះឆ្នោតដំបូងឈានចូលមកដល់ចាប់តាំងពីគណបក្សសង្គ្រោះជាតិបិះធ្វើឱ្យគណបក្សកាន់អំណាចទទួលបរាជ័យនៅក្នុងឆ្នាំ២០១៣មក គណបក្សប្រឆាំងជឿជាក់ថា ខ្លួននៅតែមានសម្ទុះគាំទ្រ។

មុនពេលថ្លែងទៅកាន់អ្នកគាំទ្រក្នុងពិធីជួបជុំមួយនៅខេត្តឧត្តរមានជ័យ ដែលអ្នករៀបចំរំពឹងថានឹងមានអ្នកចូលរួមពីរបីរយនាក់ លោកស្រី មូរ សុខហួរ អនុប្រធានគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍កាលពីម្សិលមិញថា "ខ្ញុំសម្លឹងទៅខាងមុខខ្ញុំឃើញមានស្ត្រីរាប់ពាន់នាក់។ យើងកំពុងចូលទៅដល់មូលដ្ឋានដែលធ្លាប់តែជាតំបន់របស់គណបក្សប្រជាជនកម្ពុជា"។

លោកស្រី មូរ សុខហួរ មានសុទិដ្ឋិនិយមដោយសារហេតុផលមួយចំនួន។

ទោះបីជាដំបូងឡើយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាត់ទុកការបិះបរាជ័យរបស់គណបក្សលោកនៅក្នុងឆ្នាំ២០១៣ថាជាការដាស់ស្មារតីឱ្យធ្វើកំណែទម្រង់រដ្ឋក្តី ក៏មានសញ្ញាតិចតួចណាស់ដែលបង្ហាញថា គណបក្សប្រជាជនកម្ពុជាបានកែលម្អខ្លួនដើម្បីដោះស្រាយបញ្ហាកំហឹងដែលមានសម្ទុះកើនឡើងខ្លាំងនៅមុនរដូវកាលឃោសនាផ្លូវការនៃការបោះឆ្នោតឃុំ-សង្កាត់ ដែលនឹងចាប់ផ្តើមពីថ្ងៃសៅរ៍នេះទៅ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដែលមានសមាសភាពពីរគណបក្សចូលរួមបានធ្វើបញ្ជីបោះឆ្នោតថ្មីដែលបណ្តាអ្នកសង្កេតការណ៍បោះឆ្នោតនៅពេលនេះចាត់ថាគួរជឿទុកចិត្តបាន ហើយបានចាប់ផ្តើមធ្វើកំណែទម្រង់ផ្សេងៗទៀតដើម្បីបញ្ចៀសការលួចបន្លំដែលបណ្តាអ្នករិះគន់និយាយថា ធ្លាប់ជួយគណបក្សកាន់អំណាចច្រើនឱ្យមានប្រៀបលើសគេ។

ដោយរងបណ្តឹងតុលាការជាបន្តបន្ទាប់ ហើយប្រឈមនឹងច្បាប់ដែលខ្លួនចាត់ទុកថាសុទ្ធតែជារឿងនយោបាយបក្ខពួកនិយម និងគោលនយោបាយចម្រូងចម្រាសគណបក្សប្រឆាំងបានជម្នះឧបសគ្គដែលប្រហែលជាធំបំផុតរបស់ខ្លួន ដោយនៅតែឈរជើងរឹងមាំ និងដាក់បញ្ចូលបេក្ខជននៅគ្រប់ឃុំ សង្កាត់ ដោយជោគជ័យសម្រាប់ការបោះឆ្នោតនៅថ្ងៃទី៤ខែមិថុនា។



ប៉ុន្តែក៏មានហេតុផលមួយចំនួនដែរដែលគេមានមន្ទិលថា គណបក្សសង្គ្រោះជាតិនឹងមិនអាចសម្រេចគោលដៅរបស់ខ្លួនក្នុងការដណ្តើមឱ្យបានយ៉ាងតិច៤០ភាគរយនៃឃុំ-សង្កាត់ ទាំង១.៦៤៦ អំឡុងការបោះឆ្នោតក្នុងពេលដ៏ខ្លីខាងមុខ ពីចំនួន២ភាគរយដែលបានបូកបញ្ចូលគ្នារវាងគណបក្សសមរង្ស៊ីនិងគណបក្សសិទ្ធិមនុស្សអំឡុងការបោះឆ្នោតលើកចុងក្រោយ។

លោក អ៊ា សុផល សាស្ត្រាចារ្យផ្នែកការទូត និងកិច្ចការពិភពលោកនៅមហាវិទ្យាល័យ Occidental College ក្នុងទីក្រុងឡូសអែនជើឡេស និងជាអ្នកសរសេររួមគ្នានូវរបាយការណ៍សិក្សាមួយកាលពីឆ្នាំមុនស្តីពីអភិបាលកិច្ចមូលដ្ឋានក្នុងប្រទេសកម្ពុជា បានសរសេរថា "អ្វីៗត្រូវបានរៀបចំទុកជាមុនធ្វើយ៉ាងណាឱ្យគណបក្សប្រឆាំងពិបាកខ្លាំងក្នុងការឈ្នះអាសនៈក្រុមប្រឹក្សាឱ្យឃុំ-សង្កាត់" ហើយកាន់តែពិបាកជាងនេះទៅទៀតក្នុងការឈ្នះអាសនៈមេឃុំចៅសង្កាត់។

**តទៅទំព័រទី ២៤**

**Continued from page 01**

# COMMUNE VOTE PITS CPP…

signs that the CPP has reinvented itself to address that ground swell of anger ahead of the upcoming commune elections' official campaigning period, which begins on Saturday. A bipartisan National Election Committee ( NEC) has rebuilt voter lists that election observers now deem credible, and instituted other changes designed to avert fraud that critics said used to play heavily in the ruling party's favor.

Dogged by court cases and legislation it sees as politically motivated, factionalism, and fidgety policy, the opposition party has cleared perhaps the highest hurdle by simply staying intact and successfully fielding candidates in all communes for the June 4 vote.

But there are also several reasons to doubt that the CNRP will be able to reach its goal of capturing control of at least 40 percent of the 1,646 communes in play during the upcoming vote, up from the combined two percent won by the Sam Rainsy Party (SRP) and Human Rights Party (HRP) during the last vote.

"The deck is just stacked in such a way as to make it very hard for the opposition to win [commune] council seats and even harder to win chiefs," wrote Sophal Ear, an associate professor of diplomacy and world affairs at Occidental College in Los Angeles, and co-author of a study last year on local governance in Cambodia. "Even if they get control of the council (not an easy feat), they would have no money to do anything."

Up against a formidable CPP party machine whose resources outstrip those of local governments, an election formula that favors incumbents, and voters' traditional reluctance to risk old patronage relationships, the opposition party faces a long road ahead to both win communes and govern them effectively.

The 2012 commune elections give a hint of the hurdles faced by the opposition.

The SRP and HRP, which merged later that year to form the CNRP, garnered a combined 30.6 percent of the votes, compared to about 60 percent for the CPP.

But because the opposition votes were scattered across many communes, each of which requires a plurality of votes to control the commune chief spot, the CPP was able to convert its votes to control about 72 percent of the councilor seats and a whopping 97 percent of the commune chiefs.

"The overwhelming gains of the CPP are partly explained by technical rather than political reasons," election monitor Comfrel wrote in its post-election report, including a formula for proportional representation for councilors "that is widely considered to lead to less proportional election results" compared to other systems.

"The structure of commune council election results in situations in which you, as the opposition party, are lucky to get one seat, maybe two seats, but guess what, you still lost the council itself," Mr. Ear wrote. "The advantage of incumbency is huge."

For many local leaders, their incumbency stretches back as far as 1979 and even into the Khmer Rouge era, according to a 2008 study by the Cambodia Development Resource Institute (CDRI), which found that voters on the village level across three unnamed communes told researchers they preferred older, entrenched leaders to newcomers with less social capital or fewer connections to patrons.

"Villagers in general fear change and it takes quite a time and effort for new leaders to prove themselves and be accepted," the study says.

The researchers found that in the three communes they visited, the ruling party was deeply intertwined with the state, with its patrons propping up pagodas, its working groups overseeing new roads, and commune councilors mingling their administrative duties with party campaigning, infrastructure projects and handouts. Nearly all districts and provinces have a wealthy, powerful CPP patron assigned by the party to pay regular visits, fund and oversee projects and ensure votes for the party.

"The concept of reciprocity is ill used to keep villagers depended so that they vote for those who provide assistance," notes the CDRI study.

In cases where the commune leaders could tap into a generous national patron, as was the case in one of the three communes visited by CDRI, villagers saw little need to threaten the status quo.

But the authors also said that local leaders who stood by party higher-ups or powerful businessmen in land grabs or corrupt dealings were susceptible to lose their perch-a sentiment social and political scientist Meas Nee said he **Continued to Page 20**

តមកទំព័រទី ១៩

## អង្គការលើកលែងទោសអន្តរជាតិ...

ភស្តុតាងបង្ហាញថា គណបក្សប្រឆាំងជាអ្នករៀបចំគម្រោងអំពើហិង្សានៅមុនព្រឹត្តិការណ៍ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ នោះទេ។ ផ្ទុយទៅវិញ មានភស្តុតាងជាច្រើនបង្ហាញថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិដែលចូលរួម បានប្រាប់អ្នកគាំទ្ររបស់ខ្លួនម្តងហើយម្តងទៀតឱ្យប្រកាន់យកឥរិយាបថអហិង្សា ហើយវីដេអូដែលមានតាមបណ្តាញអ៊ីនធឺណិតបង្ហាញថា តាមពិតអំពើហិង្សាដែលបានកើតឡើងបានផ្តើមចេញពីវាបង្ហាញពីភាពឃោឃៅរបស់អាជ្ញាធរនក្នុងការប្រើប្រាស់?រំលោភបំពាន?ឬបកស្រាយក្រមព្រហ្មទណ្ឌតាមអំពើចិត្ត?ដើម្បីឃុំខ្លួនសកម្មជន ហើយវាបង្ហាញពីភាពគ្មានឆន្ទៈ?ឬអសមត្ថភាពរបស់តុលាការក្នុងការការពារសិទ្ធិទទួលបានសវនាការយុត្តិធម៌?ដែលទទួលស្គាល់ជាអន្តរជាតិ សម្រាប់សកម្មជនការពារសិទ្ធិមនុស្ស"។

របាយការណ៍នេះបញ្ចប់ដោយផ្តល់អនុសាសន៍ចំនួនប្រាំបួនដល់រដ្ឋាភិបាលរួមមានការគោរព



លោក មាជ សុវណ្ណារ៉ា ប្រធាននាយកដ្ឋានព័ត៌មាននៃគណបក្សសង្គ្រោះជាតិ ធ្វើកាយវិការទៅកាន់អ្នកយកព័ត៌មានខណៈដែលគាត់ត្រូវបានបណ្តើរចេញពីតុលាការបន្ទាប់ពីបើកសវនការនៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញកាលពីខែ សីហា ឆ្នាំមុនក្នុងករណីចោទប្រកាន់ពីបទកុបកម្ម និងសកម្មជន មន្ត្រីគណបក្សប្រឆាំង១០រូបផ្សេងទៀត។ រូបថត: ស៊ីវ ចាន់ណា,ឌឺ ខេមបូឌា ដេលី

កងកម្លាំងសន្តិសុខ"។

អង្គការសិទ្ធិមនុស្សមួយនេះបានអះអាងថា ការចោទប្រកាន់ទាំងនេះមិនទទួលបានការគាំទ្រទេនៅក្នុងតុលាការ ដោយលើកឡើងអង្គហេតុថា ក្នុងចំណោមសន្តិសុខទាំង៣៨នាក់ដែលត្រូវបានកោះហៅធ្វើជាសាក្សីគ្មាននរណាម្នាក់អាចកំណត់អត្តសញ្ញាណចុងចោទណាម្នាក់ក្នុងចំណោមនេះថា បានចូលរួមក្នុងអំពើហិង្សាឡើយ ។

ការប្រព្រឹត្តរបស់តុលាការទៅលើស្ត្រីសកម្មជនមកពីសហគមន៍បឹងកក់ ដែលរងការបណ្តេញចេញនៅក្នុងរាជធានីភ្នំពេញ ក៏ត្រូវបានបង្ហាញក្នុងរបាយការណ៍នេះដែលផ្តោតលើអ្នកតវ៉ាដ៏សំខាន់បំផុតរបស់ខ្លួនគឺអ្នកស្រី ទេព វន្នី ដែលត្រូវបានជាប់ពន្ធនាគារជាថ្មីម្តងទៀតកាលពីឆ្នាំមុននៅក្នុងអ្វីដែលគេចាត់ទុកជាទូទៅថាជាការព្យាយាមបំបិទមាត់អ្នកប្រឆាំងល្បីល្បាញបំផុតនៅក្នុងប្រទេសរូបនេះ។

របាយការណ៍នេះលើកឡើងថា "ប្រជាពលរដ្ឋក្នុងសហគមន៍នេះបានប្រឈមនឹងកលល្បិចគ្រប់វិធីដែលគេប្រើ ដើម្បីធ្វើបាបពួកគាត់"។

របាយការណ៍នេះបន្ថែមទៀតថា "សំណុំរឿងប្រឆាំងអ្នកស្រី ទេព វន្នី មានសារៈសំខាន់សម្រាប់ការពិភាក្សានៅពេលបច្ចុប្បន្ន ពីព្រោះចំពោះឯករាជភាពនៃប្រព័ន្ធតុលាការ ការអង្វរករសុំឱ្យឈប់ប្រើប្រាស់ប្រព័ន្ធតុលាការតម្រង់គោលដៅវាយប្រហារលើរកអ្នករិះគន់របស់ខ្លួននិងលុបចោលភ្លាមៗនូវសំណុំរឿងទាំងអស់ប្រឆាំងអ្នកការពារសិទ្ធិមនុស្សនិងសកម្មជនគណបក្សប្រឆាំង។

ពេលទាក់ទងតាមទូរស័ព្ទ លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា បានរិះគន់អង្គការសិទ្ធិមនុស្សមួយនេះខ្លាំងៗ ហើយអះអាងថា វាលម្អៀងប្រឆាំងរដ្ឋាភិបាល ។

លោកមានប្រសាសន៍ថា "គ្មានអីចម្លែកទេ វាឱ្យអង្គការលើកលែងទោសអន្តរជាតិ" ជាសត្រូវរបស់រដ្ឋាភិបាល។ បើអ្នកឯងមិនប្រព្រឹត្តបទល្មើសមានស្ថានទម្ងន់ទោសទេ ក៏គ្មានការចោទប្រកាន់ដែរ។ តុលាការមិនលម្អៀងទេ បើអ្នកឯងមិនល្មើសច្បាប់"៕ **សុខុម**

តមកទំព័រទី ០៩

## ការលះបង់គោរមងារជាម្ចាស់ក្សត្រី...

មិនមែនជាខ្សែរាជ្យវង្សនោះទេ។

ទោះបីជាយ៉ាងណាក៏ដោយ ព្រះនាង ម៉ាកូ មិនមែនជាម្ចាស់ក្សត្រីដំបូងនោះទេក្នុងគ្រួសាររាជ្យវង្សដែលបានជ្រើសរើសបោះបង់ចោលដំណែង។ កាលពី១២ឆ្នាំមុនព្រះមាតុលានី (ម្តាយមីង) របស់ព្រះនាងព្រះនាម Sayako Kuroda ដែលពេលនេះមានព្រះជន៤៨វស្សា និងជាបុត្រីតែមួយគត់របស់ព្រះចៅអាធិរាជ្យអាគីហ៊ីតូបានរៀបអភិសេកជាមួយជនសាមញ្ញ ឈ្មោះ Yoshiki Kuroda ហើយត្រូវចាកចេញពីរាជ្យវាំងផងដែរ។

នៅក្នុងប្រទេសជប៉ុន សមាជិកគ្រួសារជាមនុស្សប្រុសត្រូវបានអនុញ្ញាតឱ្យរៀបការជាមួយជនសាមញ្ញ និងនៅតែរក្សាតំណែងរបស់ខ្លួនដដែល។ ផ្ទុយទៅវិញ វាមិនដូចគ្នាឡើយសម្រាប់សមាជិកគ្រួសារជាស្ត្រី។ ជាក់ស្តែងអធិរាជជប៉ុន អាគីហ៊ីតូគឺជាខ្សែរាជវង្សជប៉ុនដំបូងគេបង្អស់ដែលបានរៀបអភិសេកជាមួយជនសាមញ្ញ (ព្រះអគ្គមហេសី Michiko) ប៉ុន្តែនៅតែរក្សាតំណែងជាអធិរាជដដែរ។

**ចំនួនសមាជិកគ្រួសារអធិរាជ្យ**

នាពេលបច្ចុប្បន្ននេះ គ្រួសារអធិរាជ្យជប៉ុនមានសមជិកចំនួន១២អង្គ ប្រសិនបើមានការចាកចេញរបស់ព្រះនាងម៉ាកូមែននោះ ចំនួនសមាជិករាជ្យវង្សដែលមានចំនួនតិចរួចហើយនោះ នឹងកាន់តែរួមតូចថែមទៀតដោយនៅសល់តែចំនួន ១១ អង្គប៉ុណ្ណោះ៕




**ដំណឹងរកបុគ្គលិកចែកផ្សាយ**

ខ្មែរផុសស.រ.អា.ត្រូវការរកបុគ្គលិកសម្រាប់ចែកផ្សាយកាសែតនៅក្នុងតំបន់ មានឡូវែល - លីន រីវែ - ក្រេងស្តុន រ៉ូដអាយឡិន ។ កាសែតចែក២ដង ក្នុង១ខែ ។ បេក្ខជនត្រូវមានប័ណ្ណបើកបរ នឹងធ្លាប់ស្គាល់តំបន់ច្បាស់លាស់ ។ សូមទាក់ទងមកទីស្នាក់ការយើង នៅលេខ **978 - 677 7163** ឬទាក់ទងមក **សូបិន 978-656 8141**

# ចាប់ផ្ដើមដាំដំណាំដោយប្រើដុំចំបើង

**ដោយ សុខាវ័ត្ថ កួយ**

នៅរដូវក្ដៅខាងមុខខ្មែរផុស សូមធ្វើការណែនាំលោកអ្នកនូវការបង្កើតសួនដំណាំពីដុំចំបើងដែលវាមិនមែនជាការងារធ្ងន់, ចំណាយថវិការតិច, ងាយស្រួលក្នុងការដាំ, និងមិនចាំចាប់ត្រូវការទីធ្លាធំ និងមានដីច្រើន និងសម្រាប់ការហូបក្នុងគ្រួសារផងដែរ។ ការដាំដំណាំក្នុងដុំចំបើងគឺជាការប្រើប្រាស់ដុំចំបើងមកចងជាដុំដោយប្រើខ្សែដោយមានផ្ទៃខាងក្រៅមានរាងដូចជាសុំ ហើយលក្ខណ្ឌខាងក្នុងចំបើងនឹងរលួយទៅជាកំប៉ុសសម្រាប់ការដាំដំណាំគ្រាប់ប្រភេទ។

លោក Joel Karsten អ្នកជំនាញការផ្នែកការដាំដំណាំពីដុំចំបើង និងរស់នៅ Roseville ក្រុង Minnesota បានប្រាប់ខ្មែរផុសតាមរយៈសារអេលិចត្រូនិចឱ្យដឹងការដាំដំណាំនៅក្នុងដុំចំបើងមានគុណប្រយោជន៏ច្រើនដោយវាមិនមានរុក្ខជាតិតូចៗឥតប្រយោជន៏ ដូចជាមិនមានស្មៅ, ចំបើងរក្សាសំណើមបានល្អ, មិនលិចទឹក, គឺទឹកហូរបានយ៉ាងស្រួល, មានចន្លោះខ្យល់ជាច្រើនជាពិសេសសម្រាប់ការចាក់ឫស, សារធាតុចិញ្ចឹមនៅក្នុងចំបើងដែលរលួយបង្កើតចេញពីការពុកផុយ, មានទំងន់ស្រាល, នៅផ្ទៃខាងលើ រឺកន្លែងផ្សេងៗទៀត, អាចដាំអ្វីក៏បាន និងអាចរុះរើពីទីតាំងមួយទៅមួយទៀត, មិនតំរូវឱ្យមានដី, មានខ្យល់ចេញចូលប្រសើរជុំវិញដំណាំ, មិនសូវមានជំងឺ, មិនមានធាតុសើមត្រូវបានបាត់បង់, ងាយស្រួលឃើញបញ្ហាជាមួយកំពស់ដែលដាំ និងវាធ្វើឱ្យកម្ដៅកើនឡើង និងជំរុញការរីកលូតលាស់នៃឫសឆាប់រហ័ស, ងាយស្រួលជាង។

លោក Joel បានលើកឡើងថា ដើម្បីរៀបចំការដាំដំណាំក្នុងដុំចំបើងបានដំបូងយើងគួរជ្រើសរើសយកទីកន្លែង រឺទីតាំងណាក៏បានទៅតាមចំណង់ចំណូលចិត្តដោយការដាំដំណាំប្រភេទនេះមិនចាំបាច់ត្រូវការដី និងទីធ្លាធំនោះទេ អាចដាក់



គំរូរបៀបនៃការរៀចបំរងដំចំបើង




លើបេតុងស៊ីម៉ង្សកន្លែងចំណតយានយន្ត, ផ្លូវកៅស៊ូ រឺជិតប្រពភទឹកក៏បានតែគួរជ្រើសយកកន្លែងណាដែលមានពន្លឺថ្ងៃច្រើន។ បន្ទាប់មកត្រូវរកទិញដុំចំបើងដែលមានលក់ស្រាប់ក៏បាន រឺក៏ធ្វើដុំចំបើងដោយខ្លួនឯងដោយប្រើប្រាស់ធុង រួចដាក់ចំបើងចូលយកខ្សែមកចងរិតឱ្យណែនជាការស្រេច រឺអាចយកសំណាញ់ទ្រុងមាន់ដោយចងជាប់ជាមួយបង្គោលឈើរួចរឹតឱ្យតឹងជាមួយនឹងចំបើងដើម្បីឱ្យបានជាដុំកាន់តែណែនកាន់តែល្អ ហើយដុំចំបើងអាចធ្វើប្រវែងពី៣៦ទៅ៤៨ Inch, ទទឹង១៨ ទៅ ២៤ inch និងកំពស់ ១៤ ទៅ ២២ Inch។ លោកបានមានប្រសាសន៏ថា តំបន់ខ្លះពិបាកក្នុងការរកចំបើង ដូច្នេះយើងអាចប្រើប្រាស់ស្លឹកឈើងាប់ និងស្មៅងាប់ដាក់លាយបញ្ចូលគ្នាក្នុងធុងរិតឱ្យទៅជាដុំសម្រាប់ដាំដំណាំក៏បាន។

លោក Joel បានបន្តថា បន្ទាប់ពីរៀចចំដុំចំបើងរួចរាល់ហើយ ត្រូវរៀបដុំចំបើងដាក់ជាជួរ រឺរៀបឱ្យដូចជារង រួចយកឈើរឺដែកមកដុំខាងចុង និងខាងដើមនៃរង ដើម្បីឱ្យរងចំបើងណែនល្អងាយស្រួលក្នុងការដាំ។ ប្រសិនបើដាំរុក្ខជាតិប្រភេទជាវល្លិ៍ត្រូវរៀបចំទ្រើងដោយយកខ្សែលួស រឺខ្សែជ័រចង់ភ្ជាប់ទៅនឹងជ្រុងសងសាងនៃឈើរឺដែរក៏ដោយទុកចន្លោះ8ទៅ20CM ដើម្បីឱ្យដំណាំវាលតោងឡើងងាយស្រួលការលូតលាស់។ លោកបានបន្តថា ដំណាក់កាលបន្ទាប់ គឺការធ្វើឱ្យចំបើងរលួយដោយចាំបាច់ត្រូវស្រោចទឹក និងដាក់ជី។ ដំណើរការបំរែបំរួលនៃដុំចំបើងបន្ទាប់ពីដាក់ជី និងស្រោចទឹកត្រូវចំណាយពេល១០ទៅ១២ថ្ងៃសម្រាប់ការរលួយក្លាយទៅជាកំបុសអាចដាំដំណាំបាន។

ដំបូងត្រូវដាក់ជីនីត្រូសែន (high nitrogen fertilizer) លើដុំចំបើងចំនួន 100CC សម្រាប់ចំបើងមួយដុំនៅថ្ងៃទី១,២, និង ថ្ងៃទី៥ និងប្រើជីចំនួន 50CC នៅថ្ងៃទី៧, ៨ និងទី៩បន្ទាប់មក ទៀតត្រូវដាក់ជី ១០-១០-១០ ចំនួន200CC នៅថ្ងៃទី១០។ យើងក៏អាចប្រើប្រាស់ជីប្រភេទផ្សេងទៀតដើម្បីជាជុំនួយផងដែរ ដូចជាកាកសំណល់សាច់ដែលមានឈាម, កាកសំណល់រោម សត្វ, រឺក៏លាមកសត្វត្រូវដាក់នៅថ្ងៃទី ១, ៣, ៥, ៧-៩។ ជារៀងរាល់ពេលនៅពេលដែលដាក់ជីនៅលើដុំចំបើងរួចត្រូវស្រោចទឹកលើដុំចំបើងទាំងអស់ឱ្យសើមល្មមកុំឱ្យដក់ទឹកជាប់ច្រើនពេកចំនួន២លីត្រសម្រាប់ដុំចំបើងមួយដុំមួយថ្ងៃម្ដងជារៀងរាល់ថ្ងៃរយៈពេល១២ថ្ងៃ គឺចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១២។ ការស្រោចទឹកយើងអាចប្រើប្រាស់ទុយយោ soaker hose ដែលវាមាន លក្ខណៈងាយស្រួល។

ក្នុងរយៈពេល១២ថ្ងៃនេះ ដុំចំបើងនឹងរលួយក្លាយជាកំបុស ហើយនៅថ្ងៃទី១២នេះ គឺយើងអាចចាប់ផ្ដើមដាំដំណាំបាន។ សម្រាប់ការដំណាំដោយប្រើដុំចំបើងនេះ lelak Joel បានឱ្យដឹងថាយើងអាចដាំដំណាំប្រភេទដូចជាពោត, Rhubarb ( ដូចប្រភេទដើមក្ដាត) & (ទំពាំងបារាំង), បន្លែ, ដំណាំដែលមានឫស, ដំណាំប្រភេទវល្លិ រឺឡើងទ្រើង, ផ្កា និងរុក្ខជាដែលមានលក្ខណៈជាគុម្ព (Herbs)។ ប្រសិនបើលោកអ្នកចង់រៀន និងស្វែងយល់ពីការដាំដំណាំពីដុំចំបើងអាចទំនាក់ទំនងលោក Joel Karsten តាមអ៊ីម៉េល joel@strawbalegardens.com រឺវិបសាយ www.strabalegardens.com ៕

Continued from page 18

## COMMUNE VOTE PITS CPP…

had been hearing more and more of lately in his provincial work.

"I think people are ready for change," he said, pointing to widespread internet penetration enabling better informed voters. "Not everybody, but a significant number."

Assuming Mr. Nee is right, history suggests the opposition commune chiefs will have their work cut out for them.

With coffers in the hands of a central government hesitant to provide funding even for CPP communes in spite of nationwide decentralization plans, opposition-led commune chiefs say they have faced extra obstacles to stay in the loop and finance projects.

An unnamed SRP commune chief interviewed by CDRI said she struggled to find money for projects and was "the last person to know any news."

Siek Mekong, an SRP commune chief in Stung Treng province, said district and provincial authorities generally offered 50 million riel, or about $12,325, toward annual infrastructure projects, but had refused his requests in recent years to build a new road, accusing him of squandering state funds.

"They always oppose me, or reject my proposals because they do not want opposition members to be here," he said of the district and provincial councils, who are chosen by commune councilors and therefore swing solidly to the CPP.

Nor does the CNRP have anything to rival the CPP's working group structure, which has centralized wealth and power over the past three decades.

"If you look at the resources, the ruling party's local office headquarters looks better than the commune council headquarters," Mr. Ear wrote. "It's clear where the money is."

The CNRP hopes to change that by providing $500,000 worth of funding to every commune-a plan that Ms. Sochua admits is contingent on the party winning next year's national elections.

"That's why we're tying the 2017 message with 2018," she said. "Otherwise the national budget is in the hands of the ruling party."

The CNRP is hoping that local voters' deep connections with the CPP will actually work against the ruling party-that Cambodians have had decades to get to know the government, and don't like what they see anymore.

"Their only message is fear," Ms. Sochua said. "Our strategy is door to door, village to village."

Mr. Ear said he isn't convinced that the CNRP can translate that effort into a significantly improved performance over 2012.

But Mr. Nee, the social scientist, has a rosier outlook for the opposition, predicting the CNRP to take about 40 percent of the commune chief spots as the CPP sticks to its "old tricks."

He described recently watching villagers exit a CPP gathering with 20,000 riel, or about $5.

"When they came out, they were laughing," he said, recalling the sentiment he heard from locals: "You can never change my mind or my heart."

(Additional reporting by Sek Odom)

# វត្តភ្នំប្រុស ភ្នំស្រី កសាងសមិទ្ធផលច្រើន ទាក់ទាញអ្នកទេសចរទៅកម្សាន្ត



**ខេត្តកំពង់ចាម :** ភ្នំប្រុសភ្នំស្រីស្ថិតក្នុងឃុំក្រឡា និងឃុំអំពិល ស្រុកកំពង់សៀម មានប្រវត្តិរឿងព្រេងនិទានតៗគ្នាថា បុរស និងស្ត្រីបបួលភ្នាល់គ្នាលើកភ្នំ ហើយខាងស្រីជាអ្នកឈ្នះបុរស ។ ភ្នំប្រុសភ្នំស្រីត្រូវព្រះចៅអធិការវត្តប្រឹងប្រែងកសាងសមិទ្ធផលជាច្រើនទាំងនៅលើភ្នំ និងផ្នែកខាងក្រោម ។ រៀងរាល់ថ្ងៃមានអ្នកទេសចរជាតិ និងអន្តរជាតិទៅកម្សាន្តជាហូរហែ ។

លោកតា ធុច ស្រឿង អាយុ៧៨ឆ្នាំ ជាអ្នកថែទាំនៅលើភ្នំស្រី មានប្រសាសន៍ កាលពីរសៀលថ្ងៃទី២៤ ឧសភា២០១៧ថា តាមរឿងនិទានតៗគ្នាថា ប្រពៃណីស្ត្រីចូលស្តីដណ្តឹងបុរសជាច្រើនតំណមកហើយ តែស្ត្រីដែលមានរូបឆោមមិនស្អាតធ្វើឱ្យបុរសចេះតែគេចមិនព្រមដណ្តឹងជាភរិយាទេ ។ ដោយបែបនោះហើយស្ត្រីបានបបួលបុរសលើកដីពូនធ្វើភ្នំប្រុស និងភ្នំស្រីប្រណាំងគ្នា ដោយកំណត់ដាក់លក្ខខណ្ឌថា ប្រសិនបើឃើញផ្កាយព្រឹករះឡើងហើយនោះ ត្រូវឈប់សម្រាក មិនមានអ្នកណាប្រើកម្លាំងពលកម្មលើកបន្តទេ ។

ដោយសារស្ត្រីជាមនុស្សវៃឆ្លាត ម្នាក់ៗខិតខំប្រឹងប្រែងលើកដីញាប់ដៃញាប់ជើងមិនសម្រាកទេ គឺនាំគ្នាលើកដីហុចពីម្នាក់ទៅម្នាក់ទៀត បណ្តាក់គ្នាដូចខ្សែង ។ មិនតែប៉ុណ្ណោះបានប្រើល្បិចចងគោមបង្ហោះឡើង ។ ភាគីខាងបុរសដែលកំពុងតែលើកដីនៅផ្នែកម្ខាងទៀតឃើញគោមនឹកស្មានតែផ្កាយព្រឹករះឡើងក៏នាំគ្នាឈប់លើកដី ។ ចំណែកភាគីស្ត្រីវិញចេះតែនាំគ្នាលើកដីតទៅទៀត រហូតដល់ខ្ពស់ជាងខាងប្រុស ។ ទីនោះគេហៅថា "ភ្នំស្រី" ហើយវាខ្ពស់ជាងភ្នំប្រុស ។

ដោយការភ្នាល់ចាញ់នោះ ប្រពៃណីក៏មានការផ្លាស់ប្តូរ គឺបុរសចូលស្តីដណ្តឹងស្ត្រីវិញម្តង ហើយបន្តរហូតមកដល់សព្វថ្ងៃនេះ ។

លោកតា ធុច ស្រឿង នៅថែរក្សាភ្នំស្រីតាំងពីមិនទាន់មានអភិវឌ្ឍអ្វី គឺសម្បូរទៅដោយព្រៃដុះទ្រុបទ្រុល ។ គាត់នៅជាមួយលោកតាម្នាក់ទៀតឈ្មោះ ជន ហ៊ាន អាយុដំណាលគ្នា ។

ក្រោមការដឹកនាំរបស់ព្រះចៅអធិការវត្ត បានកសាងសមិទ្ធផលបន្តិចម្តងៗ ។ ជាក់ស្តែងកាំជណ្តើរឡើងទៅលើកំពូលភ្នំស្រីចំនួន២១៧កាំ និងកម្ពស់១១៤ម៉ែត្រ ព្រមទាំងខ្លោងទ្វារបានកសាងឡើងជាង១០ឆ្នាំមកហើយ ។ ចំពោះបង្កាន់ដៃព័ទ្ធជុំវិញលើកំពូលភ្នំកសាងជាង២០ឆ្នាំហើយ ។

កាលពីបុណ្យចូលឆ្នាំប្រពៃណីជាតិកន្លងទៅ មានមនុស្សម្នាច្រើនកុះករទៅលេងកម្សាន្ត ដូច្នោះហើយប្រមូលបច្ច័យបានច្រើនសម្រាប់ធ្វើបន្ទប់ទឹកនៅជើងភ្នំឱ្យអ្នកទេសចរជាតិ និងអន្តរជាតិប្រើប្រាស់ ។

លោកយាយណាង ស៊ុនធីម អាយុ៧២ឆ្នាំ ជាអ្នកមើលថែទាំនៅជើងភ្នំស្រីមានប្រសាសន៍ថា គាត់និងប្តីនៅបម្រើព្រះសង្ឃចាប់តាំងពីអំឡុងឆ្នាំ១៩៩៨មក ។ ក្នុងអំឡុងពេលនោះគាត់ដឹងថា មានការកសាងសាលាឆទាន១ខ្នងនៅជើងភ្នំព្រមទាំងសមិទ្ធផលផ្សេងៗទៀត ។

ប្តីរបស់លោកយាយណាង ស៊ុនធីម បានស្លាប់កាលពីឆ្នាំទៅតែគាត់នៅតែមានចិត្តជ្រះថ្លាក្នុងវិស័យព្រះពុទ្ធសាសនាគឺតែងតែនៅចាំរៃបច្ច័យពីភ្ញៀវ ទោះបីតិចក្តីច្រើនក្តីសន្សំដើម្បីឱ្យថ្លៃជាងធ្វើបន្ទប់ទឹកអនាម័យ ។

នៅលើភ្នំប្រុសនិងភ្នំស្រីមានចេតិយ១ នៅពីក្រោយព្រះវិហារដូចគ្នាក្នុងជំនាន់ដែលបុរសនិងស្ត្រីបបួលគ្នាលើកភ្នំ និងលើកថ្មបាយក្រៀមធ្វើចេតិយ ។

លោក ជួន សុផាត ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តឱ្យដឹងថា រមណីយដ្ឋានភ្នំប្រុសភ្នំស្រីមានរឿងនិទាន តៗគ្នាថានាសម័យកាល "ស្តេចស្រីអយុធ្យា" ដែលទ្រង់មានរូបឆោមស្រស់ស្អាតតែស្តីដណ្តឹងប្រុសៗមកធ្វើជាព្រះស្វាមីមិនបាន ។ បន្ទាប់មកក៏កោះប្រជុំស្ត្រីទាំងនគរចង់ឱ្យបុរសចូលស្តីដណ្តឹងស្ត្រីវិញ ។ គ្រានោះហើយបានបបួលប្រុសៗលើកភ្នំប្រុសភ្នំស្រីប្រណាំងគ្នា ។ ប្រុសៗនៅផ្នែកខាងលិច និងស្ត្រីវិញនៅប៉ែកខាងកើតថែមទាំងមានលក្ខខណ្ឌ បើឃើញផ្កាយព្រឹករះឡើងត្រូវនាំគ្នាឈប់ ។

ពេលជួងបន្លឺឡើងក៏នាំគ្នាលើកភ្នំប្រណាំងគ្នា ។ លុះវេលាជិតកណ្តាលអធ្រាត្រដោយភាគីស្ត្រីឆ្លាតវៃបានចងគោមលើកឡើងនៅទិសពាយ័ព្យត្រូវនឹងទិសផ្កាយព្រឹករះឡើង ធ្វើឱ្យប្រុសៗនាំគ្នាឈប់សម្រាក គឺចាញ់ល្បិចរបស់ស្ត្រី ។

ចំណែកខាងស្ត្រីវិញនាំគ្នាបន្តលើកដីរហូតដល់ឈ្នះប្រុសៗគឺភ្នំស្រីខ្ពស់ជាងភ្នំប្រុស ។ ចាប់តាំងពីពេលនោះមកប្រពៃណីបានផ្លាស់ប្តូរ គឺបុរសចូលស្តីដណ្តឹងស្ត្រីបន្តរហូតមកដល់សព្វថ្ងៃ ។ រឿងនិទាននេះមិនមានឯកសារណាមួយបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងសតវត្សទីប៉ុន្មានទេ គឺគ្រាន់តែដឹងថាក្នុងរជ្ជកាលស្តេចស្រីសម័យអយុធ្យា ។

លោកតា ហួត ទ្រី អាយុ៧២ឆ្នាំ នៅលើភ្នំសុវណ្ណគិរីរតនៈភ្នំប្រុសមានប្រសាសន៍ថា នៅចង្កេះជើងភ្នំប្រុសភ្នំស្រីកន្លងមកសម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុន រ៉ានី ហ៊ុន សែន បានកសាងសមិទ្ធផលជាច្រើន មានសាលាបាលី សាលាឆទាន បណ្ណាល័យ រូបសំណាកព្រះពុទ្ធប្រវត្តិតាំងពីប្រសូតរហូតដល់បរិនិព្វាន និង សមិទ្ធផលជាច្រើនទៀត ។

រាល់រដូវបុណ្យទានធំៗមហាជនពីគ្រប់ទិសទីនាំគ្នាទៅលេងភ្នំប្រុសសឹងតែរកកន្លែងដាក់រថយន្តមិនបាន ។ រាល់ថ្ងៃនេះមានព្រះចៅអធិការវត្តព្រះនាម ទឹម ស្រ៊ុន ព្រះជន្ម៧៩ព្រះវស្សា ។





# ត្រឹមតែ៣ថ្ងៃប៉ុណ្ណោះប្រហោងមុខ នឹងបាត់អស់ពីលើផ្ទៃមុខ



នៅលើផ្ទៃមុខមនុស្សម្នាក់ៗមានប្រហោងស្បែករាប់លានបើទោះជាយើងមិនអាចមើលឃើញដោយភ្នែកទទេបាន តែពេលអ្នកកាន់តែចាស់ឡើង ឬជួនកាលដោយសារបញ្ហាកើតមុនទើបធ្វើឱ្យមើលឃើញប្រហោងមុខ ប៉ុន្តែវានឹងបាត់ទៅវិញ បើអ្នកចង់បង្រួមវា ។

ទោះបីជាយ៉ាងណាក៏ដោយ ថ្ងៃនេះយើងមានវិធីម្យ៉ាងអាចបង្រួមប្រហោងមុខបានឆាប់រហ័ស:

**១. ប្រើទឹកខ្ទេះប៉ោមជាក្រែមបន្ទន់ស្បែក**

- យកទឹកខ្ទេះប៉ោម ១ស្លាបព្រាបាយ
- ដាក់ទឹកផឹកចូល ៥ស្លាបព្រាបាយ
- ច្របល់វាចូលគ្នា ហើយចាក់ចូលក្នុងដបបាញ់
- ក្រោយពេលលាងសម្អាតមុខរួចបាញ់ទឹកនេះលើផ្ទៃមុខរបស់អ្នក និងជូតឱ្យស្ងួត
- បន្ទាប់មកប្រើក្រែមសំណើមស្បែក

ទឹកខ្ទេះប៉ោមពិតជាមានប្រសិទ្ធិភាពជួយរឹតបន្តឹងប្រហោងមុខជួយរក្សាកម្រិតតុល្យភាពស្បែកប្រឆាំងនឹងការឆ្លងមេរោគ

**២. ប្រើជែលប្រទាលកន្ទុយក្រពើជាក្រែមរាត្រី**

**១.**លាបជែលប្រទាលកន្ទុយក្រពើពេញលើផ្ទៃមុខអ្នក និងទុកវាចោល១យប់

**២.**លុះព្រឹកឡើងលាងសម្អាតផ្ទៃមុខចេញ ។ វានឹងមិនត្រឹមតែរក្សាជាតិសំណើមលើស្បែកប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យស្បែកតឹងណែន ។ ជែលជួយលាងសម្អាតនិងចិញ្ចឹមស្បែក ព្រមទាំងកម្ចាត់ជាតិខ្លាញ់ ធាតុកខ្វក់ពីក្នុងរន្ធស្បែក

**៣.** ម៉ាស់ស៊ុតស

- ស៊ុតស ១គ្រាប់
- ម្សៅអាវ៉ែន ២ស្លាបព្រាបាយ
- ទឹកក្រូចឆ្មា ២ស្លាបព្រាបាយ

**ការណែនាំ**

**១.**យកស៊ុតសលាយច្របល់ចូលគ្នាជាមួយម្សៅអាវ៉ែន និងទឹកក្រូចឆ្មា ។ លាបវាលើផ្ទៃមុខអ្នក និងរង់ចាំរយៈពេល៣០នាទី ។

**២.**លាងសម្អាតនឹងទឹកត្រជាក់ ។

**៤.** ម្សៅសូដា


MIDDLESEX Community College
BEDFORD • LOWELL
សិស្សទទួលបានជោគជ័យគឺចាប់ផ្តើមពីទីនេះ

## ការគ្រប់គ្រងបដិសណ្ឋារកិច្ច - មុខវិជ្ជាធ្វើម្ហូប
កម្មវិធីកំរិតសញ្ញាប័ត្រ និងវិញ្ញាបនប័ត្រ

តើមានសេចក្តីប្រាថ្នាអាជីពខាងផ្នែកវិជ្ជាធ្វើម្ហូបដែរឬទេ?



កម្មវិធីមុខវិជ្ជាធ្វើម្ហូបរបស់សាលាមីដលសិច គឺជាទីកន្លែងដែលត្រូវចាប់ផ្តើម! កម្មវិធីរបស់យើងមានផ្តល់ជូននូវ៖

- ការបង្រៀនធ្វើម្ហូបដោយការអនុវត្តផ្ទាល់
- វគ្គសិក្សាពីការធ្វើអាជីវកម្ម និងការគ្រប់គ្រង
- ការចុះកម្មសិក្សាហ្វឹកហាត់ការងារផ្ទាល់
- ទំហំថ្នាក់តូច

ថ្នាក់គ្រប់គ្រងបដិសណ្ឋារកិច្ច-មុខវិជ្ជាធ្វើម្ហូបរបស់សាលាមីដលសិច ត្រូវបានបោះឆ្នោតជាប់ចំណាត់ថ្នាក់លេខ៤ នៅក្នុងរដ្ឋ ដោយ Best Choice Schools

ចុះឈ្មោះឥឡូវនេះសម្រាប់ថ្នាក់រដូវស្លឹកឈើជ្រុះ ដោយចាប់ផ្តើមពីថ្ងៃទី៥ ខែកញ្ញានេះតទៅ





មានការបង្ហាត់ផ្ទាល់ជាមួយលោកគ្រូដែលមានជំនាញនៅថ្នាក់បង្រៀនធ្វើម្ហូប ដោយប្រើប្រាស់ឧបករណ៍ និងសម្ភារៈថ្មីៗ និងទំនើបក្នុងក្រុងឡូវែល

ដើម្បីដឹងព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខ 1-800-818-3434 ឬចូលទៅកាន់វេបសាយ www.middlesex.mass.edu/hospitality

# វីតាមីន B1 ដ៏សក្តិសិទ្ធិបំផុត លេបហើយ មូសលែងហ៊ានខាំ



រដូវនេះជារដូវធ្លាក់ភ្លៀងដែលគេហៅថាជារដូវវស្សា ហើយក៏ជាពេលដែលសម្បូរទៅដោយសត្វមូសបំផុត និងជាពិសេស គឺមូសខ្លាដែលជាប្រភេទចម្លងមេរោគ ប៉ុន្តែមានវីតាមីនមួយចំនួនអាចជួយបណ្តេញមូសបានយ៉ាងមានប្រសិទ្ធិភាពបំផុត។ លោកអ្នកមិនចាំបាច់បារម្ភឡើយ ព្រោះមានថ្នាំបាញ់មូសដាក់លក់ពេញផ្សារ។ តែទោះជាយ៉ាងណា បើសិនអ្នកមិនចង់ធុំក្លិនថ្នាំបាញ់មូសក្នុងផ្ទះទេ ដែលធ្វើឱ្យមានក្លិនរំខានដល់ខ្ញុំកូនតូចៗនោះ លោកអ្នកសាកល្បងប្រើវីតាមីនទាំងនេះនៅក្នុងរបបអាហារប្រចាំថ្ងៃរបស់អ្នក។







**វីតាមីន B1**

វីតាមីន B1 គឺជាវីតាមីនមានប្រយោជន៍បំផុតចំពោះខ្លួនអ្នក។ អ្នកអាចរកវាបាននៅក្នុងអាហារដូចជា អង្ករសម្រូប ស្រូវអូក ថ្លើម ទំពាំង ផ្សិត និង ស៊ុត។ រឿងមួយដែលយើងនឹកស្មានមិនដល់នោះគឺ វីតាមីន B1មានអត្ថប្រយោជន៍ អាចផ្លាស់ប្តូរក្លិនរបស់អ្នក និងបណ្តេញសត្វមូសឱ្យចេញឆ្ងាយ។ កាលណាក្នុងខ្លួនអ្នកមានផ្ទុកវីតាមីន B1 គ្រប់គ្រាន់ ខ្លួនអ្នកនឹងមានក្លិនមេដំបែដែលធ្វើឱ្យមូសមិនហ៊ានខាំ។

**វេជ្ជបញ្ជា**

ប្រសិនអ្នកចង់សាកល្បងវា ទទួលទានវីតាមីន B1 100មីលីក្រាមជារៀងរាល់ថ្ងៃ។ រយៈពេល ២-៣ថ្ងៃអ្នកនឹងចាប់ផ្តើមសង្កេតឃើញថា ខ្លួនអ្នកលែងសូវមានមូសមកក្បែរ៕


REMEDIUM PHARMACY

ឱសថស្ថានរ៉ីមីឌៀម



ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក

ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ

FREE daily delivery | Blisterpack Packaging

Compounding Medication

2 Vinal Square. North Chelmsford, MA 01863

Tel: 978-251-7070 | Fax: 978-251-7071

តមកពីទំព័រទី ១៨

## ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់...

ទោះបីជាពួកគេដណ្តើមគ្រប់គ្រងក្រុមប្រឹក្សាឱ្យដែលមិនមែនជារឿងងាយស្រួល "បានក្តីក៏ពួកគេនឹងគ្មានលុយធ្វើដែរ"។

ប្រឈមនឹងក្បាលម៉ាស៊ីនរបស់គណបក្សប្រជាជនកម្ពុជា ដែលមានធនធានច្រើនជាងរដ្ឋអំណាចមូលដ្ឋានរូបមន្តបោះឆ្នោតដែលគាំទ្រអ្នកកំពុងកាន់តំណែង និងការស្មោក់ស្មើរចិត្តរហូតមករបស់អ្នកបោះឆ្នោតដែលមិនហ៊ានបោះបង់ការគាំទ្រចាស់គណបក្សប្រឆាំងប្រឈមផ្លូវវែងឆ្ងាយនៅខាងមុខទាំងការឈ្នះអាសនៈឃុំសង្កាត់និងការគ្រប់គ្រងវាដោយមានប្រសិទ្ធភាព។

ការបោះឆ្នោតឃុំ សង្កាត់ក្នុងឆ្នាំ២០១២មានឧបសគ្គតិចតួចប៉ុណ្ណោះសម្រាប់គណបក្សប្រឆាំង។

ក្រោយមកគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សដែលបានច្របាច់បញ្ចូលគ្នានៅក្នុងឆ្នាំនោះដើម្បីបង្កើតគណបក្សសង្គ្រោះជាតិដណ្តើមបានការគាំទ្រសរុប៣០ឞ៦ភាគរយនៃសំឡេងឆ្នោតទាំងអស់បើប្រៀបធៀបទៅនឹងប្រហែល៦០ភាគរយសម្រាប់គណបក្សប្រជាជនកម្ពុជា។

ប៉ុន្តែដោយសារតែសំឡេងឆ្នោតរបស់គណបក្សប្រឆាំងត្រូវបានបែកខ្ញែកនៅតាមឃុំសង្កាត់ជាច្រើន ដែលឃុំ សង្កាត់នីមួយៗតម្រូវឱ្យមានសំឡេងឆ្នោតភាគច្រើនជាងគេដើម្បីគ្រប់គ្រងតំណែងមេឃុំ?ឬចៅសង្កាត់នេះគណបក្សប្រជាជនកម្ពុជាអាចប្រែក្លាយសន្លឹកឆ្នោតរបស់ខ្លួនដើម្បីគ្រប់គ្រងប្រហែល៧២ភាគរយនៃអាសនៈក្រុមប្រឹក្សា និង៩៧ភាគរយនៃអាសនៈមេឃុំចៅសង្កាត់។

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ខុមហ្វ្រែល ដែលជាអង្គការឃ្លាំមើលការបោះឆ្នោតបានសរសេរនៅក្នុងរបាយការណ៍ក្រោយការបោះឆ្នោតរបស់ខ្លួនថា "គណបក្សប្រជាជនកម្ពុជាមានប្រៀបលើសលប់ដោយសារគិតតាមលក្ខណៈបច្ចេកទេសជាជាងហេតុផលនយោបាយ" ក្នុងនោះរួមទាំងរូបមន្តសម្រាប់ការតំណាងសមាមាត្រសម្រាប់មន្ត្រីក្រុមប្រឹក្សា"ដែលជាទូទៅគេចាត់ទុកថានាំឱ្យមានលទ្ធផលបោះឆ្នោតសមាមាត្រតិច" បើប្រៀបធៀបទៅនឹងប្រព័ន្ធផ្សេងទៀត។

លោក អ៊ា សុផល សរសេរថា "រចនាសម្ព័ន្ធនៃការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ធ្វើឱ្យមានស្ថានភាពមួយដែលគណបក្សប្រឆាំងមានសំណាងទទួលបានមួយឬពីរអាសនៈ ហើយ ប៉ុន្តែនៅតែបាត់បង់ក្រុមប្រឹក្សា។ អត្ថប្រយោជន៍នៃការកំពុងកាន់តំណែងគឺធំធេងណាស់"។

សម្រាប់ថ្នាក់ដឹកនាំមូលដ្ឋានជាច្រើន គឺកាន់តំណែងតាំងពីឆ្នាំ១៩៧៩ និងខ្លះតាំងពីសម័យខ្មែរក្រហមមកម្ល៉េះ នេះបើយោងតាមការសិក្សាឆ្នាំ២០០៨ដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលរកឃើញថា អ្នកបោះឆ្នោតនៅភូមិក្នុងឃុំមិនបញ្ចេញឈ្មោះចំនួន៣ បានប្រាប់អ្នកសិក្សាស្រាវជ្រាវថាពួកគាត់ចង់បានថ្នាក់ដឹកនាំចាស់ដែលកាន់តំណែងដុះស្លែជាងអ្នកថ្មីដែលមិនសូវមានទុនសង្គម ឬក៏ទំនាក់ទំនងជាមួយអ្នកគាំទ្រ។

ការសិក្សានេះលើកឡើងថា "ជាទូទៅអ្នកភូមិខ្លាចការផ្លាស់ប្តូរ ហើយថ្នាក់ដឹកនាំថ្មីត្រូវខិតខំ និងចំណាយពេលច្រើនដើម្បីឱ្យប្រជាពលរដ្ឋស្គាល់ និងទទួលយក"។

នៅក្នុងឃុំចំនួន៣ដែលខ្លួនបានចុះទៅក្រុមអ្នកសិក្សាស្រាវជ្រាវបានរកឃើញថា គណបក្សកាន់អំណាចមានទំនាក់ទំនងស៊ីជម្រៅជាមួយរដ្ឋាភិបាលជាមួយអ្នកគាំទ្រដ៏ស្មោះស្ម័គ្រដែលកសាងវត្តអារាម ជាមួយក្រុមការងារដែលមើលការខុសត្រូវការស្ថាបនាផ្លូវថ្មី និងជាមួយក្រុមប្រឹក្សាឃុំដែលយកតួនាទីរដ្ឋបាលរបស់ខ្លួនមកលាយឡំជាមួយយុទ្ធនាការឃោសនារបស់គណបក្សគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការចែកអំណោយ។

គណបក្សប្រជាជនកម្ពុជាបានចាត់តាំងឱ្យអ្នកគាំទ្រដ៏ស្មោះស្ម័គ្រដែលមានទ្រព្យសម្បត្តិ និងអំណាចចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋជាប្រចាំផ្តល់មូលនិធិ និងមើលការខុសត្រូវលើគម្រោងនានានៅស្ទើរគ្រប់ស្រុក ខណ្ឌ និងខេត្ត ដើម្បីធានាថា ប្រជាពលរដ្ឋបោះឆ្នោតឱ្យគណបក្សរបស់ខ្លួន។

ការសិក្សារបស់ CDRI បានគូសបញ្ជាក់ថា "គោលការណ៍មានទៅមានមកនេះនៅតែត្រូវបានប្រើប្រាស់ក្នុងផ្លូវមិនល្អដើម្បីធ្វើឱ្យភូមិអត់ពួកគេមិនបាន ហើយបោះឆ្នោតឱ្យអ្នកដែលផ្តល់ជំនួយ"។

នៅក្នុងករណីដែលថ្នាក់ដឹកនាំឃុំអាចឆក់យកបេះដូងអ្នកគាំទ្រខ្លួនបាន ដូចជាក្នុងករណីនៅឃុំមួយក្នុងចំណោមឃុំទាំងបីដែលក្រុម CDRI បានចុះទៅសិក្សានោះ គេឃើញថា អ្នកភូមិមិនសូវចង់មានការ ផ្លាស់ប្តូរទេ។

ប៉ុន្តែអ្នកនិពន្ធក៏បានលើកឡើងដែរថា ថ្នាក់ដឹកនាំមូលដ្ឋានដែលគាំទ្រអ្នកជំនួញមានអំណាចបុណ្យស័ក្តិខ្ពស់ដែលជាប់ពាក់ព័ន្ធក្នុងការទន្ទ្រានយកដី ឬការប្រព្រឹត្តអំពើពុករលួយ នោះអាចបាត់បង់តំណែងរបស់ខ្លួន ជាការយល់ឃើញដែលលោក មាស នី អ្នកវិទ្យាសាស្ត្រ សង្គម និងវិទ្យាសាស្ត្រនយោបាយបានលើកឡើងថា លោកបានឮកាន់តែច្រើនឡើងៗអំឡុងពេលបំពេញការងារនៅតាមខេត្ត។

សំដៅដល់ការយល់ដឹងកាន់តែច្រើនឡើងៗអំពីអ៊ិនធឺណិតដែលជួយឱ្យអ្នកបោះឆ្នោតដឹងព័ត៌មានកាន់តែច្រើនៗនោះ លោកបានថ្លែងថា "ខ្ញុំគិតថា ប្រជាពលរដ្ឋត្រៀមខ្លួនរួច ហើយសម្រាប់ការផ្លាស់ប្តូរ"។ លោកបានបន្តថា "មិនមែនគ្រប់គ្នានោះទេ ប៉ុន្តែមួយចំនួនធំ"។

សន្មតថាលោក មាស នី ត្រូវចុះ តែតាមបទពិសោធន៍កន្លងមក មេឃុំគណបក្សប្រឆាំងនឹងជួបការលំបាកច្រើនក្នុងការបំពេញការងារ។ ដោយថវិកាសម្រាប់ចំណាយផ្សេងៗស្ថិតនៅក្នុងដៃរដ្ឋាភិបាលដែលស្ទាក់ស្ទើរក្នុងការផ្តល់មូលនិធិ

តទៅទំព័រទី ២៥



តមកពីទំព័រទី ២៤

## ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់...

សូម្បីតែសម្រាប់ឃុំដែលគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត ទោះជាមានផែនការវិមជ្ឈការទូទាំងប្រទេសក៏ដោយនោះ មេឃុំគណបក្សប្រឆាំងបានលើកឡើងថា ខ្លួនជួបឧបសគ្គទ្វេដងក្នុងបំពេញការ និងទទួលមូលនិធិសម្រាប់គម្រោងផ្សេងៗ។

មេឃុំគណបក្ស សម រង្ស៊ី ដែលគេមិនបញ្ចេញឈ្មោះនិងដែលត្រូវបានសម្ភាសដោយ CDRI នោះ បានលើកឡើងថា លោកស្រីមានការលំបាកនៅក្នុងការស្វែងរកប្រាក់សម្រាប់គម្រោងនានា ហើយជានិច្ចកាលតែងតែទទួលបានព័ត៌មានក្រោយគេ។

លោក សៀក មេគង្គ មេឃុំគណបក្ស សម រង្ស៊ី នៅក្នុងខេត្តស្ទឹងត្រែងបានលើកឡើងថា អាជ្ញាធរស្រុក និងខេត្តជាទូទៅផ្តល់ប្រាក់៥០លានរៀលសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធប្រចាំឆ្នាំ ប៉ុន្តែបានបដិសេធសំណើរបស់លោកដែលស្នើសុំស្ពាបនាផ្លូវថ្មីមួយខ្សែក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយចោទប្រកាន់លោកថាប្រើប្រាស់មូលនិធិរដ្ឋខុសគោលដៅ។

លោកបានថ្លែងទាក់ទិននឹងក្រុមប្រឹក្សាស្រុកនិងខេត្តដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំថា "គេតែងតែជំទាស់នឹងខ្ញុំ ឬក៏ច្រានចោលសំណើរបស់ខ្ញុំ ព្រោះពួកគេមិនចង់ឱ្យមានសមាជិកគណបក្សប្រឆាំងនៅទីនេះ"។

គណបក្សសង្គ្រោះជាតិគ្មានអ្វីៗដើម្បីប្រកួតប្រជែងនឹងក្រុមការងាររបស់គណបក្សប្រជាជនកម្ពុជាដែលមានអំណាច និងទ្រព្យសម្បត្តិក្នុងរយៈពេលពាទសវត្សរ៍មកនេះនោះឡើយ។

លោក អ៊ា សុផល បានសរសេរថា "បើយើងក្រលេកមើលធនធានទីស្នាក់ការការិយាល័យមូលដ្ឋានរបស់គណបក្សកាន់អំណាចមើលទៅល្អប្រសើរជាងទីស្នាក់ការរបស់ទីប្រឹក្សាឃុំទៅទៀត"។ លោកបានបន្ថែមថា "វាច្បាស់ណាស់ថា តើលុយទាំងនេះបានមកពីណា"។

គណបក្សសង្គ្រោះជាតិសង្ឃឹមថា នឹងផ្លាស់ប្តូរអ្វីៗទាំងអស់នេះតាមរយៈការផ្តល់មូលនិធិ៥00.000ដុល្លារទៅឱ្យឃុំនីមួយៗ ជាគម្រោងដែលលោកស្រី មូរ សុខហួរ ទទួលស្គាល់ថាអាស្រ័យលើជ័យជម្នះរបស់គណបក្សលោកស្រីនៅក្នុងការបោះឆ្នោតជាតិឆ្នាំក្រោយ។

លោកស្រីបានថ្លែងថា "ហេតុដូច្នេះ ហើយទើបយើងកំពុងភ្ជាប់សារឆ្នាំ២០១៧ជាមួយនឹងសារឆ្នាំ២០១៨"។ លោកស្រីបានបន្ថែមថា "តែថវិកាជាតិស្ថិតនៅក្នុងដៃរបស់គណបក្សកាន់អំណាច"។

គណបក្សសង្គ្រោះជាតិសង្ឃឹមថា អ្នកបោះឆ្នោតមូលដ្ឋានដែលមានទំនាក់ទំនងស៊ីជម្រៅជាមួយគណបក្សប្រជាជកម្ពុជានឹងមិនបោះឆ្នោតឱ្យគណបក្សកាន់អំណាចនេះឡើយ ដោយសារប្រជាពលរដ្ឋខ្មែរបានដឹងអំពីការដឹកនាំរបស់រដ្ឋាភិបាលក្នុងរយៈពេលជាច្រើនទសវត្សរ៍មកនេះ ហើយមិនចង់ឃើញអ្វីដែលពួកគាត់បានជួបទៀតនោះទេ។

លោកស្រី មូរ សុខហួរ បានមានប្រសាសន៍ថា "សារតែមួយគត់របស់ពួកគេគឺបំភ័យ"។ លោកស្រីបានបន្តថា "យុទ្ធសាស្ត្ររបស់យើង គឺពីផ្ទះមួយទៅផ្ទះមួយពីភូមិមួយទៅភូមិមួយ"។

លោក អ៊ា សុផល បានលើកឡើងទៀតថា លោកមិនជឿថា គណបក្សសង្គ្រោះជាតិអាចប្រែក្លាយការខិតខំនេះឱ្យទទួលបានលទ្ធផលដ៏ល្អប្រសើរដូចកាលពីឆ្នាំ២០១២ទៀតនោះឡើយ។

ប៉ុន្តែលោក មាស នី មានការប្រមើលមើលក្នុងផ្លូវប្រសើរជាងសម្រាប់គណបក្សប្រឆាំងដោយព្យាករថា គណបក្សសង្គ្រោះជាតិនឹងទទួលបានអាសនៈឃុំសង្កាត់ប្រហែល៤០ភាគរយ ដោយសារគណបក្សប្រជាជនកម្ពុជានៅតែប្រកាន់ខ្ជាប់ "យុទ្ធសាស្ត្រចាស់របស់ខ្លួន" ។ លោកបានរៀបរាប់ពីសកម្មភាពដែលបានឃើញអ្នកភូមិចេញពីកន្លែងប្រជុំរបស់គណបក្សប្រជាជនមកវិញដោយទទួលបានប្រាក់២ម៉ឺនរៀលមកជាមួយក្នុងពេលថ្មីៗ។ លោកបានថ្លែងថា "ពេលពួកគាត់ចេញមកវិញពួកគាត់នាំគ្នាសើច"។ លោកបានលើកឡើងបន្តលោកបានឮអ្នកភូមិមូលដ្ឋាននិយាយថា "អស់លោកមិនអាចធ្វើឱ្យខ្ញុំផ្លាស់ប្តូរចិត្ត ឬបេះដូងបាននោះទេ"។ **សុខុម និងស៊ុយឈាង (រាយការណ៍បន្ថែមដោយ សេក ឧត្តម)**












**តពីលេខមុន**

-ពេលដែលយើងត្រូវបែកគ្នាមកដល់ ហើយលោក ម៉ាំង ឧទ្ទានថា "កូនដឹងថានឹងទៅទីណាទេ? គឺកូនទៅរៀននៅសាលាកុមារយោធធិន្ទវិញ នៅកំពុងចាមកូនត្រូវខំរៀន ដើម្បីឱ្យបានពាក់សាក់ដូចប៉ា ឬក៏ធំជាងប៉ាផងក៏មិនដឹង, ប៉ាម៉ាក់មិនបាននៅជាមួយកូនរាល់ថ្ងៃទេ តែប៉ាម៉ាក់នឹងបងប្អូននៅទីនេះ នឹងនឹកដល់ឯងជានិច្ច ហើយឯងក៏អាចមកលេងនឹងប៉ាម្ដងម្កាលបានដែរឬទេ?" ចៅប៉ុនដឹងថានឹងមានថ្ងៃនេះនៅពេលណាមួយជាមិនខានទេ តែមិនដែលបែកពីម្ដាយឪពុក ចៅប៉ុនស្រក់ទឹកភ្នែកច្រោក ដើរសំដៅទៅរថយន្ត "កាត់១" មិនងាកក្រោយឡើយ ព្រោះដឹងថាសេចក្ដីសម្រេចនេះនឹងមិនត្រឡប់ក្រោយបានឡើយ ហើយម្យាងទៀតថ្វីត្បិតតែដឹងថា នឹងមិនបានទទួលការថ្នាក់ថ្នម នឹងកាពារពីម្ដាយឪពុកតទៅទៀតក៏ដោយសេចក្ដីសម្រេចចិត្តរបស់ឪពុកខ្លួន ជាសេចក្ដីសម្រេចចិត្តចុងក្រោយគេបង្អស់ដែរ, ងាកទៅមើលម្ដាយចៅប៉ុន ជូតទឹកភ្នែកមិនឈប់សោះ លោកស្រីមិនដែលបញ្ចេញយោបល់ជំទាស់ឪពុកម្ដងណាឡើយ។ ចៅពិន ជាប្អូន ហាក់ដូចជាស្រឡាំងកាំង ចំពោះការព្រាត់ប្រាស់គ្នានេះ មិនយំទេ តែដើរទៅដឹកដៃបងរបស់ខ្លួនជូនទៅកាន់រថយន្ត, ហាក់ដូចជារង់ចាំព្រឹត្តិការណ៍ស្រដៀងគ្នានេះ នឹងកើតដល់ខ្លួននៅពេលខាងមុខជាមិនខានឡើយ, ចៅពិន និយាយប្រាប់បងថា បងដឹងទេខ្ញុំមិនយូរមិនឆាប់នឹងតាមទៅរកបងដែរហើយ! ឥឡូវខ្ញុំនៅតូចមិនទាន់ទៅជាមួយបងបានទេ ចៅប៉ុនងាកមកញញឹមបន្តិចហើយនិយាយទាំងអួលដើមករថា "មែនហើយ, បងនៅចាំឯងនៅទីនោះណា!" ថាហើយក៏បោះវ៉ាលីសព្រួសទៅក្នុងឡាន ចៅប៉ុនឡើងអង្គុយក្នុងឡាងរួចហើយ, ទាហ៊ានស្មៀកឯកសណ្ឋានខ្លី "ស៊ែហ្សង់" បានមកគោះជើងគំនាប់លាលោកកុម៉ង់ដង់ម៉ាំង, ហើយថា "ខ្ញុំបាទគោរពលាហើយតេកគុណ!" រួចក៏នាំចៅប៉ុនចេញឡានទៅបាត់។

ចៅប៉ុនចេញទៅបាត់២អាទិត្យហើយនៅពាក់កណ្ដាលឆ្នាំ១៩៥២ ពុំមានដំណឹងអ្វីពីចៅប៉ុនវិញសោះ គេតែងនិយាយថា "គ្មានដំណឹងគឺដំណឹងល្អ" គ្រួសារលោកកុម្មដង់ម៉ាំងរួមកាន់តែតូចនៅសល់បងស្រី យ៉ាស៊ុន នឹងចៅពិនតែប៉ុណ្ណោះ មិនយូរប៉ុន្មានក៏ដល់ពេលចៅពិនទៀត។ ថ្ងៃអាទិត្យបន្ទាប់មកប្រមាណជាម៉ោង៨ព្រឹក "សូហ្វ័រ"ឡាង"ហ្សីប"តូចលោកកុម៉ង់ដង់ម៉ាំង



មកដល់ទទួលលោកម៉ាំង លោកស្រី នឹងចៅពិន ជូនទៅវត្ត"សាមគ្គីរាម"ហៅវត្តថ្មី ស្ថិតនៅខាងជើងឈៀងខាងកើតនៃខេត្រកំពង់ស្ពឺ លោកស្រីមានចានស្រាក់ដាក់ម្ហូបអាហារយ៉ាងពេញ ដើម្បីយកទៅប្រគេនលោក។ ទៅវត្តសាមគ្គីរាម ឬ "វត្តថ្មី"ពីព្រោះគ្រួសារលោកកិម៉ង់ដង់ម៉ាំងស្គាល់ព្រះតេជគុណ សូមេត នោះជាចៅអធិការច្បាស់លាស់ ដោយធ្លាប់បានជួបគ្នានៅពិធីផ្សេងៗផង នឹងមកចូលរួមផ្ដើមបុណ្យផង។ ដើម្បីទៅវត្តថ្មី តាមផ្លូវកាត់ហាក់ដូចជាជិតបង្ខើយពី ពីព្រោះបន្ទាយនៅពីខាងត្បូងឈៀងខាងកើត រីឯវត្តថ្មីស្ថិតនៅខាងជើងចំពីបន្ទាយជើងខ្មៅទៅ តែត្រូវឆ្លងស្ទឹងព្រែកត្នោតនៅក្បែរៗនេះគ្មានស្ពានទេ ហើយក៏មិនងាយនឹងរកទូកដែរ ពីព្រោះទឹកច្រើនរាក់បន្ទាប់ពីទំនប់ ហើយសម្បូរថ្មដេបរដុបដោយរដ្ឋាភិបាលខេត្ត គេប្រមូលថ្មផ្ទាំងធំៗមកទប់ទឹកនៅទីនោះ ឱ្យទឹកឡើងខ្ពស់សម្រាប់គេបូមយកទៅបញ្ចូលម៉ាស៊ីនភ្លើងដ៏ធំមួយសម្រាប់ភ្លើងអគ្គិសនីប្រើក្នុងក្រុងកំពង់ស្ពឺទាំងមូល។ គ្រួសារលោកកុម៉ង់ដង់ ម៉ាំង ត្រូវទៅកាត់ផ្សារកំពង់ស្ពឺ ដើម្បីទៅវត្ត ពីព្រោះមានតែទីនោះមួយគត់ដែលមានស្ពានសម្រាប់ឆ្លងពីខាងត្បូងទៅខាងជើងបានរថយន្តហ្សីបបោះពួយតាមផ្លូវជាតិរហូតដល់ក្លោងទ្វារវត្ត រួចទៅដល់វត្តព្រះតេជគុណ សូម៉េត នៅគង់រង់ចាំទទួលឯជើងជណ្ដើរសាលាឆាន់រួចជាស្រេច ពីព្រោះដឹងថា លោកកុម៉ងដង់ម៉ាំងមកដល់ទៀងម៉ោងណាស់ មិនដែលយឺតទេ។ ទាំងអស់គ្នាថ្វាយបង្គំព្រះសង្ឃរួចហើយ លោកស្រី ស៊ីង នាំយកចង្ហាន់ទាំងស្រាក់ឡើងសាលាជាមួយកូន ដើម្បីឱ្យអាចារ្យគេរៀបចំសម្រាប់លោកឆាន់ថ្ងៃត្រង់នៅពេលដែលលោកប្រុសដើរតាមព្រះគ្រូ សូម៉េត ដែលទំនងជារាយការពីស្ថានភាពនឹងជីវភាពក្នុងវត្តជូនលោកកុម៉ងដង់ឱ្យបានជ្រាប។ វត្តនោះមានទីធ្លាធំទូលាយនៅចំកណ្ដាលខាងកើតមានទង់សញ្ញាក្រពើដ៏ធំមួយយោលរេរាតាខ្យល់នៅបង្គោលដ៏ខ្ពស់មួយនៅទល់មុខគ្នានោះ បន្ទាប់ពីទីធ្លាដ៏ធំនោះទៅមានអាគារសង់មិនទាន់ហើយមួយ គឺសាលាបាលីដែលប្រហែលជាខកខានមិនបានបន្តសង់បញ្ចប់ច្រើនឆ្នាំមកហើយ លោកគ្រូមេវត្តត្រូវរកសប្បុរសជន មកជួយសង់ឱ្យបានឆាប់ចប់ដែរ ប្រជាពលរដ្ឋថ្វីត្បិតតែមានសទ្ធាមែនតែនៅក្រីក្រមិនអាចជួយបច្ច័យបានច្រើនទេ ក្នុងមួយឆ្នាំៗនោះ។ នៅផ្នែកខាងជើងវត្តមានសាលាឆាន់ធំវែងខ្ពស់ពីដីចំណាច់ច្រើនសិបឆ្នាំហើយ តែនៅមាំទាំងខ្លាំណាស់នៅឡើយ ហើយនៅទល់មុខគ្នានឹងសាលាឆាន់នោះ នាទិសម្ខាងទៀតនៃទីធ្លាធំនោះ គឺព្រះវិហ៊ារចាស់វស្សាមួយដែរ មិនទាន់ជាទ្រុឌទ្រោមនៅឡើយ ធ្វើពីឈើ ហើយកុដិលោកនឹងសំណាក់យាយជីតាជីមាន៥-៦ខ្នងពីក្រោយព្រះវិហ៊ារនឹងសាលបាលី ហើយនៅពីក្រោយកុដិជីវាលឆ្ងាយបន្តិចក៏ដល់ស្ទឹងព្រែកត្នោត។

ម៉ោង១០កន្លះព្រឹក លោកតាអាចារ្យគោះគងនិមន្តព្រះសង្ឃមកសាលាឆាន់លោកគ្រូចៅអធិការនឹងលោកកុម៉ង់ដង់ក៏ត្រឡប់មកសាលឆាន់ដូចលោកឯទៀតដែរ ឆាន់ថ្ងៃត្រង់ជាពិធីសំខាន់មួយក្នុងមួយថ្ងៃៗ ដែលគ្រហស្ថវេប្រគេនចង្ហាន់ចំពោះព្រះសង្ឃហើយ គេមានសូត្រធមិម្ដងឆាន់ចប់ព្រះសង្ឃជូនពរសព្វសាធុការត្រឡប់មកវិញ នាចន្លោះពេលធ្វើពិធីទាំងនោះ លោកម៉ាំងក៏ទូលលោកថា "ខ្ញុំព្រះករុណាមករកព្រះតេជគុណថ្ងៃនេះ ពីព្រោះចង់ផ្ញើរអាចៅពីន ជាកូនឱ្យមកធ្វើជាកូនសិស្សរបស់ព្រះអង្គពីថ្ងៃនេះតទៅប្រគេនព្រះអង្គឱ្យជួយប្រៀនប្រដៅ ខ្ញុំព្រះករុណាសុំដូចពាក្យបូរាណតែងនិយាយថាខ្ញុំគួណាប្រគល់ស្បែកនឹងសាច់ប្រគេនព្រះអង្គហើយ សូមតែភ្នែកនឹងឆ្អឹងត្រឡប់ទៅវិញតែប៉ុណ្ណោះ..." លោកគ្រូ សូមេត តបថា "ដូចអាត្មាបានជម្រាបញោមកុម៉ង់ដង់រួចហើយ ថាអាត្មាទទួលចៅពិនជាកូនសិស្សបានជាសិស្សជំនិតជាមួយអាចៅថាចម្នាក់ទៀតគ្រាន់បានជាគ្នា"មានសង្ឃដីការរួចក៏បន្តរឆាន់តទៅទៀត នៅក្បែរព្រះអង្គមានសិស្សម្នាក់ទៀតឈ្មោះ ចៅថាច ជាកូនរបស់នាយទាហ៊ានម្នាក់ធ្វើជាគណនេយ្យកងទ័ពជាមួយលោកម៉ាំងដែរ ចៅពិនមិនបានយល់ពីពាក្យដែលឪពុករបស់ខ្លួននិយាយប្រគល់ទៅឱ្យព្រះសង្ឃនោះបានន័យយ៉ាងណានោទេ តែទោះជាឱ្យធ្វើយ៉ាងណាក៏មិនអាចប្រកែកនឹងឪពុកបានដែរ ។ អង្គុយមើលលោកឆាន់ប្រមាណ១០អង្គ ឃើញតែលោកគ្រូចៅអធិការតែមួយអង្គគត់ដែរ ឆាន់មានសណ្ដាប់ធ្នាប់ខុសពីគេអស់, បាយដួសដាក់ចានតែមួយវែក ស្លាបព្រានឹងសមធ្វើពីលោហធាតុដ៏ធ្ងន់របស់លោក លោករៀបបាយដាក់លើស្លាបព្រាសង្កត់ឱ្យរាបស្មើ ដាក់ត្រី ឬសាច់មួយដុំពីលើបាយនោះទើបឆាន់មិនឱ្យមានឃើញរលិះរលែះម្ដងណាទេ ម្ហូបឆ្ងាញ់ឬមិនឆ្ងាញ់ក៏ឥតមាននរណាមើលទឹកមុខលោកដឹងបានទេ លោកឆាន់ដូចជាគេរាប់ចំនួនស្លាបព្រាអស់បាយពីចានត្រឹមណាលោកឈប់ត្រឹមណុង មិនមានថែមម្ដងទៀតទេ ពេលលោកឆាន់សម្លរម្ដងៗ លោកតែងដួសដាក់កូនចានតូចមួយដាក់នៅក្បែរដៃលោក ហើយក៏មិនដួសម្ដងទៀតដែរ។ ព្រះអង្គមានរូបរាងស្គមខ្ពស់ ថ្ពាល់ខូង តែរហ័សរហួនមិនមានទ្រមក់ដូចជាមនុស្សឈឺទេ, ព្រះអង្គបានហៅចៅពិនឱ្យឡើងមកអង្គុយបត់ជើងក្បែរលោកឱ្យបាននៅជាមួយនឹងចៅថាច ដែលទំនងជាមានអាយុប្រហាក់ប្រហែលគ្នា តែនោះគេក្រម៉ាប់ជាងហើយក្រម៉ាច់ក្រមើមទៀតផង។

ម៉ោង១១កន្លះ ពិធីឆាន់ថ្ងៃត្រង់បានត្រូវ

**តទៅទំព័រទី២៧**

## តមកពីទំព័រទី ២៦ រឿងប្រលោមលោក "រឿងចៅពិន"...

បញ្ចប់លោកកុម៉ង់ដង់នឹងភរិយាក៏ថ្វាយបង្គំលាលោកគ្រូចៅអធិការ នឹងលាអ្នកទាំងអស់គ្នាដែលបានទទួលរាក់ទាក់នឹងលោក ហើយងាកមកសន្យានឹងកូនថាល្ងាចនឹងឱ្យគេមកទទួលទៅបន្ទាយវិញ ហើយស្អែកព្រឹកព្រលឹមនឹងមកម្តងទៀត។ អ្នកទាំង២ចេញដំណើរដោយមិនបានទទួលម្ហូបអាហារ ដែលលោកឆាន់មាននៅវត្តនោះទេ តែចៅពិន នឹងចៅថាចបានហូបម្ហូបស្លកសល់ពីលោកគ្រូចៅអធិការតែ២នាក់គ្នាឯង, អ្នកឯទៀតយកម្ហូបដែលសែសសល់ពីស្លកលោកដ៏ទៃឯទៀត មករៀបជា២វង់ហើយ"ហូបបាយជាកូនសិស្សលោក" ជុំទាំងអស់គ្នាទៅ។ ការពិតទៅការហូបបាយដាក់ ហើយបោសសំអាតកន្លែងតុបាយខ្លួនឯងឱ្យបានស្អាតឡើងវិញធ្វើការ២នាក់បែបស្រួលដែរ។ នៅកាច់ជ្រុងម្ខាងនៃសាលាឆាន់មានជញ្ជាំងឈើបាំងថ្ងៃជិតដែរ លោកគ្រូយកជាកន្លែងសម្រាប់លោកសឹងពេលថ្ងៃ បន្ទាប់ពីពេលឆាន់នឹងចរចាជាមួយចាស់ទុំក្នុងវត្តរួច ហើយនៅសល់កន្លែងបន្តិចចៅថាចក្រាលកន្ទេលដេកថ្ងៃក្បែរលោកដែរ លោកគ្រូបានចង្អុលបង្ហាញកន្លែងឱ្យចៅពិនទៅដេកថ្ងៃជាមួយគ្នានឹងចៅថាច តែមិនឱ្យទៅលេងទឹកស្ទឹងទេ ខ្លាចលង់ទឹកស្លាប់។ លោកគ្រូចូលសឹងបានមួយសន្ទុះក្នុងបន្ទប់ដែលបិទបាំងដោយផ្ទាំងស្បង់ធំកូនសិស្សទាំង២មិនបានចូលទៅដេកទេ ជជែកគ្នាខ្សិប



ជុំគ្នានេះ ជាឱកាសល្អណាស់ដែលធ្វើឱ្យមនុស្សស្គាល់គ្នាប្រស្រ័យទាក់ទងគ្នាហើយរាប់អានគ្នាបានតែគេមានពេលតិចតួចមកគិតពីអនាម័យដែលអាចឆ្លងជម្ងឺពីម្នាក់ទៅម្នាក់យ៉ាងងាយស្រួលដោយការដួសសម្លរពីស្លាព្រាអ្នកជម្ងឺម្នាក់ទៅមនុស្សដែលមានសុខភាពល្អនៅក្នុងចានសម្លឬឆាដដែល ហើយទម្លាប់នេះបានបន្តរាប់ឆ្នាំមកហើយ នឹងនៅបន្តរាប់ឆ្នាំទៅមុខទៀត ដោយគ្មាននរណាដឹងថា នៅផ្ទះអ្នករួមស្លកមាននរណាជាអ្នកមានជម្ងឺឆ្លងដែ ឬទេ។ ព្រះគ្រូចៅអធិការបានផ្តល់គំរូនៃការប្រុងប្រយ័ត្នក្នុងការបរិភោគចំណីអាហារដល់ពុទ្ធបរិស័ទជារឿងរាល់ថ្ងៃ ប៉ុន្តែមានបនុស្សប៉ុន្មាននាក់បានទទួលនូវឱវាទនេះ? ប្រហែលជាមិនយល់ថា មានប្រយោជន៏អ្វីនឹងធ្វើតាមលោកនោះផង!

ចៅពិនមកនៅវត្ត នាថ្ងៃដំបូងមិនសូវបានមាត់កអ្វីទេ សម្លឹងមើលអាចៅថាច គេធ្វើអ្វីខ្លះក៏ធ្វើតាមគេទៅយើងជាកូនសិស្សត្រូវលើកចានទៅឱ្យគេលាងផ្ទេរម្ហូបដែលនៅសល់ទៅទុកខ្សៀវក្បែរត្រចៀកលោកគ្រូ លោកក៏ក្រហែមឡើង ពួកគេបែកគំនិតនាំគ្នាទៅមើលក្មេងគប់វង់នៅឯក្រោយវត្ត, ថ្ងៃក្តៅហែង អ្នកទាំង២មិនបានពាក់អាវទៅទេ ខោខ្លីរឹតកៅស៊ូចង្កេះខ្លួនទទេ មកចូលហ្វូងពួកអ្នកគប់វង់ដាក់កៅស៊ូសមតែចុះ តែពួកនោះជាក្មេងធំៗពូកែរខ្លាំងណាស់ដៃវែងៗហើយគប់ត្រង់ទៀតផង ដូច្នេះគេមិនឱ្យលេងជាមួយគេទេ ក្មេងស្រី៧៣-៤នាក់នៅក្បែរនោះ ជាអ្នកកាន់កៅស៊ូឱ្យបងរបស់ខ្លួនលេងអ្វីផ្សេងជាមួយគ្នាឯងជាស្រីៗ មានភាពអ៊ូអរខ្លាំងណាស់ដែរ ពេលខ្លះសម្លេងឡូឡាខ្លាំងពេកឮដល់លោកគ្រូក៏ប្រាប់តាតាឱ្យដេញក្មេងរត់ខ្ចាត់ខ្ចាយអស់ក៏មាន។ ដោយមិនបានលេងនឹងគេក៏ដើរមួយជុំចង់ទៅបេះស្វាយបន្តិច ចង់បេះផ្លែពុទ្រាបន្តិច ចង់បេះម៉ាក់ប្រាំងបន្តិច ចុងបញ្ចប់ក៏សម្រេចទៅរើសអំពិលទុំយកមកដើរបកហូបលេងតែ២នាក់ ក្នុងវត្តសម្បូរដោយផ្លែឈើទុំហើយជ្រុះចោលច្រើនណាស់ គួរឱ្យស្តាយមុននឹង

**តទៅលេខក្រោយ**

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៏ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial
45, Merrimack Street, #218A
Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៏ដល់សហគមន៏ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**


**កាសែតដែលបំរើសហគមន៏ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ**

KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Richard Howe Jr,
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២............................................................

**អត្ថបទក្នុងសំបុត្រនេះ:**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


# MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com



Element Care

# ខ្ញុំគ្មានការព្រួយបារម្ភទៀតទេ។



- ការផ្តល់សេវាធ្មេញដោយឥតគិតថ្លៃ
- ការផ្តល់ជូននូវយានជំនិះដោយឥតគិតថ្លៃ
- ផ្តល់ជូនវ៉ែនតានិងឧបករណ៍ជំនួយការស្តាប់ដោយឥតគិតថ្លៃ
- ការថែទាំតាមផ្ទះនិងផ្តល់ជូននូវអាហារដោយឥតគិតថ្លៃ
- ផ្តល់ជូននូវថ្នាំតាមវេជ្ជបញ្ជាដោយឥតគិតថ្លៃ

## នៅជាមួយនឹងកម្មវិធី PACE នៃអង្គការ Element Care, ការថែរក្សានឹងការចំណាយរបស់ខ្ញុំគឺត្រូវបានទទួលខុសត្រូវទាំងស្រុងជំនួសខ្ញុំ។

អ្នកដែលមានសិទ្ធិមាន MassHealth នឹង Medicare គឺមិនត្រូវបង់ថ្លៃទេ។ សូមទាក់ទងមកយើងខ្ញុំបើអ្នកមានតែ Medicare ហើយនឹងការបង់ថ្លៃដោយឯកជន។ គ្រប់សមាជិកទទួលបាននូវការថែទាំសុខភាព, សេវាកម្មពេទ្យឯកទេស-លើកលែងតែសេវាកម្មសង្គ្រោះបន្ទាន់-ដូចជាបានអនុញ្ញាតពីកម្មវិធី PACE, ពុំនោះទេនឹងទទួលខុសត្រូវដោយខ្លួនឯងចំពោះថ្លៃសេវាកម្មមិនបានអនុញ្ញាតជាមុន។
H2222_2016_3K

សូមអញ្ជើញទាក់ទងមកកាន់ទូរសព្ទលេខខាងក្រោមនេះ
1-877-803-5564
(TTY 711)
ឬក៏តាមរយៈ:
elementcare.org







## NOTICE OF PUBLIC MEETING AND COMMENT OPPORTUNITY:Draft Amendment 2 to theNMMPOFFY 2017-2021 Transportation Improvement Program

The Northern Middlesex Metropolitan Planning Organization (NMMPO) has releaseda draft amendment to the FFY 2017-2021 Transportation Improvement Program (TIP)for public comment. The proposed TIP amendment programs-funding for several projects in Lowell, including canalwaypedestrian improvements in the downtown area, rehabilitation of the Swamp Locks pedestrian bridge, and reprogramming of a TIGER grant award for the rehabilitation of six canal bridges.

A public meeting to receive comments on the draft amendmentwill be held on June 6th, 5:30 PM, at the Northern Middlesex Council of Governments office,40 Church Street, Suite 200, Lowell, MA.You may submit comments by phone at (978) 454-8021, ext. 121, or by email:jhoward@nmcog.org. If preferred, comments may be mailed to the above address. The public comment period for the TIP amendment ends on June 16, 2017.You may access a copy of the documents online atwww.nmcog.org. Please note the TIP contains the program of projects for the Lowell Regional Transit Authority (LRTA). The MPO's public participation process satisfies the LRTA's public participation requirements for the program of projects.

## សេចក្តីជូនដំណឹងស្តីពីការរៀបចំកិច្ចប្រជុំជាសាធារណៈ និងឪកាសក្នុងការបញ្ចេញមតិពង្រៀងវិសោធនកម្មលើកទី២ ចំពោះគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន NMMPO FFY 2017-2021

អង្គភាពរៀបចំក្រុង ន័សធន ម៉ុដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO បានផ្សព្វផ្សាយពង្រៀងវិសោធនកម្មគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (TIP) FFY ឆ្នាំ ២០១៧-២០២១សម្រាប់ទទួលនូវមតិយោបល់ពីសារធារណជន។ កម្មវិធីវិសោធនកម្មគម្រោងទីភដែលបានស្នើឡើង ជាមូលនិធិសម្រាប់គម្រោងមួយចំនួនក្នុងក្រុងឡូវែល មានដូចជាការលើកកម្ពស់ផ្លូវដើរសម្រាប់អ្នកដើរនៅតំបន់កណ្តាលក្រុង, ការស្តារឡើងវិញស្ពានសម្រាប់អ្នកដើរ Swamp Locks និងការរៀបចំកម្មវិធីឡើងវិញនៃអំណោយថវិការ TIGER សម្រាប់ការស្តារឡើងវិញស្ពានប្រឡាយចំនួន ៦។

ការរៀបចំកិច្ចប្រជុំជាសាធារណៈ ដើម្បីទទួលមត្តិយោបលលើពង្រៀងវិសោធកម្មនេះនឹងប្រព្រឹត្តទៅនៅវេលាម៉ោង ៥:៣០ ល្ងាចនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៧ នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធន ម៉ុដូលសិច ៕ Northern Middlesex Council of Governments) ដែលមានទីតាំងស្ថិតនៅផ្លូវ 40 Church Street, Suite 200, Lowell, MA ។ លោកអ្នកអាចផ្តល់ជាមតិយោបលតាមរយៈទូរស័ព្ទមកកាន់លេខ (978) 454-8021, ext 121 រឺអ៊ីម៉េលមកអសយដ្ឋាន jhoward@nmcog.org ។ លោកអ្នកអាចផ្ញើសំបុត្រមកកាន់យើងខ្ញុំតាមរយៈអសយដ្ឋានខាងលើ ប្រសិនបើលោកអ្នកចងសរសរជាសំណូមពរ រឺមានយោបល់។ កាលបរិច្ឆេទទទួលមត្តិយោបលជាសាធារណៈសម្រាប់ពង្រៀងវិសោធកម្មគម្រោង TIP នឹងបញ្ចប់នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧។ លោកអ្នកអាចទទួលបាននូវច្បាប់ចម្លងនៃឯកសារពង្រៀងខាងលើមាននៅ online តាមរយៈវេបសាយ www.nmcog.org។ សូមបញ្ជាក់ថា គម្រោង TIP មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើន សម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA)ផងដែរ។ ដំណើរការចូលរួមជាសាធាណៈរបស់អង្គភាព MPO គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន ៕

## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare®
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# KhmerPost USA

Cambodian American Biweekly Newspaper

## ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវែល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

Connecting 50,000 Khmer-speaking readers per month.
Free Newspaper copies are available in these cities:

Massachusetts:

- Lowell
- Lynn/Revere

Rhode Island:

- Providence
- Cranston



Soben Pin, Co-founder/Managing Partner;
Sochet Chhen, Office Coordinator

**កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ :**

- ថ្ងៃទី ១២ និង ២៦ ខែមិថុនា
- ថ្ងៃទី ១០ និង ២៤ ខែកក្កដា
- ថ្ងៃទី ០៧ និង ២១ ខែសីហា
- ថ្ងៃទី ១១ និង ២៥ ខែតុលា
- ថ្ងៃទី ០៩ និង ២៣ ខែកញ្ញា
- ថ្ងៃទី ០៦ និង ២០ ខែវិច្ឆិការ
- ថ្ងៃទី ០៤ និង ១៨ ខែធ្នូ

**2017 Print Dates**

- June 12, 26
- July 10, 24
- August 07, 21
- September 11, 25
- October 09, 23
- November 06, 20
- December 04, 18

* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន ៣ ថ្ងៃមុនការបោះផ្សាយ។

**ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក**

**Contact Soben Pin For Advertising Opportunities**
**Email: sobenpin@khmerpost.us**
**978-677-7163**

ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:00 ល្ងាច
អសយដ្ឋានការិយាល័យ**កាសែតខ្មែរផុសស.រ.អា**

Office: KhmerPost USA, LLC. 45 Merrimack St. Suite 218A. Lowell, MA 01852
Hours: Monday – Friday. 9AM – 4PM
**VISIT KHMERPOST.US**

# ១០ឆ្នាំនៃការបង្កើតកាសែតខ្មែរផុសក្នុងទឹកដីអាមេរិក


វាគ្មិនកិត្តិយស សេរ៉ូ បេរ៉ូ


របាំសមាគមអង្គរ



វាគ្មិនសេរ៉ូប៊ីរ៉ូ រ៉ូដអាឡិន


ក្រុមការងារខ្មែរផុស


ក្រុមមិត្តចំរុះ


ក្រុមមិត្តសមាគមខ្មែរ


ថារ៉ាសេក -អែនថូនៀល មិនឌីតា
ឌីឌី អូប្រាយអិន -ចច អាណាស្តា អេមី ភីសសៀ


ក្រុមអាគីឃែ
សុវណ្ណ ខុន-រ៉ាឌី ម៉ម សូបិន្ត-អេចេ- រ៉ដ នីអេលីយ៉ុត


រ៉ដី លើកបង្ហាញផ្លាកកោតសរសើរស្តីពីតិមានវិទ្យា


វីរអ៊ុយ-អេចេ សេង-ស៊ូសិន ឡេវីង-ពិនសំខុន-រ៉ាឌីម៉ម-ចេលៃនីហែន-បុប្ផាម៉ាឡូន


តារាឯកនៃសមាគមអង្គរ និងជាបវរកញ្ញាលេខ២
ពិភពលោក នាង វេជីឡៀ ប្រាក់


សុទ្ធា ជៀមរូម-វីរអ៊ុយ-សិកស្តុឌីយីសឹស-បុប្ផាម៉ាឡូន


ស៊ីសែនប្រមស្វែល-ភីរី និងមីសែល ប៊ីនារ៉ន-សុបិន្ត ពិន-វ៉ារី និងម៉ាលកូល រ៉សហ្វូល


ប៊ុន វិតសាត និងមិត្តភក្តិ ថតជាមួយវាគ្មិនអែនឌីផេណីថេន


រ៉ូដនី អ៊ីលីយ៉ុត - រ៉ដី ពិន -សុបិន្ត ពិន និង ចន លីហ៊ី